00755183

E1/13.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Nov-2011, 14:57
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# បើកសេចក្តីសន្និដ្ឋានចោទប្រកាន់
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១**

**ម៉ោង ០៩: ០៥នាទី**

**សវនាការអង្គសេចក្តី**

**(លើកទី១)**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

កញ្ញា ណាតាចា វិចសែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក យ៉េត ចរិយា

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក ហ្សាក់ វែកហ្សេស
*(Mr. Jacques VERGES)*

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោកស្រី ជេត វណ្ណលី

លោក ហុង គីមសួន

លោកស្រី ម៉ុច សុវណ្ណារី

លោក អេម៉ានូអ៊ែល ហ្សាកូមី
*(Mr.Emmanuel JACOMY)*

លោកបាណាបេ ណេគ្វី*(Mr.Barnabé NEKUIE)*

លោក ប៉ាទ្រីក បូឌូន *(Mr. Patrick BAUDOIN)*

លោកស្រី នូស៊ីន សាកាវ៉ាទី
*(Ms. Nushin SARKARATI)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក អាន់ឌ្រូ ខេលី | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ឌុច ផារី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

ថ្ងៃនេះអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានបង្កើតឡើងតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បើកសវនាការជាសាធារណៈលើអង្គសេចក្តីសំណុំរឿងក្តីលេខ ០០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ អវតក/អជសដ ដែលមានជនជាប់ចោទដែលជនជាប់ចោទចំនួនបីរូបដូចខាងក្រោមនេះ៖

១) ឈ្មោះនួន ជា ភេទប្រុស កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគ ឃុំវត្តគ ស្រុកសង្កែ ខេត្តបាត់ដំបង។ ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិផ្សារព្រហ្ម ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានមុខងារជាអនុលេខាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានរដ្ឋសភាតំណាងប្រជាជន មានមេធាវីការពារក្តីចំនួនបីរូប។ មួយ លោក សុន អរុណ, ពីរ លោកមៃខល ផេសមិន, បី លោកវិចទ័រ កូប៉េ។

[០៩:០៨:០២]

២) លោកអៀង សារី ឈ្មោះដើម គឹម ត្រឹង ភេទប្រុស កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅឃុំលឿងវ៉ា ស្រុកត្រាវិញ ខេត្តត្រាវិញ វៀតណាមខាងត្បូង។ ទីលំនៅមុនពេលចាប់ឃុំខ្លួននៅផ្ទះលេខ ៤៧បេ ផ្លូវលេខ ២១ ក្រុមទី៣៦ មណ្ឌល៤ សង្កាត់ទន្លេបាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានមុខងារជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស មានមេធាវីការពារក្តីចំនួនពីររូប គឺលោកអាងឧត្តម និងលោកមៃខល កាណាវាស។

៣) លោកខៀវ សំផន ភេទប្រុស កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង។ មានទីលំនៅមុនពេលចាប់ឃុំខ្លួនភូមិកូនខ្ទង់ សង្កាត់អូរតាវៅ ខណ្ឌប៉ៃលិន ក្រុង

ប៉ៃលិន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានមុខងារជាសមាជិកមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈប្រធានរដ្ឋ មានមេធាវីការពារក្ដីចំនួនពីររូប គឺមួយលោក គង់ សំអុន ពីរលោកហ្សាក់ វែកហ្សេស។

[០៩:០៩:៣៧]

ជនជាប់ចោទទាំងបីរូបនេះ ជាប់ចោទពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ តាមរយៈអំពើសកម្ម និងអកម្មបានប្រព្រឹត្តដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមរៀបចំផែនការញុះញង់ឲ្យប្រព្រឹត្តបញ្ជាឲ្យមាននូវការប្រព្រឹត្ត បានជួយ និងជំរុញដល់ចារី ឬត្រូវទទួលខុសត្រូវក្នុងនាមថ្នាក់លើ។ ប្រព្រឹត្តិនៅទីក្រុងភ្នំពេញ នៅលើទឹកដីប្រទេសកម្ពុជា និងនៅក្នុងអំឡុងពេលនៃការចូលលុកលុយទឹកដីវៀតណាមក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

បទល្មើសមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ ថ្មី និងមាត្រា៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[០៩:១០:៥៦]

សមាសភាពចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមានដូចខាងក្រោមនេះ៖

១) គឺរូបយើង និល ណុន ជាប្រធាន ២) លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ៣) លោកចៅក្រម យ៉ា សុខន ៤) លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ៥) លោកចៅក្រម យូរ ឧត្តរា និងមានចៅក្រមបម្រុងចំនួនពីររូប៖ ១) លោកចៅក្រម ធូ មណី ២) លោកចៅក្រម ក្លូឌា ហ្វេនស៍

នៅក្នុងសំណុំរឿងលេខ ០០២ នេះ មានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣៨៦៦នាក់។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវរួមបញ្ចូលជាក្រុមតែមួយ ដោយមានសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូប ១)លោក ពេជ អង្គ ២) លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត និងមានមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៤០រូប ក្នុងនោះមានមេធាវីចំនួន១២រូប និងមេធាវីអន្តរជាតិចំនួន២៨រូប។

អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសបើកសវនាការលើសំណុំរឿងក្ដីនេះចាប់ពីពេលនេះតទៅ។

[០៩:១២:១៧]

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវបានអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនាព្រឹកនេះ។ សូមអញ្ជើញ!

**លោក ឌុច ផារី៖**

សូមគោរពលោកប្រធាន! ស្ថានភាពវត្តមាន និងអវត្តមានរបស់ភាគីក្នុងសវនាការក្នុងថ្ងៃនេះមានដូចខាងក្រោម៖

ការិល័យសហព្រះរាជអាជ្ញាមានវត្តមានគ្រប់ចំនួន។

ក្រុមមេធាវីការពារជនជាប់ចោទ នួន ជា មានវត្តមានគ្រប់ចំនួន។

ក្រុមមេធាវីការពារជនជាប់ចោទ អៀង សារី មានវត្តមានគ្រប់ចំនួន។

ក្រុមមេធាវីការពារជនជាប់ចោទ ខៀវ សំផន មានវត្តមាន។

នៅក្នុងថ្ងៃនេះក្រុមមេធាវីរបស់ ខៀវ សំផន ក៏មានវត្តមានរបស់លោកមេធាវី គង់ សំអុន ដែលដែលទើបតែត្រូវបានតែងតាំងថ្មីជំនួសលោកមេធាវី ស សូវាន ដែលបានលាលែងពីតំណែងផងដែរ។

[០៩:១៣:១៩]

ជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន មានវត្តមាន។

មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានវត្តមាន ហើយក៏មានវត្តមានរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបរទេសចំនួនបីរូប គឺលោកបាណាបេ ណេគ្វី លោកប៉ាទ្រីក បូឌូន និងលោកស្រី ម៉ារី ហ្គីរ៉ូដ ដែលមិនទាន់ត្រូវបានទទួលស្គាល់នៅចំពោះអង្គជំនុំជម្រះផងដែរ។

[០៩:១៣:៥១]

ក្នុងសវនាការថ្ងៃនេះ មានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១១នាក់ ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមបញ្ជាក់បន្ថែមលើ មេធាវីការពារក្ដី ខៀវ សំផន ដូចជាមានវត្តមានមេធាវីអន្តរជាតិមួយរូបទៀត? នៅជិត គង់ សំអុន យ៉ាងម៉េចដែរ?

**គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី វែកគែន គាត់ត្រូវបានស្នើសុំដោយលោក ខៀវ សំផន ដើម្បីសូមការពារបន្ថែម ក៏ប៉ុន្តែដោយសារនីតិវិធីស្បថមិនទាន់ធ្វើចប់សព្វគ្រប់ ដូច្នេះយើងមកឱ្យគាត់នៅទីនេះ ដើម្បីស្ដាប់ដំណើរការនីតិវិធីនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

តើលោកមេធាវី គង់ សំអុន លោកមេធាវីហ្នឹង គាត់បានចុះឈ្មោះនៅគណៈមេធាវីកម្ពុជាហើយ ឬនៅ?

**លោក គង់ សំអុន៖**

រៀបចំចុះឈ្មោះហើយលោកប្រធាន ក៏ប៉ុន្តែការស្បថជាចុងក្រោយនៅមិនទាន់បានចង់សព្វគ្រប់ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សូមអញ្ជើញលោក!

[០៩:១៥:២០]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ។ សូមគោរពលោកប្រធាន។ ខ្ញុំ សុន អរុណ មេធាវីការពារលោក នួន ជា។ ថ្ងៃនេះខ្ញុំមានកិត្តិយសនិងសូមជម្រាបជូនតុលាការ ជូនលោកប្រធាន ដោយមានមេធាវីម្នាក់ទើបតែបានចុះឈ្មោះនៅក្នុងគណៈមេធាវីរួចហើយ ហើយបានធ្វើស្បថពីម្សិលពីថ្ងៃសុក្រ ទី១៨ ស្បថរួចហើយ ហើយបានសរសេរសំបុត្រមួយមួយទៅ ស៊ូហ្សាន ឡេម រួចទៅហើយ។ សូមតុលាការទទួលស្គាល់លោក អាន់ឌ្រូ យ៉ានុយហ្ស៊ី ជាមេធាវីពេញលក្ខណៈរបស់ក្រុម នួន ជា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អគុណលោកមេធាវី ប៉ុន្តែអង្គជំនុំជម្រះមិនទាន់បានរៀបចំនូវឯកសារទេ ប្រហែលមានការយឺតយ៉ាវនៅក្នុងការបញ្ជូនមក។ ដូច្នេះអង្គជំនុំជម្រះទុកបញ្ហានេះរៀបចំនៅពេលក្រោយ មិនហួសពេលទេ យើងអាចធ្វើពេលណាក៏បាន ហើយនីតិវិធីនេះយើងប្រព្រឹត្តទៅនៅក្នុងលក្ខខណ្ឌនៃកិច្ចការមួយចំនួនដែលពាក់ព័ន្ធទៅនឹងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ បើកកិច្ចដំណើរការសវនាការប៉ុណ្ណោះ។ ក្រោយពេលសម្រាកនេះ យើងនឹងពិនិត្យនូវឯកសារទាំងអស់ដែលពាក់ព័ន្ធ ដើម្បីយើងរៀបចំទទួលស្គាល់មេធាវីតាមនីតិវិធី ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។ នោះយើងទើបអាចដំណើរការប្រព្រឹត្តទៅបាន។

[០៩:១៧:០១]

បាទ,អម្បាញ់មិញនេះ គឺបានស្តាប់នូវលោកក្រឡាបញ្ជីសវនាការបានបង្ហាញជូនមករាយការណ៍ដល់អង្គជំនុំជម្រះអំពីវត្តមានរបស់មេធាវីការពារក្តី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលជា

មេធាវីអន្តរជាតិ មិនទាន់បានធ្វើការបង្ហាញ និងទទួលស្គាល់ដោយអង្គជំនុំជម្រះ។

ហេតុដូច្នេះដើម្បីបំពេញកិច្ចដំណើរនីតិវិធីនេះ សូមអញ្ជើញលោកមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក ពេជ អង្គ ឡើងធ្វើការសុំទទួលស្គាល់មេធាវីអន្តរជាតិ។

**លោក ពេជ អង្គ៖**

*(មីក្រូហ្វូនមិនដំណើរការ)*

[០៩:១៨:១៩]

**ប្រធានអង្គជំនុំ៖**

អត់ឮទេ, មើលៗខាងមន្ត្រីតុលាការពិនិត្យមើល!

*(ឧបករណ៍ថតសំឡេងមិនដំណើរការពីម៉ោង៩:១៨:១៩ ដល់ម៉ោង០៩:១៩:៤៦)*

លោក ពេជ អង្គ អង្គុយសិនចុះ ចាំ--

*(មានបញ្ហាបច្ចេកទេស)*

[០៩:២៣:១០]

**លោក គង់ សំអុន៖**

លោកប្រធាន។ ឆ្លៀតឱកាសនេះ ដោយសារលោកប្រធានកំពុងរង់ចាំ។ ខ្ញុំបាទសុំអនុញ្ញាតអ្នកបច្ចេកទេសម្នាក់ជួយពិនិត្យមើល *ម៉ៃស៍* កុំព្យូទ័រខ្ញុំបាទផងវាអត់ដើរបាទ។ សូមអធ្យាស្រ័យ។

**ប្រធានអង្គជំនុំ៖**

ឥឡូវឮវិញឬនៅ? បាទ? ឥឡូវសូមអញ្ជើញលោក ពេជ អង្គ បន្តធ្វើការស្នើសុំទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានវត្តមាននៅពេលនេះ ហើយសវនាការពីមុនៗមិនទាន់ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង។ ហើយខាងមន្ត្រីរដ្ឋបាលសូមរៀបចំនូវ មើលកុំព្យូទ័ររបស់មេធាវីការពារក្តី នួន ជា ផង បញ្ហា *ម៉ៅស៍* អត់ដើរទេ។

សូមអញ្ជើញលោក ពេជ អង្គ!

*(មានបច្ចេកទេសប្រព័ន្ធសំឡេង)*

[០៩:២៤:៤១]

បាទ,ឥឡូវដោយមានបញ្ហាបច្ចេកទេសប្រព័ន្ធសំលេងខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបញ្ហា ហើយផ្នែកផ្សេងទៀតមិនមានបញ្ហាទេ។ ដូច្នេះ អង្គជំនុំជម្រះទុកការស្នើសុំទទួលស្គាល់

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទុកមួយអន្លើសិន។ អង្គជំនុំជម្រះបន្តនូវកិច្ចដំណើរការផ្សេងទៀត។

អង្គជំនុំជម្រះសូមជម្រាបថាគោលបំណងនៃសវនាការនៅសប្តាហ៍នេះ គឺជាសវនាការបើកសេចក្តីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេបដោយសហព្រះរាជអាជ្ញា និងការឆ្លើយតបដោយសង្ខេបពីសំណាក់ជនជាប់ចោទ និងក្រុមមេធាវីការពារក្តីរបស់ខ្លួន។ ឯសវនាការដេញដោយពិនិត្យភស្តុតាង និងចាប់ផ្តើមធ្វើពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១។

តាមការកំណត់កាលបរិច្ឆេទសវនាការចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ឯកសារE131 បានបញ្ជាក់ថាសវនាការនេះនឹងចាប់ផ្តើមដោយការអានបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទដូចមានចែងនៅក្នុងវិធាន៨៩ស្ទួនមួយ និងនៃវិធានផ្ទៃក្នុង។

[០៩:២៦:២៤]

អង្គជំនុំជម្រះនឹងមិនអាចនូវការវិភាគអង្គហេតុនេះ ពីព្រោះការវិភាគអង្គហេតុទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានជូនដំណឹងដល់ជនជាប់ចោទ និងភាគីរួចហើយ។

ជាកិច្ចបន្តទៅនេះ ដើម្បីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់អំពីបទចោទដែលចោទប្រកាន់លើជនជាប់ចោទទាំងបីរូប និងជាការអនុវត្តតាមវិធាន៨៩ស្ទួន កថាខណ្ឌមួយ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះចាត់លោក ឌុច ផារី ជាក្រឡាបញ្ជីសវនាការឡើងអាននូវបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទទាំងបីរូប។

សូមអញ្ជើញលោក ឌុច ផារី!

[០៩:២៧:១៧]

**លោក ឌុច ផារី៖**

សូមគោរពលោកប្រធាន!

បទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទមានដូចខាងក្រោម៖

ដោយផ្អែកលើដីកាដំណោះស្រាយដែលបានកែប្រែដោយសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលមានឯកសារ D427/3/15 ឯកសារ D427/4/15 និងឯកសារ D427/1/30 និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តីទាក់ទងនឹងអាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ ដែលមានឯកសារ E122 ជន

ជាប់ចោទ នួន ជា, អៀង សារី, ខៀវ សំផន គឺត្រូវបានចោទប្រកាន់ពីបទល្មើសដូចខាងក្រោម៖

តាមរយៈអំពើសកម្ម និងអកម្មនៅទីក្រុងភ្នំពេញនៅលើទឹកដីប្រទេសកម្ពុជា និងនៅក្នុងអំឡុងពេលនៃការចូលលុកលុយចូលទឹកដីវៀតណាម ក្នុងរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បានប្រព្រឹត្តដោយបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម រៀបចំផែនការញុះញង់ឲ្យប្រព្រឹត្ត បញ្ជាឲ្យមានការប្រព្រឹត្តនៅឧក្រិដ្ឋកម្មដូចខាងក្រោម៖ បានជួយ និងជំរុញដល់អ្នកចារី ឬត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើកនូវបទចោទប្រកាន់ដូចខាងក្រោម៖

[០៩:២៩:០៥]

១)ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមមាន៖ ក)ការធ្វើមនុស្សឃាត ខ) ការសម្លាប់រង្គាល គ) ការធ្វើឲ្យទៅជាទាសករ ឃ) ការនិរទេស ង) ការដាក់ក្នុងមន្ទីរឃុំឃាំង ច) ការធ្វើទារុណកម្ម ឆ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ជ) អំពើអមនុស្សធម៌ផ្សេងៗទៀត។

[០៩:២៩:៣៧]

បទល្មើសដែលមានចែងនិងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី)នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។

២) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុមចាម និងវៀតណាម បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៤ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី)នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។

៣) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ រួមមាន៖ ក)ការធ្វើមនុស្សឃាតដោយចេតនា ខ)ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ គ)ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព ឃ)ការដកហូតចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោស ដោយយុត្តិធម៌ និងទៀងទាត់ ង)ការនិរទេស និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

[០៩:៣០:៥៤]

បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៦ មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។

យោងដីកាបំបែកដំណើរការនីតិវិធីចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារE138 នៅក្នុងសវនាការដំបូងនៃសំណុំរឿងលេខ០០២ ដែលមានជនជាប់ចោទឈ្មោះ នួន ជា, អៀង សារី និង ខៀវ សំផន នេះអង្គជំនុំជម្រះនិងពិនិត្យលើភស្តុតាងដែលទាក់ទងនឹងអង្គហេតុដូចខាងក្រោម៖

[០៩:៣១:៤៦]

ក)ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា រួមទាំងតួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងអំឡុងពេលមុនការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ។

ខ)រចនាម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យរួមទាំងអង្គហេតុស្ដីពីរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនង រចនាសម្ព័ន្ធយោធា។

គ)តួនាទីរបស់ជនជាប់ម្នាក់ៗនៅក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ទំនួលខុសត្រូវរបស់ជនជាប់ចោទតាមការចាត់តាំង វិសាលភាពនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ និងខ្សែបណ្ដាញទំនាក់ទំនងក្នុងរយៈកាលក្រោមយុត្តាធិការរបស់អ.វ.ត.ក។

ឃ)គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្ដីពីបញ្ហាទាំងប៉ុន្មានដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[០៩:៣២:៤១]

ង)អង្គហេតុដែលបានចោទប្រកាន់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីប្រជាជនដំណាក់កាលទីមួយ និងទីពីរ។

ច)ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ។ លើកលែងតែការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។ ការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ ដែលចំណុចទាំងអស់នេះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីមួយ និងដំណាក់កាលទីពីរ។

ក្នុងអំឡុងពេលនៃការជំនុំជម្រះដំណាក់កាលដំបូងនេះ អង្គជំនុំជម្រះអាចសម្រេចផ្លាស់ប្ដូរប្រធានបទទាំងនេះ ឬបន្ថែមប្រធានបទផ្សេងទៀតដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២ បានគ្រប់ពេលទាំងអស់។ ទោះជាយ៉ាងណាអង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគីទាំងអស់

និងមេធាវីការពារក្ដីឲ្យបានដឹងជាមុន ដើម្បីឲ្យមេធាវីការពារក្ដីមានឱកាសគ្រប់គ្រាន់ក្នុងការត្រៀមរៀបចំការពារក្ដីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

សូមអរគុណលោកប្រធាន។

[០៩:៣៣:៤៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកផារី។

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់យ៉ាងសង្ខេប តែមុននឹងផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមរំឭក ដើម្បីជូនសហព្រះរាជអាជ្ញាជ្រាបថា៖ អនុលោមតាមដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ឯកសារលេខE131 ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាអាចនឹងធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបអំពីបទចោទប្រកាន់ ប្រឆាំងជនជាប់ចោទនាពេលនេះ ដោយអនុលោមតាមវិធាន៨៩ស្ទួន កថាខណ្ឌ២ នៃវិធានផ្ទៃក្នុង។

សហព្រះរាជអាជ្ញាឡើងធ្វើសេចក្ដីសន្និដ្ឋាន!

[០៩:៣៥:១៨]

លោកជំទាវសាកល្បងមើលឮទេ?

**លោកស្រី ជា លាង៖**

ឮទេ? ឮទេ? អូខេ។

**ប្រធានអង្គជំនុំ៖**

បាទ,ជាបន្ត ហើយអង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា ជាបន្តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីឡើងធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេប។ តែមុននឹងផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមរំឭកជូនសហព្រះរាជអាជ្ញាថា អនុលោមតាមដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ ឯកសារ E131 ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាអាចឡើងធ្វើសេចក្ដីសន្និដ្ឋានសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ ដែលអនុលោមតាមវិធាន៨៩ស្ទួន កថាខណ្ឌពីរនៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាឡើងធ្វើសេចក្ដីសន្និដ្ឋានសង្ខេបចោទប្រកាន់លើសំណុំរឿងក្ដី០០២ទាំងមូល ហើយអង្គជំនុំ

ជម្រះសូមផ្តល់នូវថិរវេលាមួយថ្ងៃកន្លះសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នេះ។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

[០៩:៣៧:០៥]

សូមអញ្ជើញលោកមេធាវី!

លោកជំទាវអាចអង្គុយសិន។

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំសូមរំខាន ខ្ញុំសូមបញ្ជាក់ជូន ហើយមុននឹងចាប់ផ្តើម។ តំណាងអយ្យការចាប់ផ្តើមនូវសេចក្តីសន្និដ្ឋានចោទប្រកាន់ ខ្ញុំសូមបញ្ជាក់ថា យើងខ្ញុំទើបតែដាក់ៗជូនទៅលោកស្រីចៅក្រម ខាតរាយថ៍ ទាក់ទងទៅមាត្រា៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយវិធាន៥៥ ហើយពាក្យសុំហ្នឹង គឺរាប់បញ្ចូលទាំងសំណើជាក់លាក់។ សូមឲ្យចៅក្រម ខាតរាយថ៍ ដកខ្លួនចេញរង់ចាំសម្រេចពីរឿងសំណើរបស់យើងខ្ញុំនេះ។ យើងបានស្នើថា ភាគី ហើយនិងចៅក្រមទាំងឡាយឲ្យបានអានពាក្យសុំនេះ ហើយពិនិត្យឡើងវិញនូវពាក្យបណ្តឹងទាំងនោះផងដែរ។ សូមអរគុណ។

[០៩:៣៨:១៨]

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយសូមជម្រាបសួរអ្នកចូលរួមទាំងអស់។ នៅថ្ងៃសុក្រយើងបានដាក់ពាក្យមួយចំនួន ហើយនិងបានចែកជូននូវសំណើសុំឲ្យមានការសង្កេតស៊ើបអង្កេតទាក់ទងទៅនឹងការប្រជុំរវាងលោក ខេលី និងចៅក្រម ខាតរ៉ាយថ៍ អំពីការប្រជុំដោយគ្មានភាគីចូលរួមជាមួយលោក រ៉ូសាន់ហោក។ ហើយប្រហែលជាមានបញ្ហាមួយចំនួនទៀត នៅក្នុងសំណើរបស់យើងខ្ញុំនោះ យើងបានចង្អុលបង្ហាញថា យើងចង់ឲ្យអង្គជំនុំជម្រះសាលាដំបូង កោះអញ្ជើញលោក ខេលី ដើម្បីផ្តល់ព័ត៌មាន ហើយជំរុញឲ្យលោកស្រីចៅក្រម ខាតរាយថ៍ ឲ្យផ្តល់នូវសេចក្តីថ្លែងការណ៍ ឬកំណត់ហេតុ ហើយយើងក៏បានស្នើថា ត្រូវគោរពទៅតាមនីតិវិធីដ៏ត្រឹមត្រូវ ហើយអាចនឹងល្អបំផុត ប្រសិនបើចៅក្រម ខាតរ៉ាយថ៍ ដកខ្លួនចេញ ហើយអនុញ្ញាតឲ្យចៅក្រម ហ្វេនស៍ ចូលមកជំនួសគាត់វិញក្នុងសវនាការនេះ។ ដោយសារថាគាត់ជាចៅក្រមបម្រុង អ៊ីចឹងគឺយើងអាចដោះស្រាយបញ្ហានេះបាន។

[០៩:៣៩:២៦]

ពាក្យបណ្តឹងនោះត្រូវបានច្រានចោលដោយសារថា ដោយសារថាមិនមានភាសាខ្មែរនៅក្នុងរយៈ

ពេលពីរថ្ងៃក្រោយនោះ។ ប៉ុន្តែយើងបានបញ្ជូននូវដំណឹងនោះ ហើយចៅក្រមគ្រប់រូប យើងដឹងថាបានជ្រាបពីបញ្ហានេះ ហើយយ៉ាងហោចណាស់មុននឹងចូលដល់បញ្ហានេះដោះស្រាយរួច។ ហើយយើងចាត់ថាទុកបញ្ហានេះសំខាន់ ប្រសិនបើចៅក្រមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះ ហើយមានសហព្រះរាជអាជ្ញាបានជួបដោយមិនមានវត្តមានភាគីផ្សេងទៀត ហើយជាការជួបនោះ គឺខុសនីតិវិធី ហើយបើទុកឱ្យសហព្រះរាជអាជ្ញា ឬចៅក្រមរូបនោះចូលរួមដំណើរការនេះ ហាក់ដូចជាមិនសមស្រប។ ហើយយើងមិនបានទទួលនូវសិទ្ធិ និងបុព្វសិទ្ធិស្មើគ្នាដូចលោក ខេលី នោះទេ ជាពិសេសនឹងចៅក្រមរូបនោះដែលបានចូលរួមប្រជុំពិភាក្សាពីបញ្ហាដោយមិនមានវត្តមានពួកមេធាវីការពារក្តី។ ហើយយើងគាំទ្រសំណើរបស់មេធាវីរបស់លោក នួន ជា ថាឱ្យចៅក្រម ខាតវ៉ាយថ៍ ដកខ្លួនចេញ តាំងខ្លួនជាចៅក្រមបម្រុង ហើយសូមឱ្យចៅក្រម ហ្វេនស៍ ជំនួសតំណែងរបស់គាត់ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៅពេលនេះ។ សូមអរគុណ។

[០៩:៤១:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបដល់មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី អៀង សារី និងអង្គសវនាការទាំងមូលជ្រាបថា អង្គជំនុំជម្រះពិតជាបានទទួលសំណើសុំព័ត៌មានពីមេធាវី នួន ជា ពាក់ព័ន្ធនឹងការប្រជុំក្រៅផ្លូវការរវាងចៅក្រម ខាតវាយថ៍ សហព្រះអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាលកាលពីថ្ងៃទី០៤ និងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ រួចហើយពិតប្រាកដមែន។ អង្គជំនុំជម្រះនឹងឆ្លើយតបទៅនឹងបញ្ហានេះក្នុងពេលវេលាសមស្រប។ កាលពីថ្ងៃសុក្រ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ មេធាវី អៀង សារី ក៏បានបញ្ជូននូវសំណើស្រដៀងគ្នានេះមកអង្គជំនុំជម្រះសាលាដំបូងជាលក្ខណៈប្រាប់ឱ្យដឹងជាមុនផងដែរ។ អង្គជំនុំជម្រះសាលាដំបូងនឹងឆ្លើយតបទៅនឹងសំណើនេះបន្ទាប់ពីសំណើនេះត្រូវបានជូនដំណឹងស្របតាមលក្ខខណ្ឌនៃការដាក់ឯកសារ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់ថា កន្លងមកអនុប្រធានការិយាល័យរដ្ឋបាលធ្លាប់បានឆ្លើយតបទៅនឹងសំណើនេះម្តងរួចមកហើយ។ សំណើនេះ នាពេលនេះមិនមានខ្លឹមសារអ្វីខុសពីសំណើមុនៗនោះទេ។ គោលបំណងនៃសវនាការនាពេលប៉ុន្មានថ្ងៃនេះ គឺជាសវនាការត្រូវធ្វើឡើងដើម្បីស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ប្រឆាំងទៅនឹងជនជាប់ចោទ និងសេចក្តីសន្និដ្ឋានតបរបស់មេធាវីការពារក្តី និងជនជាប់ចោទ ទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា។

ដូច្នេះអង្គជំនុំជម្រះសាលាដំបូងបដិសេធនូវការប៉ុនប៉ងរារាំងមិនឲ្យកិច្ចដំណើរការសវនាការនាពេលនេះប្រព្រឹត្តទៅបាន និងមិនអនុញ្ញាតឲ្យភាគីធ្វើអន្តរាគមន៍លើបញ្ហាផ្សេងៗក្រៅពីរបៀបវារៈបញ្ហាដែលបានដាក់សម្រាប់សវនាការនាពេលនេះឡើយ។

សូមអញ្ជើញលោកស្រី-- លោកជំទាវសហព្រះរាជអាជ្ញាអន្តរជាតិ!

អញ្ជើញលោក អាង ឧត្តម!

[០៩:៤៤:៤៥]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការ។ ក្រោយពីបានឮសេចក្ដីប្រកាសរបស់លោកប្រធានថា យ៉ាងណាក្ដីសំណើសុំឲ្យលោកស្រីចៅក្រមខាតរាយថ៍ ដកខ្លួនក្នុងដំណើរការនេះមិនអាចអនុវត្តបានទេ គឺនៅតែបន្ត។ អ៊ីចឹងមុននឹងចាប់ផ្ដើម ខ្ញុំបាទសូមជម្រាបលោកប្រធាន និងអង្គសវនាការថា លោកអៀង សារី មានសេចក្ដីប្រកាសមួយ ហើយសេចក្ដីប្រកាសផ្ទាល់ខ្លួនរបស់គាត់ចង់ ហើយសូមអនុញ្ញាតឲ្យធ្វើមុនគេ និងជាបឋមបំផុត សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យលោកអៀង សារី ប្រកាសនូវសេចក្ដីថ្លែងរបស់គាត់ តាមរយៈសេចក្ដីថ្លែងនេះខ្ញុំបាទទទួលការអនុញ្ញាតឲ្យអានជំនួសគាត់។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតតាមសំណើនេះទេ ខុសពីគោលដៅនៃសវនាការសម្រាប់ថ្ងៃនេះ។ អង្គជំនុំជម្រះបានប្រាប់ជម្រាបមេធាវីរួចហើយ ដូច្នេះក្រៅពីរបៀបវារៈដែលបានកំណត់នេះ គឺអង្គជំនុំជម្រះមិនអនុញ្ញាតឡើយ។

សូមអញ្ជើញលោកជំទាវសហព្រះរាជអាជ្ញាជាតិ!

[០៩:៤៦:១៧]

**លោកស្រី ជា លាង៖**

សូមអរគុណ។ លោកប្រធាន លោកស្រី ចៅក្រម និងសាធារណជនទាំងអស់ជាទីគោរព។ ភស្តុតាងដែលយើងខ្ញុំនឹងដាក់ជូននៅចំពោះមុខលោក លោកស្រីចៅក្រមនាពេលនេះ នឹងបង្ហាញឲ្យឃើញដោយគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អំពីបក្សកុម្មុយនីស្តកម្ពុជា ដែលបានបង្វែរកម្ពុជាឲ្យធ្លាក់ចូលទៅក្នុងជំរំទាសករមហាជន ដោយបានបង្រួមប្រជាជននៅទូទាំងប្រទេសឲ្យទៅជាទាសករ

រស់នៅក្រោមប្រព័ន្ធមួយដ៏ឃោរឃៅយង់ឃ្នង ដែលគេពិបាកជឿបាន រហូតមកដល់សព្វថ្ងៃនេះ។

ការជម្លៀសដោយបង្ខំចំពោះទីក្រុងនានារបស់ប្រទេសកម្ពុជា ការធ្វើឲ្យទៅជាទាសករនៃប្រជាជនរាប់លាននាក់ក្នុងជំរំការងារដោយបង្ខំ ការកម្ទេចជីវិតមនុស្សរាប់រយសែននាក់តាមបណ្តាមន្ទីរសន្តិសុខ និងវាលពិឃាដដ៏អសោចនានា ការសម្លាប់រង្គាលចំពោះជនជាតិភាគតិច ការស្លាប់មនុស្សដ៏ច្រើនឥតគណនាបណ្តាលមកពីជំងឺ ការធ្វើការងារហួសកម្លាំង ការរំលោភ និងការបង្អត់អាហារ ដែលឧក្រិដ្ឋកម្មទាំងនេះត្រូវបានបញ្ជា និងរៀបចំឡើងដោយជនជាប់ចោទ ដែលជាឧក្រិដ្ឋកម្មដ៏មហារន្ធត់ដែលប្រទេសជាតិមួយមិនធ្លាប់ទទួលរងក្នុងប្រវត្តិសាស្ត្រសម័យទំនើបនេះ។

[០៩:៤៧:៥០]

ប្រជាជនកម្ពុជាគ្រប់រូបដែលនៅរស់រានមានជីវិតពីសម័យនោះ បានទទួលរងនូវផលប៉ះពាល់ពីប្រព័ន្ធឧក្រិដ្ឋដ៏គាបសង្កត់មួយនេះ ដែលជនជាប់ចោទបានដាក់ចេញ។ ចំនួនមនុស្សស្លាប់សរុបធ្វើឲ្យយើងរន្ធត់ណាស់ ដោយអ្នកជំនាញខាងប្រជាសាស្ត្រដែលបានចាត់តាំងដោយសហចៅក្រមស៊ើបអង្កេតបានធ្វើការប៉ាន់ប្រមាណមានចំនួនចន្លោះពី មួយលានប្រាំពីរសែននាក់ទៅពីរលានពីរសែននាក់ បានស្លាប់បាត់បង់ជីវិត ដែលបណ្តាលមកពីលទ្ធផលនៃការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ។ ចំនួននេះគឺប្រហែលជាប្រជាជនមួយនាក់ក្នុងបួននាក់ បានបាត់បង់ជីវិតដោយរបបនេះ។ មកដល់បច្ចុប្បន្ននេះមានប្រជាជនកម្ពុជាក្នុងចំនួនដ៏ច្រើនបានទទួលរងផលប៉ះពាល់ដល់អារម្មណ៍ធ្ងន់ធ្ងរ ដែលបានកើតចេញពីស្នាដៃរបស់របបនោះ។

[០៩:៤៨:៥៤]

ផ្អែកលើទំហំនៃព្រឹត្តិការណ៍ទាំងនេះ គ្មានការជំនុំជម្រះក្តីណាអាចធ្វើបានគ្រប់បទឧក្រិដ្ឋទាំងអស់ដែលត្រូវចោទប្រកាន់ចំពោះជនជាប់ចោទនោះទេ។ អាស្រ័យហេតុនេះ ព្រឹត្តិការណ៍និងទីតាំងឧក្រិដ្ឋកម្មនានាដែលបានបញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាតួយ៉ាងដែលតំណាងឲ្យឧក្រិដ្ឋកម្មទាំងនេះ។

ព្រឹត្តិការណ៍ និងឧក្រិដ្ឋកម្មទាំងនោះរួមមាន ការផ្លាស់ដោយបង្ខំក្នុងទ្រង់ទ្រាយធំក្នុងឆ្នាំ១៩៧៥ មានចំនួនពីរលើក ពលកម្មដោយបង្ខំមានប្រាំកន្លែង ការធ្វើទុក្ខបុកម្នេញចំពោះពុទ្ធសាសនិកជនឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ជាផ្នែកនៃគោលនយោបាយនៃអាពាហ៍ពិពាហ៍ដោយបង្ខំ មន្ទីរសន្តិសុខ១១កន្លែង អំពើប្រល័យពូជសាសន៍ចាម អំពើប្រល័យពូជសាសន៍ក្រុមជាតិពន្ធុវៀតណាម និងឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀត ក្នុងសង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម។ ជាចុងក្រោយការផ្លាស់ទី

ដោយបង្ខំក្នុងដំណាក់កាលទីបី និងការសម្លាប់រង្គាលក្នុងអំឡុងពេលនៃការបោសសម្អាតភូមិភាគបូព៌ា។ ខ្ញុំនឹងលើកយកមកបង្ហាញនូវសង្ខេបអំពីឈុតឧក្រិដ្ឋកម្មនីមួយៗទាំងនេះដូចខាងក្រោម៖

[០៩:៥០:១៤]

១) អំពីការជម្លៀសដោយបង្ខំក្នុងដំណាក់កាលទីមួយ៖ សុបិនអាក្រក់នៃការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា បានចាប់ផ្តើមឡើងជាមួយនឹងការជម្លៀសដោយបង្ខំ និងជាប្រព័ន្ធប្រជាជនចេញពីទីក្រុង ទីប្រជុំជនទាំងអស់ នៅពេលកងកម្លាំងខ្មែរក្រហមបានផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ការជម្លៀសដោយបង្ខំនូវប្រជាជនទីក្រុងភ្នំពេញ ដូចបានរៀបរាប់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះថា ជាការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលជាកម្មវត្ថុនៃការជំនុំជម្រះលើកដំបូងនេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

[០៩:៥១:០៥]

ខ្ញុំសូមបង្វែរចំណាប់អារម្មណ៍របស់លោក លោកស្រីចៅក្រម ត្រឡប់ទៅកាន់ថ្ងៃដំបូងនៃខែមេសាឆ្នាំ១៩៧៥ នៅពេលនោះ សង្គ្រាមស៊ីវិលរយៈពេលប្រាំឆ្នាំរវាងកងកម្លាំងខ្មែរក្រហម និងរបបសាធារណរដ្ឋខ្មែរ ខិតកាន់តែជិតដល់ទីបញ្ចប់ហើយ។ ខ្មែរក្រហមបានចូលត្រួតត្រាតំបន់ភាគច្រើនរបស់ប្រទេស ហើយកងវរសេនាតូចប្រហែល១០០កង បានកំពុងតែរុលចូលមកដល់រាជធានី ពីគ្រប់ទិសទីទាំងអស់។

ទីប្រជុំជនអ្នកលឿង ស្ថិតនៅភាគខាងកើតទីក្រុងភ្នំពេញបានដួលរលំនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ គ្រប់ផ្លូវថ្នល់នៅសងខាងក្នុង និងខាងក្រៅទីក្រុងភ្នំពេញត្រូវបានរាំងខ្ទប់ ហើយការការពារទីក្រុងជាចុងក្រោយក៏ត្រូវបានផ្តួលរលំដែរ។ ចន ស្វេន ជាអ្នកកាសែតបរទេសម្នាក់ដែលបានត្រឡប់មកភ្នំពេញវិញ មិនយូរប៉ុន្មានបន្ទាប់ពីទីក្រុងនេះបានដួលរលំ។ ការរៀបរាប់ពីភាពវឹកវរនៅចំពោះកណ្តាលទីក្រុងភ្នំពេញនេះ នៅខណៈដែលជនភៀសសឹកកំពុងតែភៀសខ្លួននៅពេលកងកម្លាំងខ្មែរក្រហមកំពុងតែរុលចូលថា ការព្យាយាមដើម្បីបង្ខាំងអ្នកជម្លៀសកុំឲ្យទៅជាយក្រុងត្រូវបានបញ្ចប់ ហើយពួកគេកំពុងតែសំដៅទៅរកកន្លែងមួយពីគ្រប់ទិសទីទាំងអស់។ ដោយការរុញច្រានប្រជ្រៀតគ្នាក្នុងក្តីអស់សង្ឃឹម ដើម្បីរកច្រករត់ចេញពីការប្រយុទ្ធគ្នា។

[០៩:៥២:៤៧]

ផ្លូវដើរស្អាត និង សួនច្បារ ដែលមានផ្កាក្រអូបឈ្ងុយឈ្ងប់ត្រូវបានពន្លិចបាត់ស្រមោល ដោយហ្វូងមហាគ្រួសារដែលអត់ផ្ទះសម្បែង ដោយម្នាក់ៗសម្រក់ទឹកភ្នែក បាត់បង់កូនចៅ ទាំងអស់គ្នាពោរពេញដោយការភ័យខ្លាច។ ដើម្បីយល់ឲ្យបានពេញលេញអំពីឧក្រិដ្ឋកម្មនៃការបញ្ជាឲ្យជម្លៀសមនុស្សចេញពីទីក្រុងភ្នំពេញ ជាការសំខាន់ណាស់ ដែលគេត្រូវយល់អំពីស្ថានភាពមនុស្សធម៌ដ៏អាក្រក់នៅក្នុងទីក្រុងនៅក្នុងខែមេសា ឆ្នាំ១៩៧៥។ ទីក្រុងកំពុងតែអស់ម្ហូបអាហារ និងថ្នាំពេទ្យសម្រាប់ការផ្គត់ផ្គង់ ហើយមន្ទីរពេទ្យនានាពេញហៀរដោយទាហាន និងជនស៊ីវិលដែលរងរបួស។

ទីភ្នាក់ងារក្រុងស្រុក និងអន្តរជាតិ បានព្រមានអំពីមហន្តរាយមនុស្សធម៌ដែលកាន់តែខិតចូលមកដល់ និងបានផ្តល់នូវកិច្ចសហការជាមួយនឹងកងកម្លាំងដែលកំពុងតែរុលចូលមក ដើម្បីរៀបចំផ្តល់ជំនួយឲ្យបានប្រសិទ្ធភាព និងដើម្បីជួយសម្រាលការឈឺចាប់របស់មនុស្សរាប់លាននាក់។ សណ្ឋាគារឡឺភ្នំជាកន្លែងស្នាក់អាស្រ័យរបស់អ្នកកាសែត និងបុគ្គលិកផ្តល់ជំនួយជាច្រើននាក់។ សណ្ឋាគារនេះក៏បានប្រកាសថា ជាកន្លែងអព្យាក្រឹត្យ ដោយកាកបាទក្រហម និងបានយកធ្វើជាកន្លែងមួយក្នុងកន្លែងនានា សម្រាប់ទទួលអ្នករបួស។

[០៩:៥៤:១៦]

នេះជាសេចក្តីរៀបរាប់របស់ ចន ស្វេន ពីទិដ្ឋភាពដែលគាត់បានឃើញដោយផ្ទាល់នៅកន្លែងលេងបាល់ទះក្នុងសណ្ឋាគារថា មានវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា ប៉ុន្មាន១២នាក់កំពុងតែពាក់ព័ន្ធជាមួយនឹងករណីជាង ៧០០។ ប្រធានពេទ្យកំពុងតែអស់សង្ឃឹម អ្នករបួសត្រូវបានគេតម្រៀបគរលើគ្នាដូចគល់ឈើ ដោយមានអ្នករបួសពីរនាក់ ឬបីនាក់ត្រូវបានដាក់នៅលើគ្រែតែមួយ កម្រាលប្រឡាក់ដោយឈាម។ ខណៈនៃការរួលរលំទីក្រុងជៀសមិនផុត ការភ័យខ្លាច និងសេចក្តីរំពឹងក៏បានចាប់មកពីអ្នករស់នៅក្នុងទីក្រុង អំពើយង់ឃ្នងរបស់ខ្មែរក្រហមត្រូវបានគេរាយការណ៍ថា ភាពរីកសាយភាយគ្រប់ទិសទី។ ពួកគេបានបណ្តេញប្រជាជនចេញពីភូមិនានា ដែលបានធ្លាក់ក្នុងការត្រួតត្រារបស់ខ្លួន។

អំពើនេះបានធ្វើឲ្យប្រជាជនមូលដ្ឋានទៅជាទាសករ បកស្បង់ចីពរព្រះសង្ឃ បិទវត្តអារាម និងសម្លាប់អ្នកណាដែលតវ៉ានឹងការគ្រប់គ្រងរបស់ពួកគេ។

[០៩:៥៥:២៤]

ក្នុងនាមជាថ្នាក់នាំម្នាក់ ខៀវ សំផន បានបដិសេធច្រើនលើកច្រើនសា ចំពោះការចរចាសន្តិភាពដែលបានស្នើឡើងដោយ លន់ នល់។ ទោះបីយ៉ាងណាក៏ដោយ ពលរដ្ឋកម្ពុជាជាច្រើន ដែលបានរស់

នៅទីក្រុងភ្នំពេញ នៅតែមានសង្ឃឹមថា ការចាញ់សង្គ្រាមចៀសមិនរួចរបស់សាធារណរដ្ឋខ្មែរអាចនាំមកនូវការចាប់ផ្តើមសម័យកាលថ្មី និងប្រើសើរជាងសម្រាប់ប្រជាជន និងប្រទេសជាតិ។

នៅខណៈដែលកងកម្លាំងខ្មែរក្រហម បានចូលមកដល់ទីក្រុងភ្នំពេញនាព្រឹកព្រលឹម ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនក្នុងក្រុងបានចេញមកតាមដងវិថីនានា ដោយម្នាក់ៗគ្រវីទង់ស្វាគមន៍ដល់អ្នកដែលបានទទួលជ័យជម្នះ។ ទោះជាមានការភ័យខ្លាចក្តី ប្រជាជនមានអារម្មណ៍ធូរស្រាលដោយបានយល់ថា សង្គ្រាមស៊ីវិលបង្ហូរឈាមអស់រយៈពេលប្រាំឆ្នាំមកនេះ ត្រូវបានបញ្ចប់។ ប្រជាជនសង្ឃឹមថា នឹងរួចផុតពីអំពើអាក្រក់ផ្សេងៗ។

ខ្មែរក្រហមបានចូលត្រួតត្រាតាមផ្លូវសំខាន់ៗ ផ្លូវបំបែកនានា និងអគាររដ្ឋាភិបាលនៅក្នុងរាជធានី។ ដោយបង្កើតជាកន្លែងត្រួតពិនិត្យ និងបានកម្ទេចអ្នកប្រឆាំងដែលនៅសេសសល់យ៉ាងខ្លាំង យ៉ាងឆាប់រហ័សនៅជុំវិញទីក្រុង។

[០៩:៥៦:៥៣]

ទាហានសាធារណរដ្ឋខ្មែរភាគច្រើនមានការសប្បាយចិត្ត និងបានទម្លាក់អាវុធចុះចូល ដោយពួកគេក៏មានការធូរស្រាលក្នុងចិត្តផងដែរ ដែលសង្គ្រាមដ៏យូរអង្វែង និងបង្ហូរឈាមនេះត្រូវបានបញ្ចប់។

ដូច ឡូរ៉ង់ ណឺរ៉ី ជាអ្នកកាសែតបរទេសម្នាក់ ដែលមានវត្តមាននៅពេលទីក្រុងភ្នំពេញដួលរលំ បានរៀបរាប់ថា “ទាហានរដ្ឋាភិបាលសាធារណរដ្ឋខ្មែរម្នាក់ ដែលបានឱបខ្មែរក្រហមម្នាក់ និយាយប្រាប់ខ្ញុំថា ពួកគេទាំងពីរមកពីភូមិតែមួយ ហើយយើងសប្បាយចិត្តពេលសង្គ្រាមត្រូវបានបញ្ចប់”។ អ្នកទីក្រុងភ្នំពេញបានឲ្យបារីដល់អ្នកមកដល់ថ្មី។ នៅពេលទាហាន និងកុមារលើកកាំភ្លើងឡើងលើជាសញ្ញានៃជ័យជម្នះ វាហាក់ដូចជាថា ជាចុងក្រោយសន្តិភាពបានវិលត្រឡប់មកវិញហើយសម្រាប់ប្រទេសដែលខ្ទេចខ្ទាំដោយសង្គ្រាមមួយនេះ។

[០៩:៥៧:៥៨]

ផ្ទុយទៅវិញ តែប៉ុន្មានម៉ោងក្រោយប៉ុណ្ណោះ ភាពសប្បាយរីករាយ និងអារម្មណ៍ធូរស្រាលទាំងអម្បាលមានត្រូវបានជំនួសមកវិញនូវភាពដ៏រន្ធត់មួយ អ្នកឈ្នះមិនមានអារម្មណ៍សាទរជាមួយទេ។ ពួកគេបានទទួលបញ្ជាដ៏តឹងរ៉ឹងដែលត្រូវតែអនុវត្តភ្លាម និងគ្មានការលើកលែងឡើយ។

អ្នកទីក្រុងត្រូវបានគេជម្លៀសដោយបង្ខំចេញពីទីក្រុងទៅកាន់តំបន់ជនបទនានា។ អ្នកជម្លៀសត្រូវបានគេប្រាប់ថា មូលហេតុនៃការជម្លៀសគឺដោយសារបន្តិចទៀតនេះនឹងមានការទម្លាក់គ្រាប់បែក

ពីលើអាកាសមកលើទីក្រុងដោយកងទ័ពអាកាសអាមេរិក។

[០៩:៥៨:៤៩]

សាក្សីម្នាក់រស់នៅទីក្រុងភ្នំពេញបានរៀបរាប់ពីរបៀបដែលគេផ្តល់បញ្ជាថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ម៉ោងប្រាំបួនព្រឹក កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធ បានចូលមកដល់ទីក្រុងភ្នំពេញ ដោយមានមីក្រូដើរព្រមានប្រជាជនឱ្យចេញ នៅម៉ោងបីរសៀលក្នុងថ្ងៃតែមួយ។ ពួកគេប្រកាសថា ពួកអាមេរិកាំងនឹងទម្លាក់គ្រាប់បែកពីលើអាកាសមកលើទីក្រុងភ្នំពេញក្នុងពេលឆាប់ៗនេះ។ ពួកគេនិយាយថា អង្គការនឹងលើកទោសឱ្យ លើកលែងតែពួកក្បត់ទាំងប្រាំពីរ។

អ្នកទីក្រុងត្រូវបានគេបញ្ជាឱ្យដើរលើផ្លូវចេញពីទីក្រុង គឺជាផ្លូវដែលមានពួកកងទ័ពខ្មែរក្រហមតាមកៀរ។ ប្រជាជនដែលនៅភាគខាងជើងទីក្រុងត្រូវបានបញ្ជាឱ្យដើរទៅទិសខាងជើង ចំណែកអ្នកនៅខាងត្បូង ត្រូវទិសខាងត្បូង។ល។

[០៩:៥៩:៤០]

ភាពវឹកវរកាន់តែខ្លាំងឡើង ប្រជាជនរាប់ពាន់នាក់ត្រូវបានគេបំបែកពីក្រុមគ្រួសារ។ មានករណីជាច្រើនដែលប្រជាជនបានបាត់សមាជិកជាទីស្រឡាញ់របស់គេ ហើយក៏មិនបានជួបជាថ្មីម្តងទៀតឡើយ។ ក្នុងរយៈពេលតែប៉ុន្មានម៉ោង នៅតាមដងវិថីនានានៃទីក្រុងភ្នំពេញបានក្លាយទៅជាពោរពេញដោយហ្វូងមនុស្ស ដែលត្រូវគេបង្ខំឱ្យចាកចេញទៅកាន់ទីណាមួយ ដែលគ្មាននរណាដឹង ហើយផ្ទុយនឹងឆន្ទៈ។ បុរស ស្ត្រី កុមារ និងចាស់ជរា ជាងពីរលាននាក់កំពុងតែធ្វើបម្លាស់ទី គ្មានការលើកលែងសម្រាប់ការអនុវត្តឧក្រិដ្ឋដ៏ឃោរឃៅ និងគ្មានក្តីមេត្តាឡើយ។ អ្នកដែលតវ៉ាត្រូវបានគេគំរាមកំហែងវាយដំ ឬបាញ់សម្លាប់នៅនឹងកន្លែង សូម្បីតែជនដែលងាយរងគ្រោះបំផុតក៏មិនអត់ឱនឱ្យដែរ។ អ្នកជំងឺត្រូវបានគេបង្ខំឱ្យចេញពីមន្ទីរពេទ្យ ស្ត្រីមានគភ៌ និងស្ត្រីទើបសម្រាលកូនត្រូវបានគេបង្ខំឱ្យចាកចេញទាំងកណ្តាលថ្ងៃត្រង់ជាមួយនឹងកូនពក្នុងដៃ។

[១០:០០:៥៣]

លោក ហ្វ្រង់ស្វ័រ ប៉ុងហ្សូ បានសម្លឹងមើលព្រឹត្តិការណ៍នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពីទីលំនៅដ្ឋានរបស់គាត់ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីស្ថានទូតបារាំង។ គាត់បានរៀបរាប់នូវអ្វីដែលគាត់បានឃើញនៅក្នុងសៀវភៅរបស់គាត់ ដែលមានចំណងជើងថា “កម្ពុជាឆ្នាំសូន្យ”។ អ្នកជំងឺ និងអ្នករបួសរាប់ពាន់នាក់ ត្រូវបានគេបោះបង់ចោលក្នុងទីក្រុង។ អ្នកដែលនៅមានកម្លាំងខ្លាំងខំប្រវេប្រវា ទៅ

តាមគេមើលទៅគួរឲ្យអាណិតយ៉ាងក្រៃលែង ខណៈអ្នកផ្សេងទៀតត្រូវបានមិត្តភក្តិជួយគ្រា និងអ្នកខ្លះទៀតត្រូវក្រុមគ្រួសារដាក់លើគ្រែរុញ ដោយមានសេរ៉ូមឈាមភ្ជាប់ជាមួយ។ ខ្ញុំមិនភ្លេចសោះចំពោះជនពិការម្នាក់ដែលគាត់គ្មានដៃគ្មានជើង ខំរមៀលខ្លួនលើដីដូចដង្កូវដាច់ខ្លួន ឬឪពុកម្នាក់ស្ពាយកូនស្រីអាយុ១០ឆ្នាំនឹងក្រមាដោយចងព្យួរនឹងកទម្លាក់មកក្រោមដូចខ្សែជំពាម ឬបុរសម្នាក់ដែលជើងរបស់គាត់បានដាច់ធ្លាក់តាកយ៉ាកគ្មានអ្វីទប់ក្រៅពីស្បែកតែប៉ុណ្ណោះ។

[១០:០២:១៣]

អតីតកងទ័ពម្នាក់នៅភូមិភាគឧត្តរមកពីខេត្តកំពង់ចាម រៀបរាប់អំពីទិដ្ឋភាពហ្វូងមនុស្សទាំងហ្វូងៗចាកចេញទីកន្លែងដែលធ្លាប់នៅពីទីក្រុងភ្នំពេញដូចតទៅ៖ ស្ថានភាពប្រជាជនពេលនោះគួរឲ្យអាណិតណាស់ ខ្លះយំ ម្តាយយំ កូនយំ មានការឈឺចាប់ខ្លាំងណាស់ អ្នកខ្លះស្លាប់នៅក្នុងមន្ទីរពេទ្យ អ្នកជំងឺដាក់នៅក្នុងរទេះរុញ អ្នកជំងឺខ្លះដែលគ្មានបងប្អូននៅដេកទីនោះ រួចក៏ស្លាប់នៅក្នុងមន្ទីរពេទ្យ។ ដូចដែលខ្មែរក្រហមបានសម្អាតទីក្រុងជាប្រព័ន្ធ ជាចុងក្រោយខ្មែរក្រហមបានយកពលរដ្ឋកម្ពុជាជាងមួយពាន់នាក់ចេញពីស្ថានទូតបារាំង ដែលបានចូលទៅជ្រកកោននៅនោះ។ ក្នុងដំណើរការនេះ ជនជាតិខ្មែរដែលបានរៀបការជាមួយនឹងជនបរទេស ប៉ុន្តែមិនមានលិខិតឆ្លងដែនបរទេស ត្រូវបានបំបែកដោយបង្ខំពីមនុស្សជាទីស្រលាញ់របស់ខ្លួន។

[១០:០៣:១៥]

សារទូរលេខមួយដែលចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ពីស្ថានទូតបារាំងបាននិយាយថា ការឈឺចាប់មិនអាចស៊ូទ្រាំបានឡើយសម្រាប់យើងទាំងអស់គ្នា។ អ្នកខ្លះត្រូវចែកផ្លូវគ្នាបន្ទាប់ពីបានរស់នៅជាមួយគ្នាពី១៥ឆ្នាំទៅ២០ឆ្នាំ។ កាលពីម្សិលមិញក្មេងប្រុសបានកើតនៅក្នុងស្ថានទូត ម្តាយត្រូវចាកចេញនៅថ្ងៃនេះ។ ក្មេងប្រុសនេះបានក្លាយទៅជាកូនរបស់ខ្ញុំនៅថ្ងៃនេះ ខ្ញុំយកគេជាកូនចញ្ចឹម។ ក្រោយពីបានបណ្តេញចេញពីទីក្រុងជនរងគ្រោះ ត្រូវបានបង្ខំឲ្យធ្វើដំណើរក្នុងចម្ងាយផ្លូវដ៏ឆ្ងាយដោយថ្មើរជើងនៅក្នុងរដូវក្តៅ។ គេគ្មានផែនការដើម្បីជួយឡើយ ទោះបីជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានដឹងហើយថា វាជាដំណើរផ្សងព្រេងដ៏វែងឆ្ងាយ ដ៏លំបាក និងសម្រាប់មនុស្សភាគច្រើន ទោះបីដំណើរនោះទៅស្លាប់ក៏ដោយ។ គេគ្មានផែនការដើម្បីផ្តល់ការដឹកជញ្ជូន ម្ហូបអាហារ ទឹក ជំនួយវេជ្ជសាស្ត្រ ឬទីជម្រកទៅតាមផ្លូវនោះឡើយ។

[១០:០៤:២៥]

ការពិតខ្មែរក្រហមបានធ្វើឱ្យមានមហន្តរាយកាន់តែអាក្រក់ឡើង តាមរយៈការបញ្ហាមិនឱ្យយករបស់របរ ឬរបស់ផ្គត់ផ្គង់ផ្សេងៗទៅតាមខ្លួនឡើយ។ ក្បួនមនុស្សចេះតែរំកិលទៅមុខក្នុងស្ថានភាពយឺតៗដ៏សែនឈឺចាប់។ ដូចសាក្សីម្នាក់បានរៀបរាប់ថា នៅពេលនោះផ្លូវទៅព្រៃវែងមនុស្សអាចដើរទៅមុខបានតែប្រាំទៅដប់ម៉ែត្រប៉ុណ្ណោះក្នុងមួយម៉ោង។ នៅពេលឈប់សម្រាកពេលយប់អ្នកជម្លៀសត្រូវបានដេកនៅតាមផ្លូវ តាមផ្ទះគ្មានមនុស្ស តាមវត្ត ឬនៅក្រោមដើមឈើ។

[១០:០៥:០៥]

ពេលក្បួនមនុស្សបន្តដំណើរអ្នកជម្លៀសត្រូវបានគេឃ្លាំមើលជាប់ជាប្រចាំ ដោយកងទ័ពខ្មែរក្រហម។ កងទ័ពទាំងនេះគំរាមសម្លាប់ជនណាមិនគោរពតាមពួកគេ ឬក៏ព្យាយាមវិលត្រឡប់ទៅភ្នំពេញវិញ។ ជនរងគ្រោះភាគច្រើនត្រូវគេបន្ទាបបន្ថោកក្នុងខណៈដែលកងទ័ពខ្មែរក្រហមបានយករបស់របរពួកគេ ហើយពួកគេយកចាប់តាមខ្លួន។ ជនរងគ្រោះជាច្រើនត្រូវបានគេបាញ់សម្លាប់នៅតាមផ្លូវ ដោយសារតែសកម្មភាពកំប៉ិកកំប៉ុកនៃការមិនគោរពតាម ដូចជាការមិនព្រមបោះបង់ចោលកង់មួយជាដើម។

តាមពិតនៅតាមផ្លូវនានារាយប៉ាយដោយសាកសពដូចសំរាមដែលស្លាប់ដោយជំងឺ ការហេវហត់ ឬការសម្លាប់។ សាក្សីម្នាក់ដែលកាលនោះ ជានិស្សិតម្នាក់រៀបរាប់អំពីទិដ្ឋភាពដែលគាត់បានឃើញនៅតាមផ្លូវចេញពីទីក្រុងភ្នំពេញថា "នៅតាមផ្លូវ ខ្ញុំបានឃើញសកសពមនុស្សស្លាប់ សាកសពទាំងនោះក្រៀមស្វិត ហើយមនុស្សម្នាបានដើរពីលើសាកសពទាំងនោះ មានសាកសពខ្លះត្រូវឆ្កែស៊ី ហើយសាកសពខ្លះទៀតត្រូវបានដើរជាន់ឡើងសំប៉ែត ការស្លាប់មាននៅគ្រប់ទិសទី"។ សាក្សីម្នាក់ដែលជានិរសារក្នុងកងពល២២០នៃភូមិភាគនិរតី រៀបរាប់ពីអ្វីដែលគាត់បានឃើញនៅតាមផ្លូវមិនឆ្ងាយប៉ុន្មានពីកន្លែងដែលគាត់រស់នៅសព្វថ្ងៃនេះថា "ខ្ញុំបានឃើញសាកសពច្រើនណាស់នៅតាមផ្លូវ ជាពិសេសនៅក្នុងម្តុំរង្វង់មូលចោមចៅ ជិតពោធិ៍ចិនតុង។ ខ្ញុំបានឃើញផ្ទាល់កងទ័ពខ្មែរក្រហម បានបើកឡើងរ៉ាសកិនពីលើមនុស្ស។" នេះគឺជាការចាប់ផ្តើមការវាយប្រហាររបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើមនុស្សជាតិនៃជាតិកម្ពុជាទាំងមូល។ តាមសម្តីរបស់អ្នកជម្លៀសម្នាក់ដែលធ្វើដំណើរតាមវិថីព្រះមុន្នីវង្ស ចេញពីទីក្រុងភ្នំពេញបាននិយាយថា "ខ្ញុំមានអារម្មណ៍ថាពិភពលោកបានឈានដល់ទីបញ្ចប់ហើយ"។

នៅថ្ងៃទី១៧ ខែមេសា ជាថ្ងៃបន្តបន្ទាប់មកទៀត ខ្មែរក្រហមបានជម្លៀសមនុស្សដោយបង្ខំចេញពីទីប្រជុំជនដទៃទៀតទាំងអស់នៅទូទៅប្រទេសកម្ពុជា រួមទាំងកំពង់ចាម តាកែវ ស្ទោង ប៉ៃលិន បាត់ដំបង សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ ស្វាយរៀង និងព្រៃវែង។ កម្រិតនៃការធ្វើផែនការ

ការរៀបចំ និងភាពគ្មានមេត្តាគឺមានលក្ខណៈដូចគ្នាដែលគេបានឃើញនៅគ្រប់ទីប្រជុំជនទាំងអស់។

[១០:០៧:៥០]

អតីតរបស់កម្មាភិបាលម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជាបានរៀបរាប់អំពីទិដ្ឋភាពក្នុងខេត្តកំពត ដូចខាងក្រោមនេះ៖

ការជម្លៀសមនុស្សបានចាប់ផ្តើមនៅពេលរសៀល ពេល យើងទៅដល់ទីក្រុង ទីក្រុងបានក្លាយទៅជាស្ងាត់ជ្រងំ។ ពីម៉ោងក្រោមមក គ្មានមនុស្សរស់នៅក្នុងទីក្រុងទៀតទេ គ្មានអ្នកប្រឆាំងទេ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលបានឃើញការជម្លៀសដោយបង្ខំ នៅក្នុងក្រុងព្រះសីហនុ បានផ្តល់សក្ខីកម្មថា នៅក្នុងទីក្រុងនេះ ក៏ដូចភ្នំពេញដែរ ប្រជាជនត្រូវបានគេប្រាប់ពីមូលដ្ឋាននៃការជម្លៀសនេះថា គឺដោយសារការខ្លាចទម្លាក់គ្រប់បែករបស់អាមេរិកនៅក្នុងពេលឆាប់ៗនេះ។ ដូចភ្នំពេញដែរ ប្រជាជនត្រូវបានគេប្រាប់ថា ពួកគេអាចវិលត្រឡប់មកផ្ទះខ្លួនវិញបានក្នុងរយៈពេលពីរ ឬបីថ្ងៃ។

[១០:០៨:៤២]

ការឈឺចាប់ និងការស្លាប់មនុស្សរាប់ពាន់នាក់ដោយសារការអត់បាយ ការបាក់កម្លាំង ការទទួលរងឥទ្ធិពលផ្សេងៗ និងជំងឺនៅក្នុងអំឡុងពេលនៃការជម្លៀសដោយការបង្ខំលើកដំបូងនេះ មិនបានធ្វើឲ្យមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាភ្ញាក់ផ្អើលទេ។ ដូច ខៀវ សំផន បាននិយាយប្រាប់សហចៅក្រមស៊ើបអង្កេតក្នុងពេលសួរចម្លើយមួយថា "ខ្ញុំបានដឹងច្បាស់ថា ចំនួនប្រជាជនអាចនឹងធ្លាក់ចុះនៅតាមផ្លូវ"។ លោក ប៉ែន យៀវនិន ជាអ្នកជំនាញនាំមុខម្នាក់ដែលបានសិក្សាស្រាវជ្រាវក្នុងឧក្រិដ្ឋកម្មខ្មែរក្រហមជាច្រើនទសវត្សរ៍បានធ្វើការប៉ាន់ប្រមាណថា ជនស៊ីវិលជាងមួយម៉ឺននាក់ បានស្លាប់បណ្តាលមកពីលក្ខណៈផ្សេងៗនៃការជម្លៀសដោយបង្ខំនេះ។

អៀង សារី បានទទួលស្គាល់ក្នុងបទសម្ភាសន៍មួយ ជាមួយនឹងអ្នកសារព័ត៌មាន ជនជាតិអាល្លឺម៉ង់ម្នាក់ដែលធ្វើការនៅកាសែត ហ្គាស់ស្ពីហ្គែល ថាបានស្លាប់មនុស្សរាប់ពាន់នាក់ៗ ដោយសារការជម្លៀសនានា។ គាត់បាននិយាយថា "នៅខែដំបូងៗនៃការរំដោះ គឺមានការតឹងតែងខ្លាំងណាស់ មានមនុស្សពីពីរពាន់ ទៅបីពាន់នាក់បានស្លាប់នៅក្នុងជម្លៀសពីភ្នំពេញ ហើយរាប់ពាន់នាក់ទៀតបានសម្លាប់នៅតាមវាលស្រែ"។

[១០:១០:០៧]

ការស្រាវជ្រាវរកខ្មាំងរបស់បដិវត្តន៍នេះត្រូវបានគេធ្វើឡើងភ្លាមៗ។ សាក្សីម្នាក់ដែលត្រូវបាន

គេបង្ខំឲ្យចាកចេញពីភ្នំពេញនិយាយថា ចំពោះគ្រួសារណាមិនចង់បន្តទៅមុខទៀត ខ្មែរក្រហមនឹងកត់ឈ្មោះ ខ្មែរក្រហមបានសួរប្រជាជនអំពីព័ត៌មានផ្ទាល់ខ្លួន បើពួកខ្មែរក្រហមរកឃើញអ្វីមួយ ពួកខ្មែរក្រហមនឹងយកប្រជាជននោះចេញទៅ។ ឧទាហរណ៍ ដូចករណីឪពុកខ្ញុំដែលជាខ្មែរក្រហមបានរកឃើញថា គាត់ជាទាហាន លន់ នល់ ហើយក៏ចាប់គាត់បាត់ទៅ។

ជាការពិត កងសម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានតាមស្វែងរកនិងសម្លាប់ជាប្រព័ន្ធចំពោះមន្ត្រីនិងទាហានសាធារណរដ្ឋខ្មែរនៅទូទាំងប្រទេស។ ជនរងគ្រោះទាំងនេះ គឺជាចំណុចដៅដំបូងនៅត្រង់ប៉ុស្តិ៍ត្រួតពិនិត្យនានានៅតាមផ្លូវចេញពីភ្នំពេញ មានអ្នកខ្លះត្រូវបានគេចាប់យកទៅបាត់ ហើយមិនដែលបានឃើញត្រឡប់មកវិញទេ។ ចំណែកខ្លះទៀត ត្រូវបានគេសម្លាប់ចោលនៅនឹងកន្លែងតែម្តង សូម្បីតែទាហានចុះចូលក៏ពួកខ្មែរក្រហមមិនមេត្តាដែរ។

[១០:១១:២១]

សមាជិកម្នាក់កងពលធំលេខ១ ភូមិភាគឧត្តរ បានរៀបរាប់អំពីទិដ្ឋភាពដែលគាត់បានឃើញផ្ទាល់នៅភ្នំពេញ "ខ្ញុំបានឃើញពួកខ្មែរក្រហមសម្លាប់ទាហានដែលចុះចូលនៅស្ពានជ្រោយចង្វា។ ក្នុងចំណោមពួកគេទាំងនោះមានប្រហែលប្អូនដប់នាក់ខ្លះបាត់ដៃ ខ្លះបាត់ជើង ហើយពួកខ្មែរក្រហមបានទាញទាហានទាំងនោះយកទៅទម្លាក់ចោលក្នុងទន្លេ"។

សហការីអន្តរជាតិនឹងរៀបរាប់អំពីសមាជិកជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរពីររូបដែលស្នាក់នៅភ្នំពេញគឺនាយករដ្ឋមន្ត្រី ឡុង បូរ៉េត និងព្រះអង្គម្ចាស់ សិរីមតៈ ត្រូវបានកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាសម្លាប់។ ការស្រាវជ្រាវរុករកនិងការសម្លាប់ទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរចេះតែបន្តរហូតពេញផ្ទៃប្រទេសជាច្រើនថ្ងៃ ច្រើនសប្តាហ៍ជាបន្តមកទៀត។ ដំបូងការចាប់ខ្លួនត្រូវបានគេអនុវត្តតាមរយៈការបំភ័ន្តភ្នែក ដោយការប្រកាសឲ្យសមាជិករបស់របបចាស់រាយការណ៍ប្រាប់អាជ្ញាធរថ្មីរបស់ពួកខ្លួន ដើម្បីទទួលបានការចាត់តាំងការងារនៅក្រោមរដ្ឋបាលថ្មី។ អ្នកទាំងអស់ដែលបានរាយការណ៍ត្រូវបានគេសម្លាប់ចោល។ អតីតកងទ័ពនៅភូមិភាគឧត្តរម្នាក់ដែលធ្លាប់បានចូលរួមនៅក្នុងការជម្លៀសមនុស្សដោយបង្ខំពីទីក្រុងភ្នំពេញដែលនោះបានផ្តល់សក្ខីកម្មថា "ក្រោយពីបានប្រាំពីរ ឬប្រាំបីថ្ងៃពួកគេបានបង្កើតប្រព័ន្ធឧគ្ឃោសនសព្ទ និងប្រកាសឲ្យទាហាន លន់ នល់ ឧបមាថា អ្នកណាធ្លាប់ធ្វើការងារអ្វីមួយមានឋានៈអ្វីក៏ដោយឲ្យត្រឡប់ទៅកន្លែងខ្លួនធ្លាប់បម្រើការងារនោះ។ អ៊ីចឹង ពួកគេក៏បានស្លាប់ទៅ។

[១០:១៣:០៣]

មានអ្នកខ្លះខំព្យាយាមដើម្បីរស់ និងលាក់រឿងរ៉ាវផ្សេងៗកុំឲ្យគេដឹង ប៉ុន្តែពួកគេក៏ត្រូវចាប់ខ្លួនដែរ ព្រោះពួកវាស្រាវជ្រាវរុករកឃើញនិងសម្លាប់ចោលតាមជីវប្រវត្តិ។ ក្នុងពេលបំភ័ន្តភ្នែកនោះ ដូចជាថាទាហានត្រូវត្រឡប់ទៅកន្លែងដើមវិញ ពេលនោះមានឡានកាំមីញ៉ុងបួនដប់គ្រឿងក៏បានប្រមូលម៉ឺុចាំពួកទាហាននោះក៏ត្រូវបានដឹកចេញទៅបាត់ យកទៅសម្លាប់ចោលទិសខាងលិចព្រែកព្នៅ។

នៅទួលពោធិ៍ជ្រៃដែលជាទីតាំងឧក្រិដ្ឋមួយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមានទាហាននិងមន្ត្រីរាជការសាធារណរដ្ឋខ្មែររាប់ពាន់នាក់ត្រូវបានគេចាប់ខ្លួនដឹកតាមឡានកាំមីញ៉ុង បន្ទាប់មកត្រូវបានគេសម្លាប់ចោលជាប្រព័ន្ធ។ សាកសពរបស់ពួកគាត់ត្រូវបានគេរុញដោយអេស្កាវ៉ាទ័របញ្ចូលទៅក្នុងរណ្តៅសពរួមគពីលើគ្នាដូចគំនរសំរាម។

[១០:១៤:០៥]

អ្នកជម្លៀសដែលបានរស់នៅក្នុងស្រុក១២ ត្រូវបានគេសួរពីប្រវត្តិរូប បន្ទាប់មកអ្នកដែលធ្លាប់ធ្វើជាទាហាន មន្ត្រីរាជការនៃរបបលន់ នល់ និងពួកមូលធនត្រូវបានគេបំបែក និងយកទៅបាត់ដើម្បីសម្លាប់ចោល។

ក្នុងឱកាសបីដាច់ដោយឡែកពីគ្នា នៅក្រោយថ្ងៃទី១៧ មេសា ១៩៧៥ មានអ្នកជម្លៀសក្រុមធំដែលមានប្រមាណជា៥០០នាក់ ត្រូវបានកងឈ្លបខ្មែរក្រហមដឹកយកទៅវត្តត្បែងខ្ពស់ ស្ថិតនៅក្នុងភូមិត្បែងខ្ពស់ ដែលពួកគាត់ត្រូវបានគេដាក់ឲ្យនៅទីនោះមិនលើសពីពីរថ្ងៃទេ រួចបានក៏បានបញ្ជូនចេញដើម្បីសម្លាប់ចោល។ ការសម្លាប់មនុស្សរង្គាលជាច្រើនលើកច្រើនសាទៅលើទាហានសាធារណរដ្ឋខ្មែរ និងប្រជាជនជាអ្នកជម្លៀសបានកើតឡើងនៅទីកន្លែងដទៃទៀតនៅក្នុងស្រុកកំពង់ត្រឡាច។ ទីតាំងឧក្រិដ្ឋកម្មទាំងអស់នេះ គឺជាផ្នែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរ។

លោកប្រធាន លោក លោកស្រីចៅក្រមនឹងបានស្តាប់ភស្តុតាងពាក់ព័ន្ធនឹងការប្រជុំសំខាន់ៗដែលក្នុងកិច្ចប្រជុំទាំងនោះ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានពិភាក្សាគ្នាអំពីការជម្លៀសពីប្រជុំជននិងបានផ្តល់បញ្ជា ដែលបញ្ជាទាំងនោះត្រូវបានគេធ្វើទំនាក់ទំនងទៅកាន់កងទ័ព ដែលជាប់ព័ន្ធនៅក្នុងការវាយប្រហារទីក្រុងភ្នំពេញ និងទីក្រុងដទៃទៀត។

[១០:១៥:៤១]

សេចក្តីសម្រេចក្នុងការជម្លៀសមនុស្សពីទីក្រុងនានា ត្រូវបានជំរុញទឹកចិត្តតាមរយៈគោលដៅនានាក្នុងការបំបែកមូលដ្ឋានសំខាន់ទាំងឡាយរបស់អ្នកតស៊ូ កុំឲ្យមានការប្រឆាំងនឹងការគ្រប់គ្រងរបស់

បក្សកុម្មុយនីស្តកម្ពុជាតាមបណ្ដាលទីប្រជុំ ព្រមទាំងការកំណត់អត្តសញ្ញាណ និងការកម្ទេចជនដែលគេយល់ថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។

ពលកម្មដោយបង្ខំ៖

គួរឲ្យរន្ធត់ណាស់នូវអ្វីដែលកើតឡើង ព្រោះការជម្លៀសដោយបង្ខំ គ្រាន់តែជាការចាប់ផ្ដើមនៃអំពើគួរឲ្យតក់ស្លុត ការតក់ស្លុតរន្ធត់ជាងនេះមិនទាន់មកដល់ទេ។ បន្ទាប់ពីមានការជម្លៀសមនុស្សទាំងប៉ុន្មានដែលនៅក្នុងករណីជាច្រើន ហ្វូងមនុស្សទាំងនោះប្រើពេលលើសពីមួយខែ។ បក្សកុម្មុយនីស្តកម្ពុជាបានបង្ខាំងប្រជាជនទាំងមូលនៅតាមជនបទ សហករណ៍ និងទីតាំងការដ្ឋានការងារដោយបង្ខំដែលពេលនេះប្រជាជនកម្ពុជាត្រូវបានគេកាត់បន្ថយឋានៈសង្គម មកត្រឹមឋានៈជាទាសករ។ ដើម្បីបង្វែរប្រទេសឲ្យទៅជាគុកដ៏ធំមួយ បក្សកុម្មុយនីស្តកម្ពុជាបានកំណត់កម្ទេចចោលគ្រប់ទិដ្ឋភាពទាំងអស់ នៃសង្គមខ្មែរដែលមានពីមុន។ ជីវិតគ្រួសារ និងគ្រប់ទម្រង់ទាំងអស់នៃអន្តរសកម្ម សង្គមនានាត្រូវបានលុបបំបាត់ ទ្រព្យសម្បត្តិឯកជនទាំងអស់ត្រូវបានគេរឹបអូស អ្វីៗគ្រប់បែបយ៉ាងដែលធ្លាប់ជាកម្មសិទ្ធិរបស់ប្រជាជនត្រូវបានគេយកអស់គ្មានសល់ ជាធម្មតាបានកើតឡើងក្នុងរយៈពេលដែលតែមួយយប់។ កម្មសិទ្ធិឯកជន និងលុយកាក់ត្រូវបានលុបបំបាត់ សាលារៀន មហាវិទ្យាល័យ ពាណិជ្ជកម្ម និងផ្សារត្រូវបានបិទ សៀវភៅ និងទស្សនាវដ្ដីត្រូវបានហាមឃាត់។ វិទ្យុ ទូរទស្សន៍ រោងល្ខោន រោងភាពយន្តត្រូវបានបិទទ្វារ។ កេរដំណែលវប្បធម៌ខ្មែរ ដែលបានទទួលរងនូវអំណារ និងភាពស្ងប់ស្ងែងតាមរយៈដួរតន្ត្រី កំណាព្យ របាំ និងអក្សរសាស្ត្រ ត្រូវបានគេដាក់ឲ្យនៅក្រៅច្បាប់។ ព្រះសង្ឃត្រូវបានចាប់ផ្សឹក ហើយការគោរពសាសនាត្រូវបានបញ្ឈប់ គ្រប់សាសនាទាំងអស់ត្រូវបានហាមឃាត់។

[១០:១៨:០១]

តែក្នុងមួយពព្រិចភ្នែកបក្សកុម្មុយនីស្តកម្ពុជាបានលុបបំបាត់អ្វីដែលជារចនាសម្ព័ន្ធសង្គម ជាមូលដ្ឋានពិតប្រាកនៃជីវិតរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។ បានបំផ្លាញចោលនូវសង្គមមួយដែលជាតំណភ្ជាប់ និងបង្កើតយើងជាមនុស្ស។

ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅតាមទីតាំងការងារដោយបង្ខំចំនួនប្រាំកន្លែង គឺសហករណ៍ត្រាំកក់ ក្នុងខេត្តតាកែវ, ការដ្ឋានស្រែអំបិល ក្នុងខេត្តកំពត, ទំនប់១មករា ក្នុងខេត្តកំពង់ធំ, ទំនប់អាងត្រពាំងថ្ម ក្នុងខេត្តបន្ទាយមានជ័យ និងការដ្ឋានកសាងព្រលានយន្តកំពង់ឆ្នាំង ក្នុងខេត្តកំពង់ឆ្នាំង។

ទីតាំងទាំងនេះមានទ្រង់ទ្រាយធំណាស់ ឧទាហរណ៍ នៅការដ្ឋានកសាងព្រលានយន្តកំពង់ឆ្នាំង ត្រឹមឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ចំនួនប៉ាន់ស្មានកម្មករនៅទីនេះ គឺចន្លោះពី ២០.០០០នាក់ ទៅ៣៥.០០០ នាក់។ ការដ្ឋានស្រែអំបិលគ្របដណ្តប់លើផ្ទៃដីជាង២.៥០០ហិចតា និងមានកម្មករពីចន្លោះ៥.០០០នាក់ ទៅ៨.០០០នាក់។

មនុស្សជាង២០.០០០នាក់ត្រូវបានគេធ្វើឲ្យទៅជាទាសករនៅទំនប់១មករា គម្រោងការលាត សន្ធឹងជាង៦០គីឡូម៉ែត្រ ដូចដែលបានឃើញនៅក្នុងខែភាពយន្តខ្លីមួយនេះ របស់ ឫទ្ធី ប៉ាន់។ ទីតាំងទាំង នេះស្ថិតក្រោមការដឹកនាំ និងត្រួតត្រារបស់ជនជាប់ចោទ ដូចសហការីរបស់ខ្ញុំនឹងបង្ហាញជូនជនចាប់ ចោទ បានដាក់ចេញនូវរចនាសម្ព័ន្ធ សិទ្ធិអំណាច និងការធ្វើការរបាយការណ៍តាមខ្សែបណ្តោយតឹងរ៉ឹង ដើម្បីឲ្យប្រាកដថា បញ្ជានានារបស់ខ្លួនត្រូវបានអនុវត្តនូវទូទាំងប្រទេស។

[១០:២០:០៦]

ភស្តុតាងបញ្ជាក់ថា ជនជាប់ចោទបានដឹងថា ជាពិសេស និងបានរក្សាការត្រួតត្រាទៅលើទីតាំង ទាំងប្រាំនេះ ដែលបានដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ឧទាហរណ៍ គម្រោងកសាង ទំនប់ធំទាំងពីរ គឺជាផ្នែកមួយនៃការដាក់ទិសដៅដែលបានបង្កើតឡើងដោយមជ្ឈិមបក្ស ដើម្បីធ្វើជា ប្រព័ន្ធស្រោចស្រព។ នៅតំបន់ត្រពាំងថ្មទិសដៅការងារត្រូវបានបង្កើតឡើងដោយមេដឹកនាំភូមិភាគដែល ជារាយការណ៍មកមជ្ឈិមបក្ស។ លោក ខៀវ សំផន បានចុះទៅពិនិត្យការដ្ឋាននោះជាញឹកញាប់។ នៅ ក្នុងដំណើរចុះទៅពិនិត្យមួយ ដោយបានឃើញអំពីលក្ខខណ្ឌដ៏ខ្លោចផ្សានៅការដ្ឋាននេះ គាត់បានទទូច ឲ្យកម្មករខំប្រឹងបន្តធ្វើការងារដោយឲ្យបានខ្លាំងក្លាថែមទៀត។ ទំនប់១មករា ក៏ធ្លាប់មានមេដឹកនាំជាន់ ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាចុះទៅពិនិត្យដែរ រួមមាន ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន។ ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានបញ្ជាដោយគណៈមជ្ឈិមបក្សកុម្មុយ នីស្តកម្ពុជា។

[១០:២១:២១]

ជាថ្មីម្តងទៀត សមាជិកថ្នាក់ដឹកនាំជាច្រើននាក់ដែលធ្លាប់ចុះទៅពិនិត្យមើល ការរីកចម្រើនការ ងារនៅទីនោះ រួមមាន នួន ជា, អៀង សារី, និង ខៀវ សំផន។ នួន ជា បានធ្វើការប្រជុំមួយនៅស្រែ អំបិលក្នុងឆ្នាំ១៩៧៧ ខណៈដែលបានបញ្ជូនពួកកម្មករភូមិភាគបូព៌ា ដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់ជនជាប់ចោទ ឲ្យទៅទីនោះដើម្បីធ្វើការអប់រំរៀនសូត្រ។ លក្ខខណ្ឌជីវិតនៅក្នុងបណ្តាទីតាំង

ការងារដោយបង្ខំនេះ គឺតំណាងឲ្យទាសភាពនៃជនស៊ីវិលនៅទូទាំងប្រទេស។ គ្រប់ទិដ្ឋភាពនៃជីវិតត្រូវស្ថិតនៅក្រោមការត្រួតត្រាទាំងស្រុងដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ហើយការមិនគោរពតាមការណាមួយ ទោះតូចតាចក៏ដោយក៏ត្រូវទទួលទណ្ឌកម្មធ្ងន់ធ្ងរដែរ។ តាមសម្តីរបស់អតីតកម្មករម្នាក់ថា កម្ពុជាបានក្លាយទៅជាគុកឥតជញ្ជាំង ដែលអ្នកទោសខ្លះត្រូវបានគេឃ្លាំមើលជាប្រចាំ។ បុរស ស្ត្រី កុមារ និងចាស់ជរា ម្នាក់ៗខំបំពេញការងារដោយកម្លាំងបាយយ៉ាងសែនទារុណនៅក្នុងសភាពស្ងប់ស្ងៀម។ អ្នកយាមឃ្លាំមើលគ្រប់ដង្ហើមចេញចូល លក្ខខណ្ឌការងារគួរឲ្យរន្ធត់ ឧទាហរណ៍ នៅការដ្ឋានស្រែអំបិល ស្ត្រីត្រូវបានគេបង្ខំឲ្យធ្វើការងាររហូតទាល់តែទឹកអំបិលស៊ីជើង ចំណែកអ្នកខ្លះទៀត ត្រូវគេយកទៅទឹមបង្ខំឲ្យអូសរទេះអំបិលទៅមករហូតដល់ដួលសន្លប់ដោយសារការអស់កម្លាំង។

[១០:២៣:០៣]

ក្នុងករណីជាច្រើន ការងារនេះត្រូវគេធ្វើឡើងដោយដៃទទេ ឬប្រើឧបករណ៍ងាយៗ ដោយសារបក្សកុម្មុយនីស្តកម្ពុជាបិទប្រទេសរបស់ខ្លួន និងបដិសេធមិនទទួលជំនួយពីបរទេស និងមិនធ្វើទំនើបកម្ម។

ដោយ ខៀវ សំផន បាននិយាយនៅក្នុងសុន្ទរកថារបស់ខ្លួនក្នុងឆ្នាំ១៩៧៧ ពេលធ្វើពិធីអបអរសាទរជ័យជម្នះ បក្សកុម្មុយនីស្តកម្ពុជាលើកទីពីរថា ប្រទេសយើងគ្មានម៉ាស៊ីនអ្វីទាំងអស់ យើងធ្វើអ្វីៗគ្រប់យ៉ាងដោយផ្អែកលើកម្លាំងប្រជាជនយើង។ កម្មករម្នាក់ត្រូវបានគេរំពឹងថា ត្រូវធ្វើការតាមចំនួនកំណត់ ដូចជានៅតំបន់ត្រពាំងថ្ម មានន័យថា កម្មករត្រូវលើកដីឲ្យបានបីម៉ែត្រគីបក្នុងមួយថ្ងៃ។ នៅស្រែអំបិល ពួកស្ត្រីត្រូវលីបាវអំបិលទម្ងន់៥០គីឡូក្រាមមួយថ្ងៃៗពេញ។ ដោយហេតុថា គណៈអចិន្ត្រៃយ៍បានបង្កើតកូតាផលិតផលអំបិលជាប់ជាប្រចាំ គ្មានការលើកលែងឡើយ។ ទោះបីអ្នកនោះធ្លាក់ខ្លួនឈឺក៏ដោយ ហេវហត់គ្មានកម្លាំងកំហែង ស្ត្រីមានគភ៌ ឬអ្នកមានជំងឺកង្វះអាហារធ្ងន់ធ្ងរក៏ដោយ ក៏ត្រូវតែបំពេញឲ្យគ្រប់តាមចំនួនកំណត់។ កម្មករដែលធ្វើមិនគ្រប់ ត្រូវគេចោទថា ខ្ជិល ឬក្បត់ នឹងត្រូវបានគេដាក់ទណ្ឌកម្ម។ ប្រជាជនត្រូវបានគេរៀបចំទៅតាមវិធីសាស្ត្រជាអង្គភាពផ្សេងៗ ដែលឆ្លុះបញ្ចាំងឲ្យឃើញទៅតាមឋានានុក្រមយោធា ប្រជាជន១០០នាក់ រស់នៅ បរិភោគ និងដេកជាមួយគ្នា ដោយស្ថិតនៅក្រោមការតាមឃ្លាំមើលដោយប្រុងប្រយ័ត្នជានិច្ច ពីសំណាក់ពួកអ្នកយាមរបស់បក្សកុម្មុយនីស្តកម្ពុជា។ ទីកន្លែងស្នាក់នៅរបស់ពួកគេ ជាធម្មតាតែងតែមានរោងរួមគ្នាធំមួយ ដែលសូម្បីតែរបស់អ្វីដែលសម្រាប់សេចក្តីត្រូវការចាំបាច់ជាងគេបំផុតជាមូលដ្ឋានក៏មិនមានដែរ។

[១០:២៥:០៤]

នៅឯទំនប់ត្រពាំងថ្ម នៅកន្លែងណាក៏ដោយ ក៏មានមនុស្សពីបីរយនាក់ ទៅប្រាំមួយរយនាក់ដេកជាពីរជួរនៅក្នុងរោងធំៗ ដាក់ជើងទល់គ្នា។ ស្រដៀងគ្នានេះដែរ ពួកពលករនៅឯទំនប់១មករា បានដេកនៅក្នុងអគារវែងៗធ្វើពីឈើ តែមិនមានមុង ភួយ ឬកន្ទេលទេ ភាគច្រើនត្រូវបានគេបង្ខំឲ្យដេកផ្ទាល់នឹងដីតែម្ដង។

របបអាហារមិនគ្រប់គ្រាន់ ជាពិសេសដោយសារតែស្ថានភាពការងារមានលក្ខណៈលំបាកខ្លាំង មានអ្នករស់នៅម្នាក់បាននិយាយថា ពោះខ្ញុំហើម ភ្នៅខ្ញុំស្គមសល់តែឆ្អឹង កំភួនជើងខ្ញុំហើម ឆ្អឹងជំនីខ្ញុំគេរាប់បាន ខ្ញុំបាក់កម្លាំង ប៉ុន្តែគេនៅតែឲ្យខ្ញុំធ្វើការដូចធម្មតា។

សាក្សីម្នាក់ទៀត ដែលបានផ្ដល់សក្ខីកម្មអំពីស្ថានភាពនៅទំនប់១មករា បានធ្វើការរៀបរាប់អំពីរបបអាហារថា មិនស្មើនឹងបបរជ្រូកនៅពេលនេះផង។ នៅពេលដែលមានមនុស្សជាច្រើនជិតនឹងស្លាប់ដោយសារការអត់អាហារនោះ គេហាមឃាត់មិនឲ្យមានការដើរស្វែងរកអាហារទេ។ ដូចដែលខ្ញុំនឹងរៀបរាប់ជូនតាមក្រោយ អ្នកទាំងឡាយដែលហ៊ានដើរស្វែងរកអាហារ គឺសុទ្ធតែធ្វើដោយប្រថុយគ្រោះថ្នាក់ ដោយត្រូវគេចាប់ចង និងឲ្យទទួលរងនូវការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ។

[១០:២៦:៣៨]

ស្ថានភាពអនាម័យ គឺមានភាពគួរឲ្យខ្ពើមរអើមយ៉ាងខ្លាំង តាមធម្មតាពលករត្រូវបានគេផ្ដល់សម្លៀកបំពាក់ឲ្យតែមួយ ឬពីរកំប្លេតែប៉ុណ្ណោះក្នុងមួយឆ្នាំ ដែលតម្រូវឲ្យពួកគេត្រូវយកទៅជ្រលក់ពណ៌ខ្មៅ បន្ទប់ទឹក ឬបង្គន់ គឺគ្មានទេ។ ពលករត្រូវបង្ខំចិត្តបន្ទោរបង់នៅកណ្ដាលវាល នៅកន្លែងដែលគេធ្វើការ ដេក និងបរិភោគអាហារ។ មានរុយច្រើននៅពាសពេញការដ្ឋានទាំងអស់។ អតីតប្រធានអង្គភាពម្នាក់នៅឯទំនប់១មករា បាននិយាយថា កន្លែងនោះមានរុយរោមឡើងខ្មៅ។

នៅឯការដ្ឋានទំនប់ត្រពាំងថ្ម បទដ្ឋានអនាម័យបានក្លាយទៅជាមានសភាពអាក្រក់ខ្លាំងណាស់ ដែលធ្វើឲ្យពួកពលករមិនអាចនិយាយគ្នា ឬបរិភោគអាហារដោយគ្មានរុយហើរចូលក្នុងមាត់របស់ពួកគេនោះឡើយ ជាពិសេសស្ថានភាពរបស់ស្ត្រីគឺមានលក្ខណៈអាក្រក់គួរឲ្យខ្លាច ដូចដែលមានសាក្សីម្នាក់បាននិយាយរៀបរាប់អំពីរឿងរ៉ាវថា ពលករជាស្ត្រីដែលមករដូវមិនត្រូវបានគេផ្ដល់ទឹកឲ្យសម្រាប់ដុសលាងសម្អាតខ្លួនទេ។ ហេតុដូចនេះហើយ នៅពេលដែលពួកគេទៅណាក៏ដោយ ក៏ត្រូវមានរុយរោមតាមដែរ។

[១០:២៨:០០]

ការធ្វើពលកម្មហួសកម្លាំង ចំណីអាហារមិនគ្រប់គ្រាន់ និងស្ថានភាពអនាម័យគួរឲ្យតក់ស្លុត បាននាំឲ្យមានជំងឺផ្សេងៗយ៉ាងរាលដាល អ្នកណាដែលឈឺត្រូវបានគេទិតៀនថា ឈឺខ្ជិល និងធ្វើពុតឈឺ។ ពួកពលករមិនត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកឡើយ តែផ្ទុយទៅវិញត្រូវគេបង្ខំឲ្យវិលត្រឡប់ទៅកាន់ការដ្ឋានវិញ។ អ្នកទាំងឡាយណាដែលត្រូវបានពេទ្យផ្តល់ការព្យាបាលជំងឺឲ្យ គឺសុទ្ធតែត្រូវបានព្យាបាលដោយគ្រូពេទ្យដែលគ្មានការហ្វឹកហាត់ គ្រូពេទ្យជាកុមារ ដែលឲ្យថ្នាំលេបតែគ្មានប្រសិទ្ធភាពដូចជាថ្នាំអាចម៍ទន្សាយ ឬមួយក៏ចាក់ទឹកដូង និងថ្នាំប៉េនីស៊ីលីន។

[១០:២៨:៤៧]

ពួកពលករទាំងអស់ត្រូវបានគេដាក់ឲ្យស្ថិតក្រោមការត្រួតមើលពីលើ និងការឃ្លាំមើលជាប្រចាំដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលបានស្វែងរក និងកំណត់អត្តសញ្ញាណរបស់អ្នកដែលគេសន្មតថាជាខ្មាំង និងដែលត្រូវទទួលរងនូវការរំលោភបំពាន ការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់។ មានមនុស្សជាច្រើនត្រូវបានគេចាប់ខ្លួន ដោយគ្រាន់តែពួកគេជាមនុស្សដែលស្ថិតនៅក្នុងក្រុមគោលដៅណាមួយប៉ុណ្ណោះ ដូចជាអតីតគ្រូបង្រៀន អ្នកចេះដឹងខ្ពស់ និស្សិត ឬនគរបាល។

នៅតាមការដ្ឋាននីមួយៗ ក៏ដូចជានៅទីណាផ្សេងទៀតក៏ដោយក្នុងទូទាំងប្រទេស ពួកពលករសុទ្ធតែត្រូវបានគេបង្ខំឲ្យធ្វើប្រវត្តិរូបរបស់ខ្លួន ដែលនឹងត្រូវធ្វើការពិនិត្យឡើងវិញដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលកំពុងតែតាមស្រាវជ្រាវរកអ្នកណាដែលមានប្រវត្តិរូបដើមជានាយទុន ឬមាននិន្នាការប្រឆាំងនឹងបដិវត្តន៍។

តាមការពិត ដូចដែលភស្តុតាងនឹងបង្ហាញជូន បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតទម្រង់មួយសម្រាប់បំពេញប្រវត្តិរូប ដើម្បីធានាថា ព័ត៌មានត្រូវបានប្រមូលកត់ត្រាទុក និងពិនិត្យឡើងវិញនូវឋានៈតាមវិធីសាស្ត្រ--

**ប្រធានអង្គជំនុំ៖**

បាទ បានហើយ។ សូម ដល់ពេលវេលាសមល្មមនឹងសម្រាកហើយ ហើយអង្គជំនុំជម្រះសាលាដំបូងប្រកាសបញ្ឈប់សម្រាករយៈពេលម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ។

[១០:៣០:៣៦]

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១នាទី ដល់ម៉ោង ១០:៥៨នាទី)*

[១០:៥៩:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តសូមអញ្ជើញលោកជំទាវសហព្រះរាជអាជ្ញាជាតិបន្ត។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ដោយសារលោក អៀង សារី មានបញ្ហាឈឺចង្កេះឆ្អឹងខ្នងទ្រាំទ្រអង្គុយនៅទីនេះលែងបាន អ៊ីចឹងសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យគាត់ចុះទៅតាមដានសវនាការនៅបន្ទប់ខាងក្រោម។ សូមអរគុណ។ ហើយខ្ញុំបាទ សូមអនុញ្ញាតនេះគឺមួយថ្ងៃនេះពេញតែម្តង សម្រាប់ថ្ងៃរសៀលនេះដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវីការពារក្តីលោក នួន ជា-- មេធាវីការពារក្តីលោក អៀង សារី។ អង្គជំនុំជម្រះបានស្តាប់សំណើរបស់ជនជាប់ចោទ ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីស្នើមិនចូលរួមដោយផ្ទាល់នៅក្នុងសវនាការនេះ ហើយដកថយទៅតាមដាននូវកិច្ចដំណើរការសវនាការនៅបន្ទប់ខាងក្រោមតាមវីដេអូរខន់ហ្វឺរិន។

[១១:០០:៣៨]

អង្គជំនុំជម្រះយល់ឃើញថា បញ្ហានៃសវនាការនៅពេលនេះគឺការធ្វើសេចក្តីសន្និដ្ឋានសង្ខេបពីបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ ហើយដើម្បីការពារនូវសិទ្ធិរបស់ជនជាប់ចោទ វត្តមានរបស់ជនជាប់ចោទនាពេលនេះ មានសារៈសំខាន់ធ្វើឲ្យសវនាការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងទៀតដើម្បីបង្ហាញដល់ភាគី និងសាធារណជនទាំងអស់ឲ្យបានដឹងច្បាស់ថា ជនជាចោទពិតជាបានស្តាប់នូវបទចោទប្រកាន់ប្រឆាំងនឹងខ្លួនពិតប្រាកដមែន។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធនូវសំណើរបស់

ជនជាប់ចោទ ដែលស្នើសុំមិនចូលរួមដោយផ្ទាល់នៅក្នុងសវនាការនេះដោយមានបំណងទៅបន្តដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។

ហើយអង្គជំនុំជម្រះសូមរំឭកជនជាប់ចោទថា លោកអាចទៅបន្ទប់ទឹកបានដូចអ្វីដែលយើងបានជម្រាបជូននៅក្នុងអំឡុងពេលនៃដំណើរការសវនាការបឋមរួចហើយបញ្ហានេះ។

សូមអញ្ជើញលោកជំទាវសហព្រះរាជអាជ្ញាជាតិ!

[១១:០២:០០]

**លោកស្រី ជា លាង៖**

សូមអរគុណ ហើយសូមអនុញ្ញាតបន្តទៀតចាស។

មនុស្សគ្រប់ៗគ្នាត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមការប្រជុំទិតៀននិងស្វ័យទិតៀន។ ឧទាហរណ៍ដូចជានៅក្នុងពេលប្រជុំជាក្រុមនៅស្រែអំបិល មានពលករជាច្រើនត្រូវបានគេទិតៀនជាប្រចាំថា ខ្ជិលច្រអូស មិនខិតខំធ្វើការឲ្យសកម្ម និងនឹកក្រុមគ្រួសាររបស់ខ្លួន។ ជាថ្មីម្តងទៀត ការបំពាក់បំប៉ននយោបាយគឺ ជាការឆ្លុះបញ្ចាំងឲ្យឃើញពីគោលនយោបាយដែលបានយកមកអនុវត្តជាក់ស្តែង ដោយពួកមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ នេះគឺអ្វីដែលលោក ខៀវ សំផន ត្រូវបានគេរាយការណ៍មកថា បាននិយាយនៅក្នុងពេលបើកវគ្គបំពាក់បំប៉ននយោបាយមួយដល់ពួកបញ្ញវន្តដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយដែលត្រូវបានដាក់នៅក្នុងពន្ធនាគារដោយបក្សកុម្មុយនីស្តកម្ពុជាថា ដំបូងបង្អស់ដែលសមមិត្តត្រូវធ្វើ គឺត្រូវបំផ្លាញចោលទ្រព្យសម្បត្តិឯកជន។ ដើម្បីបំផ្លាញទ្រព្យសម្បត្តិឯកជនខាងសម្ភារៈ វិធីសាស្ត្រដែលសមស្រប គឺការជម្លៀសឲ្យចេញពីទីក្រុងនានា ប៉ុន្តែទ្រព្យសម្បត្តិឯកជនខាងស្មារតីវាមានគ្រោះថ្នាក់ជាងនេះតទៅទៀត គឺរួមមានរាល់អ្វីៗទាំងអស់ដែលសមមិត្តគិតថាជារបស់ខ្លួន។ អ្វីៗទាំងអស់ដែលសមមិត្តគិតថា មានអត្ថិភាពទាក់ទងជាមួយនឹងខ្លួនសមមិត្តផ្ទាល់ គ្រួសាររបស់សមមិត្ត និងភរិយារបស់សមមិត្ត។

[១១:០៤:០១]

នៅក្នុងការដ្ឋាននីមួយៗ ក្នុងចំណោមការដ្ឋានទាំងប្រាំ ការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរត្រូវបានកំណត់សម្រាប់បទល្មើសតូចតាច ឈឺច្រើន ឬធ្វើការដោយគ្មានកម្លាំងកំហែង ដើរស្វែងរកអាហារ ធ្វើការមិនបានគ្រប់តាមផែនការកំណត់ឲ្យដើរហើរសេរីដោយគ្មានការអនុញ្ញាតឲ្យទៅមើលក្រុមគ្រួសារ។ មិនគួរឲ្យជឿសោះចំពោះការដាក់ទណ្ឌកម្ម ដោយសារការធ្វើការមិនបានគ្រប់តាមផែនការដែលជាញឹក

ញយតែងតែត្រូវបានគេមិនឲ្យរបបអាហារ ហើយដំឡើងផែនការឲ្យធ្វើ។ ការដាក់ទណ្ឌកម្មផ្សេងៗទៀតរួមមាន ការវាយដំលើរូបរាងកាយដោយរំពត់ខ្សែតី និងដោយព្រនង់ឫស្សី ដោយការឃុំឃាំង ការធ្វើទារុណកម្ម និងចុងក្រោយសម្លាប់ចោល។

[១១:០៤:៥៥]

នៅក្នុងករណីជាច្រើនមនុស្សដែលត្រូវគេចាប់បានដោយសារការលួចចំណីអាហារ គឺគេយកចេញទៅ ហើយសម្លាប់ចោល។ នេះគឺជាការរៀបរាប់របស់អតីតពលករមួយរូបនៅទំនប់១មករា ថាតើការដាក់ទណ្ឌកម្មផ្សេងៗដែលគេប្រើចំពោះអ្នកដែលត្រូវគេចោទ ថាធ្វើការងារឲ្យមិនស្ងួរសកម្មមានលក្ខណៈដូចម្តេចខ្លះ? មានពេលខ្លះ ប្រធានអង្គភាពបានដាក់អ្នកពួកដែលកំពុងត្រូវគេដាក់ទណ្ឌកម្មនៅក្នុងទ្រុង ដែលធ្វើពីដើមឈើតូចៗទំហំប្រហែលប៉ុនកដៃមនុស្ស មានកន្លែងបើកមួយចំនួនដែលអាចឲ្យមើលឃើញមនុស្សដែលនៅក្នុងខាងក្នុង។ ទ្រុងទាំងនោះ ធ្វើរាងដូចជាទ្រុងសត្វសារិកាកែវ មនុស្សដែលនៅក្នុងទ្រុង គេឲ្យហូបបបរតែម្តងប៉ុណ្ណោះ ក្នុងមួយថ្ងៃ ដើម្បីឲ្យល្មមតែកុំឲ្យស្លាប់ប៉ុណ្ណោះ។ ភស្តុតាងនេះ បង្ហាញឲ្យឃើញថា អំពីភាពស៊ីសង្វាក់គ្នាគួរឲ្យកំណត់សម្គាល់មួយ អំពីវិធីសាស្ត្រដែលត្រូវបានគេយកមកប្រើដើម្បីស្រាវជ្រាវរកអត្តសញ្ញាណ និងដើម្បីបំផ្លាញចោលនូវពួកអ្នកដែលគេសន្មតថាជាខ្មាំង នៅក្នុងការដ្ឋានទាំងប្រាំនេះ។

[១១:០៦:០៥]

ជនរងគ្រោះទាំងឡាយត្រូវបានចាប់ខ្លួននៅពេលយប់ ត្រូវគេចង ឬដាក់ខ្នោះនិងយកចេញទៅ។ មានមួយចំនួនត្រូវបានបញ្ជូនឲ្យអប់រំកែប្រែ បានវិលត្រឡប់មកវិញ ជាយថាហេតុ ចំណែកឯអ្នកខ្លះទៀត បានបាត់ខ្លួនមិនដែលឃើញមុខជាថ្មីម្តងទៀតទេ។ ពលករម្នាក់ដែលមកពីទំនប់ត្រពាំងថ្មបានរៀបរាប់អំពីការសម្លាប់មួយ ដែលគាត់បានផ្តល់សក្ខីកម្មជាសាក្សីដែលនៅចម្ងាយតែ២០០ម៉ែត្រ ពីរោងដែលគាត់នៅ។ "ខ្ញុំបានឮពួកគេបញ្ជាឲ្យពួកអ្នកទោសជីករណ្តៅសម្រាប់កប់ដោយខ្លួនឯង។ ពួកគេបានឲ្យអ្នកទោសទៅអង្គុយក្បែរមាត់រណ្តៅ បន្ទាប់មកពួកគេវាយអ្នកទោសនឹងចប ហើយទម្លាក់អ្នកទោសចូលទៅក្នុងរណ្តៅ។ នៅក្នុងពេលនោះ ខ្ញុំឃើញអ្នកទោសកំពុងជីក ហើយយំ"។

បក្សកុម្មុយនីស្តកម្ពុជា បានដកហូតយកតម្លៃជីវិតមនុស្សនូវងទំនប់ត្រពាំងថ្ម ស្ត្រីដែលមានផ្ទៃពោះត្រូវបានគេទម្លាក់ចូលនៅក្នុងគ្រឹះស្ថាន*(ស៊ីក)* ពីព្រោះពួកកម្មាភិបាលទាំងនោះជឿថា ការធ្វើបែបនេះគឺជួយឲ្យទំនប់កាន់តែរឹងមាំថែមទៀត។ មានពលករវ័យក្មេងម្នាក់បានរៀបរាប់ក្នុងនាមជាសាក្សីអំពី

ព្រឹត្តិការណ៍នោះ ដូច្នេះថា "ខ្មែរក្រហមបានចងនិងវាយដំ ហើយទម្លាក់ស្ត្រីមានផ្ទៃពោះម្នាក់នៅក្នុងរណ្តៅទីមួយនៃកែមស្ពាននៅទំនប់ត្រពាំងថ្ម។ ពួកអ្នកសម្លាប់គេសុទ្ធតែស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ ខ្ញុំបានឃើញខ្មែរក្រហមវាយដំ និងទម្លាក់ស្ត្រីនោះចូលទៅក្នុងរណ្តៅ ដោយផ្ទាល់ភ្នែករបស់ខ្ញុំ។ ស្ត្រីនោះត្រូវបានគេទម្លាក់ចូលនៅក្នុងរណ្តៅ ហើយពួកអ្នកសម្លាប់បានទម្លាក់ដុំថ្មពីលើសពរូបគាត់"។

សាក្សីម្នាក់បាននិយាយថានៅស្រែអំបិល ពួកស្រីៗត្រូវបានគេចាប់ខ្លួន ពីព្រោះគ្រាន់តែឈរនៅខាងក្រៅម៉ាស៊ីនបូមទឹកនៅពេលយប់។ នៅឯអាកាសយានដ្ឋានកំពង់ឆ្នាំង អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាម្នាក់បានរៀបរាប់ថា ពួកយោធាត្រូវបានគេចាប់ខ្លួន ដោយភ្លង់នឹងកាំភ្លើងដោយសារតែបានធ្វើឱ្យបាក់ចបកាប់ ជជែកតវ៉ាច្រើនពេក និងខស្សាហ៍ឈឺជាញឹកញាប់ពេក។

[១១:០៨:៣៣]

ពលករជាច្រើនក៏ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខនានា ដើម្បីធ្វើការឃុំខ្លួនសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ផងដែរ។ អ្នកទាំងឡាយណាដែលត្រូវគេចាប់ខ្លួននៅទំនប់១មករា ត្រូវបានគេយកទៅដាក់នៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ដែលនៅទីនោះពួកគេត្រូវបានគេឃុំឃាំងក្នុងស្ថានភាពគួរឱ្យតក់ស្លុតយ៉ាងខ្លាំង មុនពេលពួកគេយកទៅធ្វើការសួរចម្លើយ វាយដំ និងធ្វើទារុណកម្ម។ គេបានប៉ាន់ប្រមាណថា មានមនុស្សចំនួនរហូតទៅដល់២ម៉ឺនប្រាំពាន់នាក់ បានស្លាប់នៅក្នុងមន្ទីរសន្តិសុខនេះ។ នៅតាមបណ្តាការដ្ឋានពលកម្មដោយបង្ខំជាច្រើន ស្ថានភាពដែលមិនអាចទ្រាំបាន បានធ្វើឱ្យពលករជាច្រើនសម្រេចចិត្តបញ្ចប់ជីវិតរបស់ខ្លួនដោយខ្លួនឯង។

[១១:០៩:៣១]

មានភស្តុតាងនៅក្នុងសំណុំរឿងបានបង្ហាញថា នៅការដ្ឋានសាងសង់វាលយន្តហោះកំពង់ឆ្នាំង មានពលករជាច្រើននាក់បានធ្វើអត្តឃាតរាល់សប្តាហ៍ ដោយហក់ចូលទៅក្រោមកង់ឱ្យរថយន្តកាមីញ៉ុងឬរ៉ូឡូកិនថ្នល់។ នៅឯស្រែអំបិលមានស្ត្រីជាច្រើននាក់បានសម្លាប់ខ្លួនឯង ដោយចងក ឬផឹកថ្នាំពុល មានខ្លះទៀតបានលង់ទឹកសមុទ្រនៅពេលព្យាយាមរត់ចេញពីស្ថានភាពមិនអាចទ្រាំទ្របាន។ ភស្តុតាងនឹងបង្ហាញឱ្យឃើញអំពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលជាជនដៃដល់នៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលខ្ញុំបានធ្វើការរៀបរាប់ដែលបានប្រព្រឹត្តដោយម៉ត់ចត់ទៅតាមបញ្ជា និងគោលនយោបាយនានាដែលត្រូវបានដាក់ចេញដោយជនជាប់ចោទ។

ជនជាប់ចោទមិនគ្រាន់តែបានដឹកនាំអនុវត្តនូវឧក្រិដ្ឋកម្មទាំងនេះប៉ុណ្ណោះទេ ថែមទាំងបានទទួល

ដំណឹងជាប់ជាប្រចាំអំពីស្ថានភាពនៅនឹងកន្លែងដោយផ្ទាល់តាមរយៈប្រព័ន្ធទូរគមនាគមន៍ និងសេចក្ដីរាយការណ៍ដែលសហការីអន្តរជាតិ នឹងរៀបរាប់ជូននៅពេលក្រោយ។

ឥឡូវនេះ ខ្ញុំនឹងផ្ដល់ជូននូវការរៀបរាប់ដោយសង្ខេបៗអំពីអង្គហេតុដែលបានចោទប្រកាន់ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំក្នុងដំណាក់កាលទីពីរ អំពីបទឧក្រិដ្ឋទីពីរដែលជាកម្មវត្ថុនៃសវនាការជំនុំជម្រះក្ដីលើកដំបូងនេះ។

ការជម្លៀសក្នុងដំណាក់កាលទីពីរ។ ដូចដែលសហការីរបស់ខ្ញុំនឹងរៀបរាប់តាមក្រោយនៅក្នុងខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើងនូវការជម្លៀសប្រជាជនដោយបង្ខំក្នុងទ្រង់ទ្រាយធំមួយ ដែលនៅក្នុងនោះយ៉ាងហោចណាស់ក៏មានប្រជាជនពីប្រាំសែននាក់ត្រូវបានគេបញ្ជូនពីភូមិភាគបូព៌ា និរតី និងភូមិភាគឧត្តរ ឲ្យទៅកាន់ខេត្តបាត់ដំបូង និងពោធិ៍សាត់ដែលស្ថិតនៅក្នុងភូមិភាគពាយព្យ។

[១១:១១:៣៥]

ជនរងគ្រោះភាគច្រើន គឺជាប្រជាជនថ្មីដែលជាអ្នករស់នៅក្នុងទីក្រុង ដែលត្រូវបានគេបណ្ដេញចេញពីទីក្រុងនានារួចហើយកាលពីដើមឆ្នាំ។ នៅក្នុងអំឡុងពេលតែប៉ុន្មានខែប៉ុណ្ណោះ នៃការមកដល់តាំងទីតាំងថ្មី នៅតាមតំបន់ជនបទនានា។ ប្រជាជនទាំងនេះត្រូវបានគេជម្លៀសសាជាថ្មីម្ដងទៀត នៅក្នុងការបន្ដជំរុញការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការធ្វើឲ្យទៅជាទាសករ និងធ្វើពលកម្មដោយបង្ខំជាបន្តទៀត។

គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចក្នុងខែសីហា ឆ្នាំ១៩៧៥ ដើម្បីបង្កើតផលិតផលស្រូវនៅក្នុងភូមិភាគពាយព្យ។ ដើម្បីធ្វើកិច្ចការនេះ គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចថា កម្លាំងពលកម្មនៅក្នុងភូមិភាគពាយព្យត្រូវតែពង្រីកបន្ថែមឲ្យបានច្រើនថែមទៀត ហើយថាដាច់ខាតត្រូវតែបន្ថែមមនុស្សឲ្យបានចំនួនពីបួន ឬប្រាំសែននាក់ ពីលើចំនួនប្រជាជនដែលមាននៅក្នុងភូមិភាគពាយព្យនេះស្រាប់។

[១១:១២:៤២]

ជាថ្មីម្ដងទៀត ប្រជាជនស៊ីវិលរាប់សែននាក់បានជួបប្រទះនឹងការដែលគេបង្ខំឲ្យរៀបចំអីវ៉ាន់ដែលនៅសេសសល់តែបន្តិចបន្តួចសម្រាប់ការរស់នៅរបស់ពួកគេ ហើយចាប់ផ្ដើមនាំគ្នាចាកចេញទាំងហ្វូងទៅកាន់កន្លែងផ្សេងទៀត ដែលត្រូវបានគេឃ្វាលដូចសត្វ តាមបញ្ជាតឹងរ៉ឹងរបស់ពួកកម្មាភិបាល

របស់បក្សកុម្មុយនីស្តកម្ពុជា។ ដូចជានៅក្នុងខែមេសា ឆ្នាំ១៩៧៥ អ្នកទាំងឡាយណាដែលប្រកែកមិនព្រមអនុវត្ត គឺត្រូវថិតនៅក្នុងស្ថានភាពមួយដែលពិបាកស្ទើររស់ស្ទើរស្លាប់។

តាមសម្តីរបស់អ្នកជម្លៀសម្នាក់ ដែលត្រូវបានគេជម្លៀសឲ្យទៅកាន់ខេត្តពោធិ៍សាត់ថា គ្មាននរណាម្នាក់ហ៊ានប្រកែកទេ ប្រជាជនមានការភ័យខ្លាច ពួកគេបង្ខំចិត្តត្រូវតែចាកចេញ។ ពួកខ្មែរក្រហមបាននិយាយប្រាប់ពួកយើងថា អង្គប្រជុំនៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ បើសិនជាពួកយើងប្រកែក អង្គការមុខជានឹងយកយើងទៅធ្វើការអប់រំកែប្រែហើយ។ ប្រជាជនសុទ្ធតែបានដឹងថា អ្នកដែលគេយកទៅធ្វើការអប់រំកែប្រែនោះ មិនដែលមាននរណាវិលត្រឡប់មកវិញទាល់តែសោះ។

[១១:១៣:៥៧]

ប្រជាជនត្រូវបានគេដឹកតាមមធ្យោបាយផ្សេងៗ រួមមានរថយន្តកាំមីញ៉ុង រថភ្លើង កប៉ាល់ និងរទេះគោ។ មានប្រជាជនជាច្រើនបានដើររហូតក្នុងអំឡុងពេលជម្លៀសនេះ។ នៅក្នុងពេលជម្លៀសនេះ ជនរងគ្រោះបានស្ថិតនៅក្រោមការឃ្លាំមើលដោយប្រុងប្រយ័ត្នជានិច្ច ពីពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលប្រដាប់ដោយអាវុធ។ មានប្រជាជនជាច្រើនបានស្លាប់ដោយសារការអត់អាហារ ឬបាក់កម្លាំង។ មានកម្មកររថភ្លើងរបស់បក្សកុម្មុយនីស្តកម្ពុជាម្នាក់បានផ្តល់សក្ខីកម្មជាសាក្សីពីការចងចាំអំពីការជម្លៀសចេញដោយបង្ខំ ដោយផ្តល់សក្ខីកម្មថា "គ្មាននរណាម្នាក់ចាកចេញបានទេ ដោយសារមានអ្នកយាមតាមដាន។ អ្នកណាដែលមានជំងឺមុខជាត្រូវស្លាប់នៅទីនោះហើយ"។

[១១:១៤:៥០]

ក្នុងសៀវភៅរបស់ខ្លួនដែលមានចំណងជើងថា នៅពេលដែលសង្គ្រាមផុតរលត់ទៅ លោកស្រីអេលីហ្សាប៊េត បេកយ័រ បានរៀបរាប់អំពីការនិយាយរឿងរ៉ាវផ្សេងៗរបស់សាក្សី។ អំពីស្ថានីយរទេះភ្លើងនៅពោធិ៍សាត់ ដែលនៅទីនោះមានអ្នកជម្លៀសរាប់ពាន់នាក់នៅទីនោះ នាំគ្នាបោះតង់រង់ចាំគេជម្លៀសបន្តទៀត។ នៅកន្លែងនេះមានអាចម៍មនុស្សពាសពេញ និងមានរុយរោមយ៉ាងច្រើន។ ជាថ្មីម្តងទៀត មិនមានអាហារគ្រប់គ្រាន់ទេ និងគ្មានកន្លែងណាសម្រាប់សម្រាកឡើយ គឺមានតែទីវាលទទេតែប៉ុណ្ណោះ។ ទឹកមានតិចតួចណាស់សម្រាប់ហូប មិនអាចងូតបានទេ។ មានសាកសពជាច្រើននៅរាយប៉ាយ និងមានក្លិនស្អុយដែលភាយពីលាមកមនុស្ស និងលាមកសត្វដែលធ្វើឲ្យមិនអាចទ្រាំបាន។

ជនរងគ្រោះដែលត្រូវបានធ្វើសម្ភាសន៍ដោយលោក ប៊ែន យៀរនិន បានបញ្ជាក់អំពីចំនួនមនុស្សស្លាប់យ៉ាងច្រើននៅត្រង់ចំណុចផ្ទេរនៅខេត្តពោធិ៍សាត់។ សាក្សីម្នាក់ដែលសហចៅក្រមស៊ើបអង្កេត

បានធ្វើសម្ភាសន៍ បានរៀបរាប់អំពីការបាត់កូនទាំងពីរនាក់របស់គាត់នៅក្នុងពេលជម្លៀសនោះ។ កូនប្រុសរបស់គាត់ ដែលគាត់បានដាក់នៅក្នុងល្អី ដែលគាត់រែកនៅក្នុងពេលកំពុងធ្វើដំណើរបានស្លាប់ ខ្លួនដ៏តូចរបស់កូនគាត់បានហើម ដោយសារតែមានជំងឺ។ យប់បន្ទាប់ក្នុងពេលដែលរូបគាត់ ត្រូវបានគេដឹកជញ្ជូនតាមរថយន្ត កូនង៉ែតស្រីរបស់គាត់ដែលមានអាយុមិនទាន់គ្រប់មួយខួបផង បានស្លាប់នៅក្នុងដៃរបស់គាត់។ រាល់ពេលដែលកូនគាត់ស្លាប់ គាត់ត្រូវតែគេបញ្ជាឲ្យប្រគល់សាកសពកូននោះ ឲ្យទៅពួកយោធាតែប៉ុណ្ណោះ។

[១១:១៦:៣៧]

នៅពេលដែលអ្នកជម្លៀសបានធ្វើដំណើរមកដល់ទីដៅកំណត់របស់ពួកគេ ៗត្រូវបានគេយកទៅដាក់នៅតាមតំបន់ ឬភូមិនានាដែលនៅដាច់ស្រយាល និងសោះកក្រោះ ដែលត្រូវបានបំផ្លិចបំផ្លាញ។ ពួកគេមានរបស់របរជាប់តាមខ្លួនតិចតួច ឬគ្មានសោះតែម្តង ហើយត្រូវបានគេប្រាប់ឲ្យសាងសង់ជម្រកស្នាក់នៅដោយខ្លួនឯង ដូចដែលអ្នកជម្លៀសម្នាក់បានរៀបរាប់ អំពីរឿងរ៉ាវនេះដោយលម្អិតថា “មានហ្វូងមនុស្សយ៉ាងច្រើនកកកុញ កំពុងរស់នៅក្នុងព្រៃគ្មានផ្ទះសម្បែងទេ ពួកយើងត្រូវកាប់ដើមឈើដោយខ្លួនយកមកសង់ទីជម្រកស្នាក់នៅ។ មានមនុស្សជាច្រើនផ្សេងទៀត ត្រូវបានគេដាក់ឲ្យរស់នៅកណ្តាលវាលនៅក្នុងរោងធំៗ និងនៅក្នុងក្រោលគោ ឬនៅតាមក្រោមផ្ទះរបស់ប្រជាជនអ្នកមូលដ្ឋាន ដែលជាកន្លែងដែលគេធ្លាប់បានប្រើប្រាស់ធ្វើជាកន្លែងសម្រាប់ដាក់សត្វ កាលពីមុនពេលបដិវត្តន៍។”

[១១:១៧:៣៩]

បន្ទាប់ពីការមកដល់ អ្នកជម្លៀសត្រូវបានគេបង្ខំឲ្យបន្តធ្វើពលកម្មដោយដៃ នៅក្រោមការត្រួតពិនិត្យពីលើដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ សាជាថ្មីម្តងទៀត ការអត់អាហារ ជំងឺឈឺថ្កាត់ ការធ្វើការហាលវាល និងការគ្មានពេទ្យព្យាបាលជំងឺ បានបណ្តាលឲ្យមានមនុស្សស្លាប់រាប់ពាន់នាក់។ ការជម្លៀសប្រជាជនរាប់ម៉ឺននាក់ ត្រូវបានបណ្តាលឲ្យមានការអត់អាហារយ៉ាងរីករាលដាលនៅក្នុងភូមិភាគពាយព្យ។ គ្មានការត្រៀមរៀបចំទុកជាមុនណាមួយ ត្រូវបានធ្វើឡើងដើម្បីធានាឲ្យប្រាកដថា តំបន់ទាំងឡាយ ដែលនឹងត្រូវទទួលអ្នកជម្លៀស អាចផ្គត់ផ្គង់ម្ហូបអាហារបានគ្រប់គ្រាន់នោះឡើយ។

ដូចដែលលោក ប៉ែន យៀរនិន បានធ្វើការកត់សម្គាល់ថា មជ្ឈិមបក្សមិនបានបញ្ជូនស្រូវអង្ករមកឲ្យភូមិភាគពាយព្យ ដើម្បីជួយដល់ភូមិភាគនេះទេ ក្នុងរយៈពេលដែលមិនសូវបានផលល្អនោះទេ។

នេះហើយដែលសាក្សីម្នាក់ត្រូវបានគេជម្លៀសចេញដោយបង្ខំ ឲ្យទៅកាន់ស្រុកបាកានបានរៀបរាប់អំពីថា តើមានការស្លាប់យ៉ាងដូចម្តេចនៅក្នុងឃុំរបស់គាត់? មនុស្សស្លាប់ភាគច្រើន គឺបណ្តាលមកពីការអត់អាហារ ដែលយ៉ាងហោចណាស់ក៏មានមនុស្សស្លាប់១០នាក់ដែរក្នុងមួយថ្ងៃ។ ដោយសារអត់អាហារ ពួកខ្មែរក្រហមបានយកសាកសពទៅចោលនៅក្នុងរណ្តៅធំហមួយ ដែលពួកគេមិនបានលុបវិញទេ។

[១១:១៩:១០]

សាក្សីម្នាក់ទៀត បានធ្វើការប៉ាន់ប្រមាណថា ចំនួនមនុស្សស្លាប់ដោយសារការអត់អាហារគឺមានរហូតទៅដល់៧០ទៅ៨០នាក់ឯណោះក្នុងមួយថ្ងៃ គ្រាន់តែនៅក្នុងសហករណ៍មួយប៉ុណ្ណោះក្នុងស្រុកព្រះនេត្រព្រះ។ ផ្អែកតាមប្រជាជនម្នាក់ ដែលជាអ្នកស្រុករស់នៅក្នុងស្រុកជាមួយគ្នានេះ ដែលត្រូវបានប៉ែន ឃៀរនិន ធ្វើសម្ភាសន៍នៅត្រឹមចុងឆ្នាំ១៩៧៥ និយាយថា មានកម្មករចំនួន៤០០នាក់ក្នុងចំណោម៥០០០នាក់នៅក្នុងអង្គភាពរបស់គាត់បានស្លាប់។ នៅមន្ទីរពេទ្យស៊ីសុផុន អ្នកជំងឺដែលអត់អាហារបានអារសាច់សាកសពដែលនៅក្បែរខាងរបស់ខ្លួនយកមកអាំង ហើយបរិភោគ។

[១១:១៩:៥៦]

គោលនយោបាយក្នុងការធ្វើទារុណកម្ម និងការសម្លាប់យ៉ាងសាហាវយង់ឃ្នង ដែលឥឡូវនេះបានក្លាយទៅជាស្លាកយីហោពាណិជ្ជកម្មមួយរបស់ពួកខ្មែរក្រហម ត្រូវបានក្លាយទៅជាផ្នែកមួយនៃជីវភាពប្រចាំថ្ងៃសម្រាប់អ្នកជម្លៀសក្នុងភូមិភាគពាយព្យ។ សាក្សីម្នាក់បានថ្លែងថា ការមកដល់ក្នុងភូមិភាគពាយព្យរបស់គាត់ គឺជាការចាប់ផ្តើមនៃការបាត់បង់ភាពជាមនុស្សហើយ។ អ្នកស្រីបានរៀបរាប់អំពីការសម្លាប់មួយ ដែលគាត់បានផ្តល់សក្ខីកម្មជាសាក្សីដោយមិនមានបំណងជាមុនថា "ខ្ញុំបានឮសំឡេងបុរសម្នាក់កំពុងសុំការត្រាប្រណីទោស ដោយមិនបាច់ងឿងឆ្ងល់ ខ្ញុំក៏ចូលទៅកាន់តែជិត ហើយបានឃើញបុរសម្នាក់ខ្លួនទទេចាប់ពីចង្កេះឡើងមកលើ ដោយមានពួកខ្មែរក្រហមប្រដាប់ដោយអាវុធបីទៅបួន ប្រាំនាក់នៅព័ទ្ធជុំវិញ។ បុរសនោះកំពុងត្រូវបានគេគ្រៀកឲ្យឈរឲ្យត្រង់ ដោយខ្មែរក្រហមពីរនាក់។ មានមនុស្សទីបីម្នាក់ទៀត បានយកកាំបិតមកហើយក៏បានវះពោះបុរសនោះបើចំហនៅក្នុងពេលដែលគាត់រស់នៅនៅឡើយ។ ហើយបានស្រាវយកពោះវៀន ពោះតាំងរបស់គាត់ចេញមកក្រៅ ដើម្បីលូកកាត់យកថ្លើមរបស់គាត់ចេញមក"។

[១១:២១:២៤]

អ្វីដែលបានបន្តតាមក្រោយនេះ គឺមានការបោសសម្អាតនិងការសម្លាប់នៅក្នុងភូមិភាគពាយ័ព្យ។

នៅពេលដែលមនុស្ស-- ចំនួនមនុស្សស្លាប់ពិតប្រាកដជាលទ្ធផល បណ្តាលមកពីការជម្លៀសដោយបង្ខំនៅក្នុងដំណាក់កាលទីពីរ ទំនងជាមិនបានដឹងជាការច្បាស់ណាស់ថា ឧក្រិដ្ឋកម្មនេះបានបណ្តាលឲ្យមានការស្លាប់មនុស្សចំនួនរាប់សែននាក់។ នេះគឺជាការរៀបរាប់របស់លោក ដេវីដ ឆេនដ័ល័រ ជាប្រវត្តិវិទូ និងជាអ្នកជំនាញដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ បានរៀបរាប់អំពីថា តើផលប៉ះពាល់ចំពោះជនរងគ្រោះ និងភាពមិនច្បាស់លាស់របស់របបនេះអំពីការរងទុក្ខវេទនាធំណាស់ ដែលរបបនេះបានបង្កឡើង មានលក្ខណៈយ៉ាងដូចម្តេចខ្លះ?

បុរស និងស្ត្រីទាំងនេះត្រូវបានគេបង្ខំឲ្យធ្វើស្រែ ជីកប្រឡាយទឹក លើកទំនប់ និងឆ្ការព្រៃដែលមានជំងឺគ្រុនចាញ់នៅតាមភូមិភាគនានា។ មានមនុស្សរាប់ម៉ឺននាក់បានស្លាប់នៅក្នុងចំណោមនេះ ដោយសារអាហារហូបចុកមិនគ្រប់គ្រាន់ ជំងឺ ការសម្លាប់ និងធ្វើការហួសកម្លាំង។ ការស្លាប់ទាំងនេះនៅពេលដែលបានដឹងធ្វើឲ្យរដ្ឋអំណាចនៅក្នុងទីក្រុងភ្នំពេញមានទុក្ខព្រួយ លុះត្រាតែពួកគេត្រូវបានបញ្ជាក់ថាពួកខ្មាំងដែលកំពុងតែធ្វើសកម្មភាពនៅពីក្រោយឆាកតែប៉ុណ្ណោះ។

[១១:២២:៥១]

ប្រជាជនថ្មីដោយសារតែពួកគេមានចំនួនច្រើនសន្ធឹកសន្ធាប់ ហើយដែលជាខ្មាំងសត្រូវរបស់បដិវត្តន៍ ដែលអាចឲ្យពង្រីកបន្ថែមបាន។

សហការីរបស់ខ្ញុំអន្តរជាតិ នឹងបង្ហាញឲ្យឃើញថាអំពីភស្តុតាងសហការដែលនៅក្នុងសំណុំរឿងបានបញ្ជាក់ថា មជ្ឈិមបក្សគឺត្រូវបានគេជូនដំណឹងត្រឹមត្រូវតាមការកំណត់អំពីការស្លាប់ទាំងនេះនៅក្នុងភូមិភាគពាយព្យ។

ការធ្វើទុក្ខបុកម្នេញលើព្រះពុទ្ធសាសនា៖

ជនជាប់ចោទ ក៏ត្រូវបានចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញចំពោះពុទ្ធសាសនិកជនផងដែរ។ ហើយឥឡូវនេះខ្ញុំសូមលើកឡើងដោយត្រួសៗអំពីភស្តុតាងដែលទាក់ទងនឹងឧក្រិដ្ឋកម្មនេះ។ ចាប់តាំងពីឆ្នាំ១៩៧៥បន្តមក ពួកមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានបង្កើត និងត្រួតត្រាមើលពីលើយន្តការមួយនៅទូទាំងប្រទេសក្នុងការលុបបំបាត់ព្រះពុទ្ធសាសនា។ គោលនយោបាយនេះ ត្រូវបានអនុវត្តតាមឧក្រិដ្ឋកម្មផ្សេងៗមួយចំនួន ដែលរួមមានការផ្សឹកលោកសង្ឃ និងការធ្វើឲ្យលោកសង្ឃទាំងឡាយទៅជាទាសករនៅតាមជំរំធ្វើពលកម្មដោយបង្ខំ។

[១១:២៤:០៩]

ការហាមឃាត់នូវរាល់ទម្រង់នៃការធ្វើវិធីផ្សេងៗ បែបព្រះពុទ្ធសាសនាទៅតាមទំនៀមទម្លាប់ប្រពៃណី ឬក៏ការធ្វើបុណ្យ។ ការបំផ្លាញវត្ត និងរូបបដិមាករ ការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ព្រះសង្ឃ និងអ្នកដែលរឹងរូសនឹងការបង្ក្រាបនេះ។

ព្រះពុទ្ធសាសនាហិនយាន គឺជាសាសនាដែលលើសលុបគេនៅក្នុងប្រទេសកម្ពុជា ហើយដែលប្រជាជនខ្មែរមានជំនឿយ៉ាងស្មោះ។ គោលការណ៍នៃព្រះពុទ្ធសាសនា បានញ៉ាំងចិត្តនៅក្នុងរាល់ទិដ្ឋភាពទាំងអស់នៃជីវភាពរស់នៅរបស់ប្រជាជនខ្មែរ ចាប់តាំងពីពេលកើតមក រហូតដល់ធំពេញវ័យក្នុងការអប់រំរៀនសូត្រ ការរៀបអាពាហ៍ពិពាហ៍ និងជីវភាពគ្រួសារ ហើយនៅទីបំផុតនៅក្នុងពេលស្លាប់។

[១១:២៥:០០]

ជាច្រើន ទសវត្សរ៍ សតវត្សរ៍មកហើយ រាល់ការអប់រំទាំងអស់គឺបានធ្វើឡើងនៅតាមវត្ត ហើយដែលត្រូវបានគេគ្រប់គ្រងដោយព្រះសង្ឃនៃព្រះពុទ្ធសាសនា នៅមុនរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងហោចណាស់ក៏មានប្រជាជនកម្ពុជា៨៥ភាគរយដែរ ដែលបានកាន់ព្រះពុទ្ធសាសនា។

នៅក្នុងមាត្រា២០ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានចែងថា ពលរដ្ឋគ្រប់រូបរបស់កម្ពុជាមានសិទ្ធិក្នុងការគោរពបូជាតាមសាសនាណាមួយ ហើយក៏មានសិទ្ធិមិនគោរពបូជាតាមសាសនាមួយដែរ។ សាសនាប្រតិកិរិយាទាំងឡាយដែលធ្វើឲ្យអន្តរាយដល់របបកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាត្រូវហាមឃាត់ដាច់ខាត។ ក្នុងការអនុវត្តជាក់ស្តែង រាល់សាសនាទាំងអស់ត្រូវបានចាត់ទុកថាជាសាសនាប្រតិកិរិយា ហើយដែលត្រូវតែលុបបំបាត់ចោល។ ពុទ្ធសាសនាត្រូវបានគេរំសាយចោលពីព្រោះសាសនានេះត្រូវបានគេយល់ឃើញថា ជាស្ថាប័នមួយរបស់សង្គមកេងប្រវ័ញ្ច។

[១១:២៦:០៦]

សំខាន់ជាងនេះទៅទៀត ព្រះពុទ្ធសាសនាគឺជាមជ្ឈមណ្ឌលដែលជាជម្រើសម៉្យាងទៀតនៃភាពស្មោះត្រង់សម្រាប់ប្រជាជនខ្មែរភាគច្រើន។ ហេតុដូចនេះសាសនានេះគឺអាចជាតំណាងឲ្យប្រភពមួយដែលប្រឆាំងចំពោះបក្សកុម្មុយនីស្តកម្ពុជា។ ដូចដែល យុន យ៉ាត រដ្ឋមន្ត្រីនៃក្រសួងឃោសនាការបាននិយាយថា ប្រាប់អ្នកកាសែតយូហ្គោស្លាវីនៅក្នុងអំឡុងពេលទៅធ្វើទស្សនកិច្ចរបស់គាត់ថា “ព្រះពុទ្ធសាសនាគឺជាវិសមភាពជាមួយនឹងបដិវត្តន៍”។

លោកប្រធាន លោក លោកស្រីចៅក្រម នឹងបានស្តាប់នូវការរៀបរាប់រឿងរ៉ាវជាច្រើនអំពីថា តើពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងទូទាំងប្រទេសបានហាមឃាត់មិនឲ្យអនុវត្តពុទ្ធសាសនា

និងបានធ្វើទុក្ខបុកម្នេញចំពោះពុទ្ធសាសនិកជនព្រោះតែជំនឿរបស់ពួកគេយ៉ាងដូចម្ដេចខ្លះ?

[១១:២៧:០២]

សក្ខីកម្ម សាក្សីដូចខាងក្រោមនេះបានរៀបរាប់អំពី តើមានអ្វីកើតឡើងខ្លះនៅពេលបក្សកុម្មុយនីស្តកម្ពុជាដណ្ដើមយកបានភូមិតាគាត់ នៅក្នុងស្រុកកណ្ដាល។ ពួកគេមិនបានអនុញ្ញាតឲ្យធ្វើពិធីបុណ្យផ្សេងៗ ឬធ្វើទាននោះទេ។ ព្រះសង្ឃទាំងអស់ត្រូវបានបង្ខំឲ្យបោះបង់ចោលនូវភាពជាព្រះសង្ឃ ពួកប្រធានអង្គភាព ប្រធានកង និងប្រធានភូមិនានាបានប្រកាសថា ជំនឿផ្សេងៗខាងសាសនាមិនត្រូវបានអនុញ្ញាតទេ ពួកគេនិយាយថាពួកនិស្សិតនិងបញ្ញវន្ត ហើយនិងព្រះសង្ឃ គឺសុទ្ធតែជាពួកវណ្ណៈគហបតីមធ្យម ហើយជាខ្មាំងសត្រូវរបស់ពួកគេ។ ពួកគេនិយាយថា ព្រះសង្ឃដែលស្លៀកស្បង់ធំៗគឺជាពួកសក្ដិភូមិដែលជញ្ជក់ឈាមរបស់ប្រជាជន។

[១១:២៧:៥៦]

ជាក់ស្ដែង បក្សកុម្មុយនីស្តកម្ពុជាបានបង្ខំឲ្យព្រះសង្ឃនិងយាយជីទាំងអស់ផ្សឹកដោយប្រើកម្លាំងមានករណីជាច្រើនពួកគេបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍។ ដូចដែលអតីតព្រះសង្ឃមួយអង្គបានថ្លែងថា "ការមិនព្រមអនុវត្តតាមគឺមានន័យថាពួកកម្មាភិបាលនឹងរាយការណ៍ទៅថ្នាក់លើ ហើយពួកគេនឹងយកចេញទៅមានន័យថា នឹងចូលទៅក្នុងរណ្ដៅសព"។ ចំពោះពុទ្ធសាសនិកជនគឺមានលទ្ធភាពជំទាស់បានឡើយ។

សាក្សីមួយរូបទៀតនឹងរំឭកឡើងវិញអំពីថា តើពួកកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាបានណែនាំយ៉ាងដូចម្ដេចខ្លះដល់ព្រះសង្ឃ "ឲ្យលះបង់ភាពជាព្រះសង្ឃចោល បើពុំនោះទេនឹងត្រូវគេសម្លាប់ចោល ហើយថ្លើមរបស់ពួកគេនឹងត្រូវគេយកមកឆាធ្វើជាអាហារ ដើម្បីបរិភោគ"។ អតីតព្រះសង្ឃមួយអង្គបានផ្ដល់សក្ខីកម្មសាជាថ្មីថា "សាក្សីថាព្រះសង្ឃដែលបានបដិសេធមិនព្រមផ្សឹកត្រូវបានគេបញ្ជូនឲ្យនៅក្នុងព្រៃណាមួយ ឲ្យរស់នៅតែម្នាក់ឯង ដោយគ្មានអាហារ" លោកមានសង្ឃដីកាថា "ខ្ញុំធ្លាប់បានឮពាក្យចចាមអារ៉ាមថា ព្រះសង្ឃទាំងឡាយគឺជាអ្នកចម្លងជំងឺដែលជញ្ជក់ឈាមប្រជាជន"។ បន្ទាប់ពីព្រះសង្ឃទាំងអស់ត្រូវបានផ្សឹករួចមក ស្បង់ និងរបស់របរផ្សេងៗដែលនៅក្នុងវត្តត្រូវបានគេប្រមូល ហើយបោះចោល។ នៅពេលនោះ រាល់ព្រះបដិមាករទាំងអស់ត្រូវបានគេកម្ទេច។ ពួកគេបាននិយាយថា "អ្នកឯងថ្វាយបង្គំព្រះពុទ្ធ គឺថ្វាយបង្គំរូបស៊ីម៉ងត៍ លើកដៃសំពះព្រះសង្ឃដូចសំពះកូនអ្នកស្រុក"។

[១១:២៩:៥២]

ការធ្វើទុក្ខបុកម្នេញចំពោះព្រះសង្ឃមានលក្ខណៈជាប្រព័ន្ធ ហើយមានភាពស៊ីសង្វាក់គ្នានៅក្នុងប្រទេសទាំងមូល។

តទៅនេះ គឺជាការរៀបរាប់របស់អតីតព្រះសង្ឃមួយអង្គ អំពីវិធីដំណើរការនេះ តើមានលក្ខណៈយ៉ាងដូចម្តេចខ្លះ? បញ្ជាទាំងឡាយ គឺមកពីពួកខ្មែរក្រហមនៅថ្នាក់លើ ថ្នាក់តំបន់បញ្ជាមកស្រុក ហើយថ្នាក់ស្រុកបញ្ជាមកថ្នាក់ឃុំ ហើយថ្នាក់ឃុំបញ្ជាមកគណៈកម្មាការសង្ឃថ្នាក់ឃុំ ដើម្បីឲ្យផ្សឹកលោកសង្ឃ។ នៅពេលដែលពួកគេមកបញ្ជាឲ្យពួកយើងលះបង់ចោលនូវភាពជាព្រះសង្ឃនោះ ពួកខ្មែរក្រហមបានជេរពួកយើងដោយនិយាយថា ពួកយើងនេះគឺជាឈ្លើង ជាពួកដង្កូវ ប៉ារ៉ាស៊ីត ជញ្ជក់ឈាម។ បើសិនជាពួកយើងបដិសេធមិនព្រមលះបង់ចោលនូវភាពជាព្រះសង្ឃទេនោះ ពួកយើងគេមុខជានឹងបញ្ជូនពួកយើងឲ្យទៅថ្នាក់លើ។ មានលោកសង្ឃពីរអង្គដែលបានបដិសេធ អង្គការបានយកលោកទាំងពីរអង្គនោះទៅ ហើយមិនដែលឃើញពួកលោកវិលត្រឡប់វិញទាល់តែសោះ។

[១១:៣១:០០]

បន្ទាប់មក ពួកយើងបានលះបង់ភាពជាព្រះសង្ឃចោល ពួកខ្មែរក្រហមបានឲ្យពួកយើងធ្វើពលកម្ម ហើយនៅក្នុងពេលប្រជុំជីវភាពម្តងៗ ពួកវាឲ្យពួកយើងកសាងខ្លួន។ ពួកវាបានជេរប្រទេចផ្តាសាពួកយើងថា ជាថៃសង្គម ជាមនុស្សខ្ជិលច្រអូស ដែលធ្លាប់តែរស់នៅក្នុងជីវភាពស្រណុកសុខស្រួល ស៊ីស្រួល ហើយដេកស្រួល។ ហើយពួកវាបានប្រាប់ពួកយើងថា ត្រូវបម្រើអង្គការដោយគ្មានលក្ខខណ្ឌ។

បក្សកុម្មុយនីស្តកម្ពុជាបានប្រមាថវត្ថុស័ក្តិសិទ្ធិនានា និងបំផ្លាញចោលនូវទីកន្លែងសម្រាប់សក្ការៈបូជាចំពោះព្រះពុទ្ធសាសនាផងដែរ មានវត្ត និងកុដិលោកជាច្រើនត្រូវបានក្លាយទៅជាទីកន្លែងសម្រាប់ប្រើប្រាស់ផ្សេង ដែលមិនបម្រើខាងសាសនា ដូចជាទៅជាពន្ធនាគារ កន្លែងធ្វើទារុណកម្ម ទ្រុងជ្រូក និងជាឃ្លាំង។

ទីកន្លែងជាក់លាក់ដូចខាងក្រោមនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ គឺវត្តដំណាក់ត្រយឹង នៅក្នុងខេត្តកំពត វត្តសំរោងក្នុង និងវត្តគិរីរម្យ នៅក្នុងខេត្តបាត់ដំបង វត្តចំបក់ធំ និងវត្តផ្អក នៅក្នុងខេត្តស្វាយរៀង វត្តតាគត់ និងវត្តមេ នៅក្នុងខេត្តកណ្តាល វត្តជ័យមង្គល នៅក្នុងខេត្តស្ទឹងត្រែង វត្តអន្លង់វៀន នៅក្នុងខេត្តក្រចេះ និងវត្តទាំងឡាយដែលត្រូវបានគេរកឃើញនៅក្នុងសហករណ៍

ត្រាំកក់។ វត្តសំរោងក្នុង នៅក្នុងខេត្តបាត់ដំបងត្រូវបានប្រែទៅជាមន្ទីរសន្តិសុខមួយ ដែលនៅក្នុងនោះមានកុដិលោកចំនួន១៥ត្រូវបានគេបំផ្លាញចោល ហើយពួកអ្នកទោសត្រូវបានគេឃុំឃាំងនៅក្នុងអគារមួយ ដែលនៅខាងក្រោយវត្តធំ។ មានអ្នកទោសជាច្រើនត្រូវបានគេសម្លាប់ចោល ហើយត្រូវបានគេកប់នៅតាមរណ្តៅ ដែលនៅក្បែរៗនោះ។

[១១:៣២:៥៨]

សាក្សីម្នាក់ ដែលសព្វថ្ងៃនេះជាដូនជី បានរៀបរាប់អំពីការសង្កេតក្រោយឆ្នាំ១៩៧៩ របស់គាត់។ ចំពោះវត្តគិរីរម្យ ដែលត្រូវបានប្រែក្លាយទៅជាមន្ទីរសន្តិសុខមួយ ដោយបក្សកុម្មុយនីស្តកម្ពុជាថា ខ្ញុំបានឡើងទៅកាន់ទីនោះដើម្បីចូលជាអ្នកបួស ហើយបានឃើញឆ្អឹងជាច្រើន។ ខ្ញុំបានឃើញប្រហោងដែលគេបានចោះក្នុងជញ្ជាំងនៅខាងត្បូងវត្តគិរីរម្យ និងកំពុងជ្រលក់ពណ៌ស័ង្កសី ដែលគេទុកសម្រាប់ឲ្យឈាមហូរតាមនេះ។ ពួកកម្មាភិបាលខ្មែរក្រហមបានទម្លាប់ បានបំផ្លាញផងដែរនូវស្នាដៃសិល្បនៅ ទូទាំងប្រទេស។

ជាញឹកញាប់រូបព្រះពុទ្ធបដិមាករទាំងឡាយត្រូវបានបំផ្លាញ ហើយបោះបង់ចោលនៅក្នុងស្រះស្ទឹង ឬទន្លេ ដែលនៅជិតព្រះវិហារនោះ អតីតព្រះសង្ឃមួយអង្គមានសង្ឃដីកាអំពីការវិលចូលទៅកាន់អតីតវត្តរបស់ព្រះនៅក្នុងខេត្តកំពតថា ខ្ញុំបានឃើញព្រះវិហារនៅសល់តែគ្រោងទេ អស់គ្បឿង អស់អីហើយ គឺនៅសល់កុដិធំតែមួយប៉ុណ្ណោះ។ រីឯព្រះពុទ្ធរូបវិញក៏គ្មាននៅសេសសល់ដែរ។ នៅវត្តអន្ទង់វៀនក្នុងខេត្តក្រចេះ ពីមុនជាវត្តសសរ១០០ដ៏ស្អាត មានព្រះពុទ្ធបដិមាករ១៤អង្គត្រូវបានកម្ទេច ហើយបោះចោលទៅក្នុងទន្លេ។ សាក្សីមួយរូបបាននិយាយថា ខណៈដែលចាប់ផ្តើមបំផ្លាញ ប្រហែលជាដប់ថ្ងៃព្រះវិហារត្រូវបានវាយខ្ទេចអស់។

[១១:៣៤:៣៨]

នៅក្នុងករណីនេះ ព្រះសង្ឃព្យាយាមប្រឆាំងនឹងការបំផ្លាញសាសនាឥតឈប់ឈរ ចៅអធិការវត្តដំណាក់ត្រយឹងក្នុងខេត្តកំពតទប់ទល់បានយូរដល់ទីបញ្ចប់។ សាក្សីមួយរូបបានរំឭកពីការដែលគាត់បានទៅសួរសុខទុក្ខព្រះសង្ឃ ហើយបានប្រាប់រំឭកដល់ព្រះអង្គថា អង្គការបាននិយាយថា ព្រះសង្ឃជាដង្កូវ និងជាឈ្លើងជញ្ជក់ឈាមរបស់ប្រជាជន។ ទោះជាមានការអង្វរពីសាក្សីរូបនេះក៏ដោយ ក៏ព្រះអង្គមិនចាកចេញពីវត្តដែរ។ ចៅអធិការអង្គនោះត្រូវបានពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាចាប់ខ្លួនហើយក្រោយមកគេមិនដែលបានឃើញព្រះអង្គនោះទៀតឡើយ។ សាក្សីទាំងឡាយបានបង្ហាញពីភាព

អស់សង្ឃឹមនៅពេលបានសួររំឭកឡើងវិញ ពីវិធីដែលគេបានធ្វើឲ្យពួកគាត់លះបង់ជំនឿសាសនាចោល នៅពេលបានសួរពីមូលហេតុដែលព្រះសង្ឃសឹក និងមូលហេតុដែលគាត់មិនប្រតិបត្តិតាមជំនឿរបស់ខ្លួន នៅក្នុងរបបនោះ សាក្សីមួយរូបបាននិយាយថា ដោយសារគេអស់ជំនឿ គេមិនអនុញ្ញាតឲ្យមានសាសនា គ្មាននរណាហ៊ានតវ៉ា ខ្លាចគេហៅទៅណែនាំ ទៅកសាង អត់ហ៊ានទេ សូម្បីតែអុជធូបនៅផ្ទះក៏អត់ហ៊ានដែរ។ ការធ្វើទុក្ខបុកម្នេញទៅលើអ្នកកាន់ព្រះពុទ្ធសាសនា គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប៉ះពាល់ដល់ប្រជាជនកម្ពុជារាប់លាននាក់ ក្នុងរយៈកាលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

នៅក្នុងការប៉ុនប៉ងជាប្រព័ន្ធ ដើម្បីបំបាត់សាសនា ក្រុមមេដឹកនាំខ្មែរក្រហមបានបង្កឲ្យមានការស្លាប់អ្នកកាន់ព្រះពុទ្ធសាសនារាប់មិនអស់ ហើយបានដាក់ប្រជាជនទាំងមូលឲ្យស្ថិតនៅក្រោមការប៉ះទង្គិចខាងផ្លូវកាយ និងខាងផ្លូវចិត្ត។ សូម្បីតែសព្វថ្ងៃនេះសម័យខ្មៅងងឹត និងច្របូកច្របល់ទាំងនេះ នៅតែថិតនៅក្នុងចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាទាំងអស់ នៅក្នុងប្រទេសកម្ពុជានៅឡើយ ហើយរហូតដល់សព្វថ្ងៃ ជាច្រើននាក់បានទទួលរងនូវការប៉ះទង្គិចខាងផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ដែលពួកគាត់ធ្លាប់បានជួបដែលជាលទ្ធផលនៃគំនាបហិង្សាទៅលើព្រះពុទ្ធសាសនា។

[១១:៣៦:៥៤]

អាពាហ៍ពិពាហ៍ដោយបង្ខំ៖

ឥឡូវនេះខ្ញុំសូមបកស្រាយអំពីឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តនៅក្នុងបរិបទនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ។ ដូចខ្ញុំបានរៀបរាប់ខាងដើមរួចមកហើយ បក្សកុម្មុយនីស្តកម្ពុជាបានរិះរកលុបបំបាត់នូវរាល់សំណល់វប្បធម៌ទាំងអស់ ដែលបានផ្តល់អត្ថន័យដល់ជីវិតរស់នៅនៃសង្គមកម្ពុជារាប់សតវត្សរ៍មកហើយ។ នេះមានរួមទាំងការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍រវាងយុវជន និងយុវនារីជាច្រើនម៉ឺននាក់នៅទូទាំងប្រទេស នៅក្រោមគោលនយោបាយមួយដែលអនុម័តដោយគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ គោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំបានភ្ជាប់ទៅនឹងការបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស និងការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈជាទ្រង់ទ្រាយធំ។ ជនរងគ្រោះដោយអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានដកហូតនូវមោទនភាព និងសេចក្តីថ្លៃថ្នូររបស់ខ្លួន ហើយបានទទួលរងនូវការប៉ះទង្គិចខាងផ្លូវចិត្ត និងខាងផ្លូវកាយធ្ងន់ធ្ងរ។

[១១:៣៨:០៤]

អាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាផ្នែកមួយដែលភ្ជាប់ទៅនឹងគោលនយោបាយរបស់បក្សកុម្មុយ-

នីស្តកម្ពុជាស្តីពីការធ្វើឲ្យទៅជាទាសករ វាត្រូវបានបង្កើតឡើងដើម្បីបង្កើនយ៉ាងឆាប់រហ័សចំនួនប្រជាជនក្នុងប្រទេស។ សាក្សីមួយរូបបានរំឭកពីការប្រជុំមួយនៅក្នុងឆ្នាំ១៩៧៨ នៅក្នុងខេត្តកំពង់ឆ្នាំង ដែលប៉ុល ពត បានណែនាំពួកថ្នាក់ក្រោមឲ្យរៀបចំអាពាហ៍ពិពាហ៍សម្រាប់ប្រជាជន ដើម្បីឲ្យរបបនេះអាចធានាថា នឹងមានប្រជាជនកើនឡើងពីម្ភៃទៅសាមសិបលាននាក់។ នួន ជា ធ្លាប់បានថ្លែងថា បក្សកុម្មុយ-នីស្តកម្ពុជាពិនិត្យជាថ្មីឡើងវិញ នូវផែនការបួនឆ្នាំស្តីពីការបង្កើនប្រជាជនកម្ពុជា ក៏ប៉ុន្តែអាពាហ៍ពិពាហ៍ដោយបង្ខំក៏ត្រូវបានបង្កើតឡើង ដើម្បីទប់ទល់នឹងអំណាចនៃសង្គមប្រពៃណីកម្ពុជាផងដែរ គឺសង្គមគ្រួសារ។ ដូចដែល អេលីហ្សាប៊េត បេកយ័រ បានសរសេរថា ជីវិតគ្រួសារត្រូវតែបំបាត់ចោល បើចង់រស់រដ្ឋត្រូវតែដណ្តើមកាន់កាប់អំណាចគ្រួសារ គ្រួសារមានអំណាចខ្លាំងបំផុតទៅលើគ្រប់-- ទាក់ទងទាំងអស់ទៅក្នុងសង្គមដូចវាគួរឲ្យខ្លាចបំផុត។ ខណៈដែលមានការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីកម្ពុជា និងពិធីអាពាហ៍ពិពាហ៍ធ្លាប់តែជាកិច្ចការសាំញ៉ាំពាក់ព័ន្ធទៅនឹងគ្រប់សមាជិកគ្រួសារទាំងអស់ បក្សកុម្មុយនីស្តកម្ពុជាបានកាត់បន្ថយអាពាហ៍ពិពាហ៍ឲ្យមកនៅត្រឹមតែការចាប់គូដោយបង្ខំ ដ៏ក្រៀមក្រោះជាប្រព័ន្ធ ដែលអនុវត្តដោយអង្គការ។ ណាហ្គា វ៉ាកា កាស៊ូមី ដែលបានធ្វើការស្រាវជ្រាវទូលំទូលាយស្តីពីការអនុវត្តទាំងឡាយ ក្នុងការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមរបបបក្សកុម្មុយនីស្តកម្ពុជា បានរៀបរាប់ដូចខាងក្រោម។

[១១:៤០:០០]

ដំណើរការរៀបអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម គឺខុសគ្នាទាំងស្រុង ពីរបៀបទំនៀមទម្លាប់ខ្មែរ ដែលកូនកំលោះត្រូវសូមការយល់ព្រមពីឪពុកម្តាយកូនក្រមុំ។ ពិធីរៀបអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ខ្មែរ មានរយៈពេលបីថ្ងៃ រួមមានពិធីផ្សេងៗជាច្រើន ដែលសាច់ញាតិ និងអ្នកភូមិទាំងអស់ចូលរួមនៅក្នុងពិធីទាំងនោះ ដើម្បីជូនពរជ័យដល់គូស្វាមីភរិយារៀបអាពាហ៍ពិពាហ៍ថ្មី។

ផ្ទុយទៅវិញ ទំនៀមទម្លាប់នេះក្នុងរបបខ្មែរក្រហមតាមរយៈប្រធានភូមិ មេកងនារី អង្គការបានបញ្ជាទៅជននោះថា អ្នកឯងត្រូវរៀបការ។ ជាញឹកញាប់ វិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពាក់ព័ន្ធទៅនឹងក្រុមយុវជន និងយុវនារី ជួនកាលមានរហូតដល់ទៅរាប់រយនាក់ត្រូវបានរៀបអាពាហ៍ពិពាហ៍នៅក្នុងវិធីតែមួយ។ ជាញឹកញាប់ គូស្រករពុំធ្លាប់ដែលបានជួបគ្នាទេ ឬស្គាល់គ្នាទៅវិញទៅមកតែបន្តិចបន្តួចប៉ុណ្ណោះ។

[១១:៤១:០២]

វិធីរៀបអាពាហ៍ពិពាហ៍នេះត្រូវបានពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាធ្វើជាអធិបតី ហើយបានភ្ជាប់ទៅនឹងការប្តេជ្ញាចិត្តចំពោះរបបនោះ។ បុរសម្នាក់បានរំឭកឡើងវិញពីការចាប់ផ្សំគូដោយអំពើចិត្ត នៅពេលវិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់គាត់ថា គេរៀបជាគូៗតាមលេខរៀង ដោយគេរៀបខាងស្រីម្ខាង ហើយខាងប្រុសម្ខាង ហើយគេបានបិទភ្លើង ហើយគេឲ្យបុរស និងនារីដើរសំដៅរកគ្នា ហើយចាប់ដៃគូរៀងៗខ្លួន។ ក្នុងវិធីនោះមាន១១៧គូ យើងមិនអាចរត់គេចបានទេ ដោយមានទាហានជាច្រើនយាមនៅជុំវិញកន្លែងនោះ។

សាក្សីមួយរូបទៀត ដែលជាលេខាតំបន់ បានធ្វើជាអធិបតីនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានរំឭកឡើងវិញពីសេចក្តីណែនាំពីថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាថា ខ្ញុំធ្លាប់ធ្វើជាអ្នកផ្គូផ្គងប្រុស និងស្រី ហើយប្រុសត្រូវតែមានអាយុពីរទៅបីឆ្នាំចាស់ជាងស្រី។ បុរសពីក្រុមថ្មីត្រូវផ្គុំជាមួយនឹងស្ត្រីមកពីប្រជាជនថ្មី ហើយប្រជាជនមូលដ្ឋាន ត្រូវផ្គុំជាមួយនឹងប្រជាជនមូលដ្ឋាន។ នេះគឺជានយោបាយរបស់ខ្មែរក្រហម ដែលថានៅពេលមនុស្សដល់អាយុរៀបការត្រូវតែរៀបការ។

[១១:៤២:២៨]

នៅក្នុងការដាក់ឲ្យអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំ អាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជាបានដកហូតការពាក់ព័ន្ធជាមូលដ្ឋានខាងអារម្មណ៍ និងសេចក្តីស្នេហាផ្ទាល់ខ្លួនចេញ ហើយចំពោះយើងម្នាក់ៗជាកត្តាយ៉ាងសំខាន់នៅក្នុងការជ្រើសរើសដៃគូប្រចាំជីវិតរបស់យើង។ ការដាក់ឲ្យអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាតំណាងឲ្យវិធីម្យ៉ាងទៀត ដែលរបបនោះបានបំបាត់សាសនាផងដែរ។

ព្រះសង្ឃព្រះពុទ្ធសាសនាត្រូវបានបង្ខំឲ្យបោះបង់ចោលនូវភាពនៅលីវរបស់ខ្លួន ហើយបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងស្ត្រីដែលជាអ្នកគោរពព្រះពុទ្ធសាសនាដែរ។ ចាមមូស្លីម ត្រូវបានគេប្រាប់ឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកដែលមិនមែនជាចាមមូស្លីម។ ដាច់ខាតមិនមានការគិតគូរពីការឈឺចាប់និងទុក្ខលំបាកទេ។ អំពើបែបនេះបង្កឲ្យមានការប៉ះពាល់ជំនឿផ្លូវចិត្តរបស់បុគ្គលម្នាក់ៗ។ សាក្សីជាច្រើននឹងផ្តល់សក្ខីកម្មថា នៅក្នុងករណីមួយភាគធំ គឺមានភាគីម្ខាង ឬមួយក៏ភាគីសងខាងមិនបានព្រមព្រៀងទៅនឹងអាពាហ៍ពិពាហ៍របបនោះទេ។

[១១:៤៣:៤៥]

យ៉ាងណាក៏ដោយជនរងគ្រោះមិនមានជំទាស់ទេ ព្រោះខ្លាចគេដាក់វិន័យនៅពេលក្រោយ គឺអ្វីដែលសាក្សីមួយរូបបានរំឭកឡើងវិញអំពីវិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំថា ពេលរៀបការបុរសមិន

យំទេ ប៉ុន្តែផ្ទែកនារីវិញពួកគេយំយ៉ាងខ្លាំង នៅក្នុងចិត្តរបស់ពួកគេព្រោះពួកគេមិនហ៊ានយំឲ្យគេឮ បុរសស្ត្រីដែលត្រូវរៀបការនោះ ពួកគេមិនខ្វល់ចំពោះរឿងដែលថា ពួកគេស្រឡាញ់គ្នា ឬក៏អត់នោះទេ គឺគ្រាន់តែបារម្ភអំពីជីវិតរបស់គេប៉ុណ្ណោះ។

សាក្សីស្ត្រីមួយរូប ដែលធ្លាប់បានព្យាយាមជំទាស់ចំនួនបីដងទៅនឹងអាពាហ៍ពិពាហ៍ ដែលមានបញ្ហាដោយប្រធានកងរបស់គាត់ ត្រូវបានគេប្រាប់យ៉ាងម៉ឺងម៉ាត់ថា ពេលនោះគេថាបើមិត្តឯងមិនព្រមគឺគេធ្វើទៅតាមមិនព្រម។ អារម្មណ៍របស់គាត់នឹកគិតទៅដល់ព្រឹត្តិការណ៍មួយ ដែលមាននារីម្នាក់ត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ចោល ដោយសារតែការប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍ ដោយទប់ទល់លែងរួច គាត់សុខចិត្តរៀបអាពាហ៍ពិពាហ៍តាមអង្គការបញ្ជាទៅ។

[១១:៤៥:០០]

ពេលខ្លះដោយបានដឹងថា អាពាហ៍ពិពាហ៍ដោយបង្ខំបានខិតជិតមកដល់ហើយនោះ ជននោះអាចសុំរៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកដែលខ្លួនស្គាល់បាន។ អ្នកដែលមានសំណាងតិចតួចណាស់ដែលមានលទ្ធភាពអាចរៀបអាពាហ៍ពិពាហ៍បាននៅក្នុងកាលៈទេសៈយល់ព្រមគ្នា។ យ៉ាងណាក៏ដោយភស្តុតាងក៏បានបង្ហាញផងដែរថា មានតួយ៉ាងជាច្រើនដែលជានារីត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិដូចជារបស់ជយភណ្ឌផ្តល់ជារង្វាន់ដល់ពួកយោធារបស់អង្គការ។ អតីតយោធាមួយរូបនៅក្នុងរបបនោះ បានរំឭកឡើងវិញថា រឿងល្អមួយរបស់ខ្មែរក្រហមគឺថា បើគេចង់រៀបការជាមួយនរណាម្នាក់ គេអាចស្នើរឿងនេះទៅអង្គការបាន ហើយបើនារីមិនព្រមទេ អង្គការនឹងបង្ខំនារីនោះ។ នៅក្នុងករណីជាច្រើនពួកនារីៗត្រូវបានគេឲ្យធ្វើជារង្វាន់ដល់ពួកយោធាពិការដែលត្រូវរបួសនៅក្នុងការប្រយុទ្ធគ្នា។ មាននារីម្នាក់បានរំឭកឡើងវិញពីប្តីរបស់គាត់ដែលបានបាត់ជើងម្ខាង ហើយអាចជ្រើសរើសប្រពន្ធបាន។ អង្គការផ្តល់សិទ្ធិឲ្យបុរសដើម្បីជ្រើសរើសប្រពន្ធ ហើយបុរសនោះស្នើទៅអង្គការថា គាត់ចង់រៀបការជាមួយនឹងខ្ញុំ។

[១១:៤៦:១៩]

បន្ទាប់ពីពិធីអាពាហ៍ពិពាហ៍ដោយបង្ខំពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាឲ្យមានសកម្មភាពទាក់ទងគ្នា ដើម្បីធានាថាមានការរួមដំណេកនឹងគ្នា។ ដោយចៀសមិនរួចការរំលោភសេពសន្ថវៈនៅក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងជាញឹកញាប់។ ដូចដែលសាក្សីមួយរូបបានពន្យល់ថា ប្រធានឃុំបានបញ្ជាឲ្យគាត់ដេកជាមួយនឹងប្តីរបស់គាត់បីថ្ងៃបន្ទាប់ពីអាពាហ៍ពិពាហ៍។ ខ្ញុំខ្លាច

ប្តីរបស់ខ្ញុំណាស់ ប៉ុន្តែមានពួកឈ្លបនៅលបស្តាប់នៅក្រោមផ្ទះ។ ខ្ញុំមិនចង់រួមដំណេកជាមួយប្តីរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំត្រូវតែបង្ខំចិត្ត។ ជនរងគ្រោះមួយរូបដែលគេបានសម្ភាសនៅក្នុងអំឡុងពេលធ្វើការស្រាវជ្រាវរបស់ ណាហ្គា វ៉ាកា កាស៊ូមី បានរៀបរាប់អ្វីដែលគាត់បានកើតឡើង បន្ទាប់ពីគាត់បានប្រកែក មិនយល់ព្រមសម្រុងនឹងគ្នាអស់រយៈពេលចំនួនបីយប់ថា អង្គការបានសុំប្តីខ្ញុំទៅរៀនសូត្រ ហើយគេព្រមានគាត់ថា បើនៅតែមិនរួមដំណេកទៀត ពួកគេសម្លាប់ពួកយើងចោល។ ពេលគាត់ត្រឡប់មកវិញគាត់ប្រាប់ខ្ញុំអំពីរឿងនេះ ហើយគាត់បញ្ចុះបញ្ចូលខ្ញុំឲ្យរួមដំណេកជាមួយគាត់ បើខ្ញុំមិនព្រមរួមដំណេកជាមួយគាត់ទេ ខ្ញុំមុខជាត្រូវស្លាប់ហើយ។

[១១:៤៧:៤៣]

ជនរងគ្រោះមួយរូបទៀត បានរៀបរាប់ពីការដែលគេបង្ខំឲ្យគាត់រួមភេទជាមួយនឹងប្តីថ្មីរបស់គាត់ដូចតទៅ៖ ពេលដែលខ្ញុំប្រកែកមិនព្រមរួមដំណេកជាមួយគាត់ក្រោយពេលរៀបការ គាត់បានរាយការណ៍រឿងនេះទៅកម្មាភិបាល ហើយគេយកមកចាប់ខ្ញុំ ហើយក្រោយមកនៅក្នុងផ្ទះនោះគេបានបង្ខំខ្ញុំឲ្យដោះសម្លៀកបំពាក់ដើម្បីឲ្យបុរសនោះចាប់រំលោភខ្ញុំ។ គេបាននិយាយថា បើខ្ញុំមិនព្រមទេនោះ គេនឹងសម្លាប់ខ្ញុំចោល។ សេចក្តីខ្មាសអៀន និងការឈឺចាប់ដែលជនរងគ្រោះបានជួបប្រទះ គឺហួសពីការស្មានរបស់យើង។

ជនរងគ្រោះមួយទៀត ដែលបានសម្ភាសជាមួយនឹង ណាហ្គា វ៉ាកា កាស៊ូមី បានរៀបរាប់ដែលគាត់បានជួបប្រទះដូចតទៅ៖

បន្ទាប់ពីពិធីនោះមក ពួកយោធាបានមកពិនិត្យពួកយើងដើម្បីឲ្យប្រាកដថាពួកយើងបានស្រឡាញ់គ្នា ហើយរួមដំណេកជាមួយគ្នា។ ខ្ញុំបានឃើញពួកគាត់តាមប្រហោងជញ្ជាំងផ្ទះរបស់ខ្ញុំ។ ជាផ្នែកមួយនៃគោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ មានការតតបវិញយ៉ាងឃោរឃៅចំពោះជនដែលបានងាកចេញពីសេចក្តីណែនាំរបស់របបនោះ។ គូដែលមានទំនាក់ទំនងមនោសញ្ចេតនាដោយគ្មានការអនុញ្ញាតត្រូវបានគេដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ។

[១១:៤៩:០៨]

យើងដាក់ជូននៅចំពោះមុខលោកប្រធាន លោក លោកស្រីចៅក្រមនូវរឿងរ៉ាវជាច្រើនអំពីការដាក់អ្នកដែលត្រូវគេចោទថា ខុសសីលធម៌នៅក្នុងមន្ទីរសន្តិសុខនានា។ នៅក្នុងអត្ថបទដែលមានចំណងជើងថា “កូនសៀវភៅក្រហមរបស់ ប៉ុល ពត” លោក ហង់រី ឡូកា បញ្ជាក់អំពីរបៀបដែលកម្មាភិបាល

របស់បក្សកុម្មុយនីស្តកម្ពុជា បានអនុវត្តគោលនយោបាយនេះថា មានករណីជាច្រើនជាការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង និងការសម្លាប់ចោល ដោយសារតែរឿងផិតក្បត់រវាងមនុស្សពេញវ័យ ដែលបានព្រមព្រៀងគ្នា រួមមានដៃគូដែលស្រលាញ់គ្នាខ្លាំង ប៉ុន្តែអង្គការមិនអនុញ្ញាតឲ្យរៀបការ។

[១១:៤៩:៥៣]

លោកប្រធាន លោក លោកស្រីចៅក្រម ភស្តុតាងបង្ហាញជាប្រព័ន្ធនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ដែលបានដាក់អនុវត្តដោយជនជាប់ចោទ បានភ្ជាប់ទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈ ការធ្វើទារុណកម្ម ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត ជាទ្រង់ទ្រាយធំ។ ឧក្រិដ្ឋកម្មទាំងនេះ បំផ្លិចបំផ្លាញដល់សង្គមកម្ពុជា ខណៈដែលប្រពៃណី និងទំនៀមទម្លាប់បានចាក់ឫសយ៉ាងជ្រៅនៅក្នុងជីវិតគ្រួសារ។ តាមវិធីជាច្រើនយ៉ាង អាពាហ៍ពិពាហ៍ដោយបង្ខំនាំឲ្យមានការធ្លាក់ចុះទាំងស្រុងនៃសង្គម និងវប្បធម៌កម្ពុជា ពីព្រោះវាបានបំបែង និងបំផ្លាញនូវអ្វីជាស្នូលសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប គឺគ្រួសារ។

ឥឡូវនេះ ខ្ញុំសូមនិយាយពីទិដ្ឋភាពសង្ខេបនៃឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិសុខនានា។

[១១:៥០:៥៤]

មន្ទីរសន្តិសុខ ដូចដែលសហការីអន្តរជាតិរបស់ខ្ញុំ នឹងធ្វើការបង្ហាញជូនដូច្នេះដែរ ជាច្រើនឆ្នាំមុននឹងចូលត្រួតត្រាប្រទេស។

ក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាធ្លាប់បានធ្វើការដោះស្រាយដោយប្រើអំពើហិង្សា ធ្វើជាឧបករណ៍ដើម្បីសម្រេចបាននូវគោលបំណងនយោបាយរបស់ខ្លួន ការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់ពួកដែលគេសន្មតថាជាខ្មាំង គឺជាបទដ្ឋានអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីមុនខែមេសា ឆ្នាំ១៩៧៥ មកម្ល៉េះ។ ក្រោយពេលកាន់អំណាចភ្លាម បក្សកុម្មុយនីស្តកម្ពុជាបានពង្រាតរចនាសម្ព័ន្ធសន្តិសុខរបស់ខ្លួនទៅដល់គ្រប់ជ្រុងជ្រោយនៃប្រទេស។ មន្ទីរសន្តិសុខនានា ត្រូវបានបង្កើតឡើងនៅតាមភូមិភាគនីមួយៗ តំបន់នីមួយៗ នៅតាមស្រុកនីមួយៗ ក៏ដូចជានៅតាមកងពលយោធានានាដែរ។ ភស្តុតាងបានបញ្ជាក់ថា មានមន្ទីរបែបនេះចំនួនជាង២០០កន្លែង។ មន្ទីរសន្តិសុខ១១កន្លែងបានដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺស-២១ នៅភ្នំពេញ កោះខ្យង នៅខេត្តព្រះសីហនុសព្វថ្ងៃនេះ ព្រៃដំរីស្រុត នៅខេត្តកំពង់ឆ្នាំង ក្រាំងតាចាន់ នៅខេត្តតាកែវ សង់ នៅខេត្តកណ្ដាល គោកក្ដួច

នៅខេត្តក្រចេះ ភ្នំក្រោល នៅខេត្តមណ្ឌលគិរី វត្តធ្លក នៅខេត្តស្វាយរៀង អូរកន្សែង នៅខេត្តរតនគិរី វត្តគិរីរម្យ នៅខេត្តបាត់ដំបងនៅសព្វថ្ងៃនេះ និងមន្ទីរសន្តិសុខភូមិភាគឧត្តរនៅខេត្តសៀមរាប។ ដូចទីតាំងការដ្ឋានពលកម្មដោយបង្ខំដែរ ភស្តុតាងនឹងបង្ហាញពីភាពជាប់ពាក់ព័ន្ធគួរឲ្យកត់សម្គាល់នៅក្នុងរចនាសម្ព័ន្ធ និងប្រតិបត្តិការណ៍នៃមន្ទីរសន្តិសុខទាំងនោះ។ នេះបញ្ជាក់ឲ្យឃើញពីអង្គហេតុពិតដែលជាមន្ទីរសន្តិសុខទាំងនោះ បានដំណើរការប្រព្រឹត្តទៅតាមរបៀបជារចនាសម្ព័ន្ធដែលមានការត្រួតត្រាពិនិត្យពីមជ្ឈិមបក្ស។ ចាប់តាំងពីឆ្នាំ១៩៧៥ រចនាសម្ព័ន្ធសន្តិសុខត្រូវបានគេដាក់ទិសជាបឋម សំដៅចំពោះពួកអតីតមន្ត្រីផ្លូវការ និងពួកទាហានរបបសាធារណរដ្ឋខ្មែរ ពួកសត្រូវវណ្ណៈ និងពួកដែលគេមិនបានធ្វើតាមបញ្ជារបស់បក្ស។ យ៉ាងណាក៏ដោយ បន្ទាប់ពីឆ្នាំ១៩៧៦ គេបានដាក់បញ្ចូលពួកខ្មាំងមួយប្រភេទថ្មីទៀត។

[១១:៥៣:៣២]

ជនជាប់ចោទបាននឹងស្រមៃដល់គំនិតដែលថា ការត្រួតត្រារបស់ពួកខ្លួនបានធ្វើឲ្យរលំរលាយពីខាងក្នុង ហើយបានបញ្ជាឲ្យមានចលនាបោសសម្អាតផ្ទៃក្នុង ដើម្បីធ្វើការស្វែងរក និងកម្ទេចពួកដែលគេបានសន្មតថាជា សេអ៊ីអា កាហ្សេបេ និងពួកចារកម្មវៀតណាមដែលត្រូវបានគេសន្មត ឬពិតមែនក៏ដោយ ក៏នៅក្នុងភាសារបស់បក្សកុម្មុយនីស្តកម្ពុជា គេត្រូវបានរកឃើញ និងបោសសម្អាតពួកខ្មាំង ដូចដែលលោក ដេវីដ ឆេនដ៍ល័រ ជាប្រវត្តិវិទូមួយរូបបានបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ "សំលេងពីមន្ទីរស-២១" ថាខ្មាំងប្រឆាំងបដិវត្តន៍ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ហើយចាំបាច់ត្រូវមានការបោសសម្អាតជាបន្តបន្ទាប់ ដើម្បីធានាសុវត្ថិភាពមជ្ឈិមបក្ស ហើយរក្សាភាពបរិសុទ្ធ និងកម្លាំងចលកររបស់បក្សបដិវត្តន៍។ គេគិតថា ជាខ្មាំងមាននៅគ្រប់ទីកន្លែង។ អេលីហ្សាប៊ែត បេកយ័រ ផ្តល់ជាការវិភាគស្រដៀងគ្នាមួយ ស្តីពីការវិវឌ្ឍន៍នៃការបោសសម្អាតរបស់បក្សកុម្មុយនីស្តកម្ពុជាថា ទំនោរនយោបាយនៅក្នុងបក្ស ឬការផ្លាស់ប្តូរនៅក្នុងទ្រឹស្តីបដិវត្តន៍បានបង្កើតពួកខ្មាំងប្រភេទថ្មី។

[១១:៥៤:៥០]

ការភ័យខ្លាចពីសត្រូវវណ្ណៈត្រូវបានជំនួសដោយការភ័យខ្លាច សមាសភាពខ្មាំងដែលបានជ្រាបចូលនៅក្នុងបក្ស។ ជនរងគ្រោះដោយប្រព័ន្ធនៃមន្ទីរសន្តិសុខនេះ ក៏បានរាប់បញ្ចូលនូវក្រុមផ្សេងៗទៀតផងដែរ។ ដូចដែលខ្ញុំនឹងរាប់ពិស្តារនៅពេលក្រោយទៀត។

ចាប់តាំងពីឆ្នាំ១៩៧៧ ប្រជាជននៃជាតិពន្ធុវៀតណាមនិងចាម ត្រូវបានស្វែងរកសម្លាប់ជាប្រព័ន្ធ

មន្ទីរសន្តិសុខនៅពាសពេញកន្លែងក្នុងប្រទេស។ លើសពីនេះទៀត ពួកដែលគេសង្ស័យថា មិនមានសីលធម៌ដូចដែលបានកំណត់និយមន័យដោយរបបនេះ គឺត្រូវស្ថិតនៅក្រោមការឃុំឃាំង និងសម្លាប់ផងដែរ។ ចុងបញ្ចប់ ដូចដែលខ្ញុំនឹងជម្រាបនៅពេលក្រោយ គឺមានជនរងគ្រោះជាច្រើនត្រូវបានចាប់ខ្លួន ហើយដាក់ក្នុងឃុំឃាំងទៅតាមទីតាំងការដ្ឋានពលកម្មដោយបង្ខំ ដោយសារការចោទប្រកាន់កំប៉ិកកំប៉ុក ដូចជាការមិនបានយកចិត្តទុកដាក់ធ្វើការងារ ការធ្វើឲ្យខូចខាតគ្រឿងឧបករណ៍ មិនខំប្រឹងធ្វើការ មានជំងឺ ឬលួចអាហារជាដើម។

នៅក្រោមការណែនាំរបស់ជនជាប់ចោទនោះ ពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាជាបានសម្លឹងមើលការប្រព្រឹត្តកន្លងមកនេះ ដែលគ្មានន័យអ្វីសោះនោះថាជាភស្តុតាងនៃអំពើប្រឆាំងនឹងបក្ស។ ភស្តុតាងដែលយើងនឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងបង្ហាញពីភាពជាក់ស្តែងនៃការហេតុផលនានា ដែលនាំឲ្យមានការចាប់ខ្លួនជនរងគ្រោះស្លូតត្រង់រាប់មិនអស់។ ដើម្បីប្រើប្រាស់ជាភស្តុតាង មានសាក្សីមួយរូបបានផ្តល់សក្ខីកម្មថា គាត់ធ្លាប់ជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខវត្តគោកក្តួច ហើយគេសួរចម្លើយគាត់ ពីព្រោះមានអ្នករាយការណ៍ថា គាត់ចូលចិត្តចបកាប់ស្វៀត ដែលជាអំពើមួយប្រឆាំងនឹងអង្គការ។

[១១:៥៦:៤៥]

នៅក្នុងសៀវភៅរបស់គាត់ សំឡេងស-២១ ដេវីដ ឆេនដ័ល័រ បានសរសេរឧទាហរណ៍បន្ថែមអំពីបាតុភូតនេះថា ពួកអ្នកទោសដែលបានចូលរួមនៅក្នុងការបង្កបង្កើនផល បានសារភាពថា បានធ្វើឲ្យខូចម៉ាស៊ីន ទឹកលិច ដុត លួច ដកដំឡូង ធ្វើឲ្យពិការ សម្លាប់ និងធ្វើឲ្យបាត់សត្វពាហនៈ ព្រមទាំងកាប់ដើមឈើហូបផ្លែស្រេចតែចិត្ត។ ពួកកម្មករបានសារភាពថា បានធ្វើឲ្យខូចម៉ាស៊ីន លួចសម្ភារៈ ផលិតទំនិញខុស និងមានផែនការក្បត់ជាមួយកម្មករដូចគ្នា ដើម្បីបំផ្លាញផលិតផលដោយចេតនា។

[១១:៥៧:៣២]

អតីតកម្មាភិបាលមួយរូប ដែលបានចូលរួមនៅក្នុងការប្រជុំមួយ ដែល តាម៉ុក លេខាភូមិភាគនិរតីធ្វើជាគណៈអធិបតីបានសង្ខេបពីភាពមិនសមហេតុផល នៃគោលនយោបាយសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជាថា ប៉ុន្តែបញ្ហាដែលខ្ញុំយល់ គឺបញ្ហាតិចតួចក៏គេចាត់ទុកថា សេ.អ៊ី.អា បើមនុស្សរាប់ម៉ឺនរាប់សែននាក់ តើអាមេរិកាំងមានលុយឯណាបើកប្រាក់ខែឲ្យទៅ។ វាមិនជាបញ្ហាទេដែលថា ភាគច្រើននៃពួកដែលត្រូវបានចាប់ខ្លួន មិនមានជាការគំរាមកំហែងដល់ការត្រួតត្រាផ្តាច់ការរបស់បក្សកុម្មុយនីស្ត

កម្ពុជានោះទេ។ វាមិនជាបញ្ហាទេដែលថា ភាគច្រើននៃករណីទាំងនេះ ជនរងគ្រោះជាជនស្លូតត្រង់ កំហុសដែលគេបានសន្មតថា ជាការប្រឆាំងនឹងអង្គការ។ ការក្លាយខ្លួនជាជនរងគ្រោះ ដោយរចនាសម្ព័ន្ធនៃមន្ទីរសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា។ វាគ្រប់គ្រាន់ល្មមហើយ ដែលគ្រាន់តែត្រូវបានគេឆ្លើយដាក់ថាមានការពាក់ព័ន្ធ។

[១១:៥៨:៤០]

ឧក្រិដ្ឋកម្មនានាត្រូវបានបង្កើតឡើង ដោយពិរុទ្ធភាពត្រូវបានបញ្ជាក់តាមរយៈការធ្វើទារុណកម្ម និងការសួរចម្លើយ។ មានមនុស្សជាច្រើននាក់ត្រូវបានចាប់ខ្លួន និងឃុំឃាំងដោយគ្រាន់តែពួកគេជាប់ទាក់ទងទៅនឹងបុគ្គលដែលគេបានកំណត់អត្តសញ្ញាណថា ជាខ្មាំងម្នាក់ប៉ុណ្ណោះ។ ដូច្នេះស្ត្រី និងក្មេងៗត្រូវបានដាក់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខជាច្រើនរួមមាន ស-២១ ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្ដួច វត្តធ្លក និងមន្ទីរសន្តិសុខភូមិភាគឧត្តរ។ មន្ទីរសន្តិសុខទាំងនោះ មានរៀបចំផាសិប្បករយ៉ាងត្រឹមត្រូវ ដែលមានទីតាំងនៅនឹងកន្លែង ដែលមានការយាមកាមយ៉ាងតឹងរ៉ឹង ដោយមានអ្នកយាម២៤ម៉ោងក្នុងមួយថ្ងៃ។

[១១:៥៩:៣៥]

ភារកិច្ចស្នូលរបស់ពួកគេ គឺធ្វើការឃុំឃាំង និងសួរចម្លើយពួកដែលគេសង្ស័យថាជាខ្មាំង។ ឈ្លេចយកចម្លើយសារភាព រាយការណ៍ពីសេចក្ដីសារភាពទៅរដ្ឋអំណាចបក្សកុម្មុយនីស្តកម្ពុជា និងបន្ទាប់មកទៀតសម្លាប់ពួកអ្នកទោសទាំងនោះចោល។ មានមន្ទីរសន្តិសុខមួយចំនួន ដូចជាកោះខ្សងភ្នំក្រោល និងគោកក្ដួច ជាដើម ក៏មានកន្លែងអប់រំកែប្រែសម្រាប់អ្នកទោសទាំងឡាយណា ដែលវាសនាចុងក្រោយរបស់ខ្លួនមិនទាន់ត្រូវបានសម្រេច ត្រូវបញ្ជូនទៅលត់ដំធ្វើពលកម្មដោយបង្ខំ។ ខណៈដែលចំនួនអ្នកទោសមានការប្រែប្រួល សូម្បីតែមន្ទីរសន្តិសុខតូចបំផុត ក៏អាចដាក់អ្នកទោសបានរាប់រយនាក់ដែរ។ ធំបំផុតគឺ ស-២១ ដែលអាចដាក់អ្នកទោសបានពី២.០០០នាក់ ទៅ៣.០០០នាក់ និងមន្ទីរសន្តិសុខភូមិភាគឧត្តរ នៅពេលនោះអាចដាក់បានជាង៥០០នាក់។

[១២:០០:៣៥]

មន្ទីរសន្តិសុខបានធ្វើប្រតិបត្តិការតាមកម្រិតខុសៗគ្នានៃឋានានុក្រមតំបន់ និងឃោធារបស់បក្សកុម្មុយនីស្តកម្ពុជា។ ឧទាហរណ៍ ព្រៃដំរីស្រុត គោកក្ដួច វត្តធ្លក ជាគុកកម្រិតស្រុក។ ភ្នំក្រោល និងកោះខ្សង ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លេខាតំបន់។ មន្ទីរសន្តិសុខភូមិភាគឧត្តរ រាយការណ៍ផ្ទាល់

ទៅថ្នាក់ដឹកនាំភូមិភាគឧត្តរ។ អូរកន្សែង ដំណើរការប្រព្រឹត្តទៅតាមកម្រិតកងពល នៅក្រោមកងពល ៨០១។ ស-២១ នៅក្រោមរដ្ឋអំណាចផ្ទាល់របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។

យ៉ាងណាក៏ដោយ--

**ប្រធានអង្គជំនុំ៖**

សូម-- ឥឡូវនេះដល់ពេលសមល្មមនឹងឈប់សម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ដោយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់បី និងសាមសិបនាទី សូមអញ្ជើញចូលវិញ។ ដូច្នេះសូមអញ្ជើញភាគី បុគ្គល និងសាធារណជនអញ្ជើញចូលមកកាន់ទីកន្លែងរៀងៗខ្លួនឲ្យបានមុខម៉ោងដប់បី និងសាមសិបនាទី នៅរសៀលនេះជាកំណត់ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងដប់បី និងសាមសិបនាទី ជាកំហិត។

[១២:០២:០៨]

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២នាទី ដល់ម៉ោង ១៣:៣៣នាទី)*

[១៣:៣៣:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធី។

ជាបន្តនេះ សូមអញ្ជើញលោកជំទាវសហព្រះរាជអាជ្ញាជាតិ ឡើងបន្តធ្វើការបង្ហាញនូវបទចោទប្រកាន់ដោយសង្ខេប។ សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

សូមអនុញ្ញាតបន្តទៅទៀត។

យ៉ាងណាក៏ដោយភស្តុតាងនឹងបង្ហាញថា មន្ទីរសន្តិសុខនីមួយៗបានធ្វើប្រតិបត្តិការក្រោមបញ្ជារបស់រដ្ឋអំណាចបក្សកុម្មុយនីស្តកម្ពុជា ហើយចុងក្រោយអាចនឹងឆ្លើយទៅនឹងមជ្ឈិមបក្សកុម្មុយនីស្ត

កម្ពុជាបាន។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមទាំងជនជាប់ចោទផង ត្រូវបានគេប្រាប់ដំណឹងថា ប្រចាំអំពីអត្តសញ្ញាណកម្ម និងការចាប់ខ្លួនពួកខ្មាំង តាមរយៈការដាក់ជូនរបាយការណ៍ជាទៀងទាត់ ពីភូមិភាគ ពីតំបន់ ឬពីប្រធានយោធា។ នៅក្នុងករណីជាច្រើនថ្នាក់ដឹករបស់បក្សកុម្មុយនីស្តកម្ពុជាបាន ចូលរួមដោយផ្ទាល់នៅក្នុងការបោសសម្អាត ដែលបានធ្វើឡើងនៅតាមមន្ទីរសន្តិសុខនានា។ ឧទាហរណ៍ មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា បានបញ្ជូនចម្លើយសារភាពរបស់ពួកយោធានៅកងពល៩២០ នៅ មន្ទីរស-២១ ទៅឲ្យតំបន់១០៥ដើម្បីចាប់ខ្លួនពួកក្បត់ដែលគេឆ្លើយដាក់ថា មានការពាក់ព័ន្ធយកទៅឃុំ ខ្លួននៅមន្ទីរសន្តិសុខភ្នំក្រោល។ ស្រដៀងគ្នានេះដែរ លេខាកងពល៨០១ ដែលមើលការខុសត្រូវមន្ទីរ សន្តិសុខអូរកន្សែង បានទទួលចម្លើយសារភាពដែលមានចារពីភ្នំពេញ ដោយមានបញ្ជាក់ឈ្មោះយោធា កងពល៨០១ ដែលគេបានឆ្លើយដាក់ បន្ទាប់មកគេក៏បានណែនាំកម្មាភិបាលទទួលខុសត្រូវអូរកន្សែងឲ្យ ចាប់ខ្លួន និងសួរចម្លើយពួកដែលមានឈ្មោះទាំងនោះ។

ភស្តុតាងដែលយើងនឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះ នឹងបង្ហាញពីការសួរចម្លើយក្នុងកម្រិត ខ្ពស់មួយនៅក្នុងរចនាសម្ព័ន្ធសន្តិសុខនេះ។ ឧទាហរណ៍ ក្នុងអំឡុងពេលនៃការបោសសម្អាតកងពល ៩២០ មានយោធាជាង៤០០នាក់ត្រូវបានចាប់ឃុំខ្លួន នៅភ្នំក្រោលមុននឹងបញ្ជូនទៅកាន់ស-២១។ មន្ទីរ សន្តិសុខភូមិភាគឧត្តរបានទទួលពួកដែលគេចោទពីកំហុសធ្ងន់ធ្ងរ មកពីមន្ទីរសន្តិសុខតូចៗនៅទូទាំង ភូមិភាគឧត្តរ។

[១៣:៣៦:២៩]

អាស្រ័យទៅតាមតំបន់ និងការដាក់ទីតាំងមន្ទីរសន្តិសុខ ការបញ្ជាឲ្យចាប់ខ្លួនចេញមកពីលេខា ភូមិភាគ តំបន់ ឬស្រុក ចេញមកពីមេបញ្ជាការយោធា ឬចេញមកពីប្រធានឃុំ និងសហករណ៍។ ការ ចាប់ខ្លួនត្រូវបានធ្វើឡើងដោយកងសន្តិសុខផ្សេងៗ រួមមានកងឈ្លបស្រុក និងឃុំ ឬអង្គភាពយោធា។ ពួកអ្នកទោសត្រូវបានគេនាំយកទៅកាន់មន្ទីរសន្តិសុខនានាជាក្រុមៗ ហើយបន្ទាប់មកត្រូវបានគេចាត់ ការនិងចុះក្នុងបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ។ គេអាចបរិយាយបានថា លក្ខខណ្ឌដែលបានឃុំពួក អ្នកទោសគឺមានលក្ខណៈគួរឲ្យរន្ធត់ ជនរងគ្រោះត្រូវបានគេធ្វើឲ្យលែងមានភាពថ្លៃថ្នូរដូចជាមនុស្ស ទៀតហើយ ពួកគាត់ត្រូវបានគេដាក់ក្នុងបន្ទប់ងងឹត ឬចងភ្ជាប់គ្នាក្នុងបន្ទប់ឃុំខ្លួន ដែលកខ្វក់ និង ចង្អៀត។

មន្ទីរសន្តិសុខភូមិភាគឧត្តរ អ្នកទោសជាង១០០នាក់បានរស់នៅដេកពួនស៊ីចុក និងបន្ទោរបង់នៅ

ក្នុងបន្ទប់តែមួយ។ នៅមន្ទីរសន្តិសុខសង់ មានអ្នកទោសខ្លះត្រូវបានគេឃុំខ្លួនទាំងអាក្រាតកាយនៅក្នុងបន្ទប់ ដែលបន្ទប់នីមួយៗមានទំហំតែមួយម៉ែត្រការេប៉ុណ្ណោះ។ ខ្នោះជារបស់ទូទៅធម្មតាប៉ុណ្ណោះ ដែលប្រើសម្រាប់ឃុំខ្លួន ដែលប្រើការពារកុំឲ្យអ្នកទោសរត់ ឬទៅណាមកណាដោយគ្មានការអនុញ្ញាត។ ពួកអ្នកទោសត្រូវបានគេចងភ្ជាប់ជាមួយប្រមាណជា៣០នាក់ ជាទូទៅអ្នកទោសកំហុសស្រាលនៅពេលថ្ងៃគេមិនដាក់ខ្នោះទេ ដើម្បីទុកឲ្យធ្វើការងារពលកម្មដោយបង្ខំ។ អ្នកមានកំហុសធ្ងន់គេនៅតែដាក់ខ្នោះគ្រប់ពេលវេលាទាំងអស់។

[១៣:៣៨:២១]

អ្នកទោសទាំងនោះពេលទទួលទានអាហារ ពេលដេក ឬសូម្បីតែពេលបត់ជើងក៏ពិបាកនឹងរើខ្លួនដែរ។ លក្ខខណ្ឌអនាម័យគួរឲ្យខ្ពើម នៅតាមមន្ទីរសន្តិសុខមួយចំនួន រួមមាន ស-២១ ក្រាំងតាចាន់ អូរកន្សែង និងមន្ទីរសន្តិសុខភូមិភាគឧត្តរ។ ពួកអ្នកទោសត្រូវបានគេបង្ខំឲ្យបន្ទោរបង់តូចធំចូលនៅក្នុងប្រដាប់សម្រាប់ដាក់ ដូចជា ម្ជុកដែក កែសគ្រាប់ ប៊ីដុងសាំង និងត្រឡោកដូង។ ប្រដាប់សម្រាប់ដាក់ទាំងនេះ ដាក់នៅក្នុងបន្ទប់ដដែល ឬត្រូវបានចាក់ចូលនៅក្នុងឡាំងនៅចុងជួរនីមួយៗ។ នៅក្នុងករណីខ្លះអ្នកទោសត្រូវបានគេបង្ខំឲ្យទទួលទានអាហារនៅក្នុងម្ជុកដែកដដែលដែលគាត់បានបន្ទោរបង់ដាក់។ សាក្សីមួយរូបមកពីមន្ទីរសន្តិសុខកោះខ្យង រៀបរាប់ពីការដែលគាត់បានឃើញអ្នកទោសជាប់ខ្នោះដៃ និងខ្នោះជើង ដេកលើភក់ដែលមានលាមក និងទឹកនោមលាយឡំនៅក្នុងទីនោះដែរ។

គេបានទុកពួកអ្នកទោសឲ្យនៅរស់ ដោយផ្តល់របបហូបចុកបន្តិចបន្តួច ដែលជាទូទៅមានតែបបររាវៗ យូរៗទៅរាងកាយទ្រុឌទ្រោម។ ដោយទទួលរងនូវការអត់ឃ្លានយ៉ាងខ្លាំងនោះ អ្នកខ្លះក៏បែរទៅជាអស់សង្ឃឹម។ សាក្សីមួយរូបបានរៀបរាប់ពីរបៀប ដែលអ្នកទោម្នាក់នៅមន្ទីរសន្តិសុខអូរកន្សែងប្រើកំណាត់ឫស្សីអារសាច់អ្នកទោសម្នាក់ទៀត ដែលបានស្លាប់ដោយសារការអត់ឃ្លាន ហើយយកមកស៊ី។

[១៣:៤០:០២]

ការថែរក្សាផ្នែកវេជ្ជសាស្ត្រជាទូទៅត្រូវបានគេប្រើសម្រាប់តែរក្សាទុកឲ្យអ្នកទោសនៅរស់ដើម្បីសួរចម្លើយបន្តតែប៉ុណ្ណោះ។ នៅមន្ទីរសន្តិសុខខ្លះដូចជាព្រៃដំរីស្រុត និងមន្ទីរសន្តិសុខភូមិភាគឧត្តរ ការថែរក្សាផ្នែកវេជ្ជសាស្ត្រមានសម្រាប់តែបុគ្គលិកគុកនិងអ្នកយាមតែប៉ុណ្ណោះ។ នៅស-២១ ពួកអ្នកទោសបានក្លាយទៅជាជនរងគ្រោះដោយសារការពិសោធន៍វេជ្ជសាស្ត្រផ្សេងៗ ហើយគេបានបូមយក

ឈាមដោយបង្ខំពីអ្នកទោសរាប់រយនាក់ ដើម្បីយកទៅព្យាបាលយុទ្ធជនដែលត្រូវរបួស។ អតីតប្រធានអង្គភាពសួរចម្លើយម្នាក់នៅស-២១ បានរំឭកឡើងវិញពីការដែលគាត់បានឃើញរថយន្តមួយដឹកអ្នកទោស ដែលចុះខ្សោយដោយសារការបូមយកឈាម។ គាត់បានថ្លែងថា អ្នកទោសហ្នឹងលែងដឹងខ្លួនហើយ នៅដង្ហើមតិកៗ បូមហើយដកទុយោ ហើយយកអ្នកទោសទៅគរទុកមួយម្ដុំ។

[១៣:៤១:០៧]

ចំពោះអ្នកទោសដែលត្រូវធ្វើពលកម្មដោយបង្ខំវិញ៖ ការងារចាប់ផ្តើមពីម៉ោង៣យប់ហើយបញ្ចប់នៅពាក់កណ្តាលអធ្រាត្រ។ ពួកដែលត្រូវធ្វើពលកម្មដោយបង្ខំនៅព្រៃដំរីស្រុតរួមមានកុមារផង។ ការងារត្រូវតែបំពេញដោយស្ងៀមស្ងាត់ ហើយអ្នកទោសត្រូវបានគេដាក់ទណ្ឌកម្ម បើមិនធ្វើការឲ្យខ្លាំងទេ។ សាក្សីមួយរូបនៅមន្ទីរសន្តិសុខគោកក្ដួចបានផ្ដល់សក្ខីកម្មដូចតទៅ៖ “តែបើខកខានមិនបានធ្វើការ គេច្រៀកដកចេញមកជ្រុង ហើយបើខកមួយថ្ងៃទៀត ត្រូវគេដកមួយជ្រុងទៀត មានន័យថាអស់ពាក់កណ្តាលនៃរបបអាហារមួយពេល”។

ការដាក់ទណ្ឌកម្មចំពោះការមិនធ្វើការខ្លាំងរួមមាន៖ ការទះដោយដៃ ការធ្វើទារុណកម្ម និងការសម្លាប់។ អ្នកនៅរស់រានមានជីវិតម្នាក់ពីមន្ទីរសន្តិសុខវត្តធ្លក បានផ្តល់សក្ខីកម្មថាពួកដែលមិនបានធ្វើការខ្លាំងត្រូវបានគេវាយទះ ហើយជួនកាលត្រូវគេកប់ទាំងរស់។

[១៣:៤២:១៤]

លោកប្រធាន លោក លោកស្រីចៅក្រម នឹងបានដឹងពីព្រឹត្តិការណ៍ឃោរឃៅដែលពួកអ្នកទោសត្រូវទទួលរង។ សាក្សីមួយរូបដែលបានផ្តល់សក្ខីកម្មអំពីលក្ខខណ្ឌនៅមន្ទីរសន្តិសុខសង់ បានរៀបរាប់ពីការដែលខ្លួនបានឃើញពួកយោធាវាយធ្វើបាបយុវជនម្នាក់នឹងដែកភ្លៅរទេះរហូតដល់ស្លាប់។ ដោយសារតែយុវជននោះបានរើសកន្ទុយបារីពីដី ហើយបម្រុងនឹងជក់។

នៅមន្ទីរសន្តិសុខភូមិភាគឧត្តរ កូនស្រីរបស់អ្នកទោសពីររូបដែលមានអាយុបីឆ្នាំ ត្រូវបានគេវាយធ្វើបាបព្រោះតែវាស្រែកយំរកម្តាយរបស់វា។ កុមារីនោះធ្លាក់ខ្លួនឈឺហើយក្រោយមកក៏ស្លាប់ទៅ។ អ្នកនៅរស់រានមានជីវិតម្នាក់ពីមន្ទីរសន្តិសុខភូមិភាគឧត្តរ បានរៀបរាប់ពីរបៀបដែលពួកអ្នកយាមបានយកអ្នកទោសម្នាក់មកធ្វើជាគំរូ ដែលប៉ុនប៉ងលួចរត់។ អ្នកទោសនោះត្រូវបានគេធ្វើទារុណកម្ម និងវាយដំនៅចំពោះមុខអ្នកទោសដទៃទៀត។ ពួកអ្នកយាមបានបោះដែកគោលនៅលើជើងរបស់គាត់ទាំងពីរជាប់នឹងក្តារ លាតសន្ធឹងដៃ ហើយបញ្ជាឲ្យគាត់ឲ្យច្រៀង។ នៅពេលដែលគាត់ច្រៀង ពួកអ្នកយាម

បានបន្តវាយធ្វើបាបគាត់ទៀត។

[១៣:៤៣:៣៣]

អតីតអ្នកទោសម្នាក់នៅមន្ទីរសន្តិសុខភ្នំក្រោល បានរំឭកឡើងវិញពីការវាយតប់ទៅលើអ្នកទោសមួយរូបដែលត្រូវបានគេចោទថាប៉ុនប៉ងលួចរត់ទៅស្រុកយួនថា "ពេលនោះពួកវាចាប់ផ្តើមវាយអ្នកទោសរហូតដល់សន្លប់ ដោយបែកឈាមខ្ទាតប្រឡាក់មកលើខ្ញុំ និងអ្នកទោសផ្សេងៗទៀត។ បន្ទាប់មកពួកវាបានដោះខ្នោះអូសចេញ ហើយចាក់នឹងជំពុះទង់សម្លាប់នៅក្នុងគុកនោះ។"

លោកប្រធាន លោក លោកស្រីចៅក្រម នឹងបានដឹងពីរឿងរ៉ាវមួយអំពីរបៀបដែលអ្នកទោសស្ត្រីម្នាក់នៅមន្ទីរសន្តិសុខអូរកន្សែង ត្រូវបានគេពុះខ្នង ហើយបន្ទាប់មកត្រូវគេខ្វះយកថង់ប្រមាត់ចេញនៅក្នុងរោងបាយ ដើម្បីធ្វើឲ្យអ្នកទោសដទៃទៀតខ្លាច។ នៅគ្រប់មន្ទីរសន្តិសុខទាំងអស់ ពួកអ្នកទោសស្ថិតនៅក្រោមការធ្វើទារុណកម្មគួរឲ្យរន្ធត់ ដែលជាផ្នែកមួយនៃការសួរចម្លើយ ធ្វើឡើងដើម្បីទាញយកចម្លើយសារភាព។ រឿងរ៉ាវដែលគេធ្លាប់បានជួប ដូចជាការសួរចម្លើយ ការធ្វើទារុណកម្មនៅតាមមន្ទីរសន្តិសុខផ្សេងៗ មើលមួយភ្លែតទៅគួរឲ្យភ័យខ្លាច និងឈឺចាប់ពីការដែលគេធ្វើឲ្យពួកអ្នកទោសមានការភ័យខ្លាច។ ទម្រង់ជាទូទៅនៃការធ្វើទារុណកម្ម គឺជាការវាយធក់ តប់ ឆក់ខ្សែភ្លើង និងធ្វើឲ្យថប់ដង្ហើម។ អតីតអ្នកទោសស្ត្រីម្នាក់ដែលគេឃុំនៅមន្ទីរសន្តិសុខសង់ អស់រយៈពេលប្រហែលជាប្រាំបួនខែបានរៀបរាប់ពីការវាយធ្វើបាបនៅក្នុងអំឡុងពេលសួរចម្លើយដូចតទៅ៖

[១៣:៤៥:១៣]

ពួកគេសួរចម្លើយអ្នកទោសរៀងរាល់ថ្ងៃ ចំពោះអ្នកទោសបុរសវិញ ប្រសិនបើគេមិនឆ្លើយសំណួរក្នុងពេលសួរចម្លើយទេ ខ្មែរក្រហមនឹងវាយពួកគេរហូតដល់ស្លាប់។ នៅស-២១ ពួកអ្នកសួរចម្លើយបានប្រើបច្ចេកទេសសួរចម្លើយគ្រប់បែបយ៉ាង ពួកគេជ្រមុជអ្នកទោសចូលទៅក្នុងទឹក អុជនឹងបារី នឹងអំពូលអគ្គិសនី ដកក្រចកដៃក្រចកជើងផងដែរ។ ពួកគេបានប្រើដង្កាប់ចាប់ហែកសាច់អ្នកទោសបង្ខំអ្នកទោសឲ្យវាយគ្នា បង្ខំឲ្យស៊ីអាចម៍ ឲ្យផឹកទឹកនោម និងបង្ខំអ្នកទោសឲ្យធ្វើការគោរពវត្ថុផ្សេងៗឬរូបសត្វឆ្កែ។

ភស្តុតាងដែលយើងនឹងដាក់នៅចំពោះមុខលោកប្រធាន លោកលោកស្រីចៅក្រមរួមមានឯកសារកាលពីជំនាន់នោះដែលបានកត់ត្រានូវសេចក្តីពិស្តារដែលគួរឲ្យខ្លាចនៃការប្រើប្រាស់នៃអំពើទារុណកម្មដ៏ឃោរឃៅ និងជាប្រព័ន្ធនេះ។ របាយការណ៍នៅស-២១ ដែលបានរៀបរាប់ដោយកម្មាភិបាលទទួល

ខុសត្រូវចំពោះការសួរចម្លើយអ្នកទោស កែ គឹមហួត ដែលជាអតីតកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាបានថ្លែងថា "នៅព្រឹកថ្ងៃទី២០ ខែ៧ ឆ្នាំ១៩៧៧ យើងខ្ញុំបុកមួយសាទៀត ម្តងនេះវាប្រតិកម្មថា ជាពាក្យសម្តីថាវាអត់ក្បត់។ អាណាឆ្លើយដាក់គឺសុទ្ធតែពួកក្បត់ ជាសុខភាពគ្រាន់តែខ្សោយតែពុំមានអីគួរឲ្យកត់សម្គាល់ទេ។ ល្ងាចយប់ថ្ងៃទី២១ ខែ៧ ឆ្នាំ១៩៧៧ បុកមួយសាទៀត ឆក់ខ្សែភ្លើងនិងឲ្យស៊ីអាចម៍ លើកនេះវាជេរអ្នកវាយជាច្រើន "ពួកឯងវាយអញឲ្យងាប់មក!" ឲ្យស៊ីអាចម៍ពីរបីស្លាបព្រា ហើយវាសួររក អានឹង អានូវ អាសាន អារញ្ញ ដល់ពេលយប់យើងបុកខ្សែភ្លើងមួយសាទៀត លើកនេះធូរន់បន្តិច វាចេញវេរីវាយ អត់អីទេ ក្រោយមកសារភាពមួយកម្រិតដូចខាងលើ។"

នៅក្រាំងតាចាន់ វិធីធ្វើទារុណកម្មរួមមាន៖ ការវាយធ្វើបាបដោយរំពាត់ខ្សែតី ឬរំពាត់ផ្តៅចងព្យួរជើងឡើងលើ ប្រើដង្កៀបកៀបច្រមុះ ឬដកក្រចក និងច្រកថង់ផ្លាស្ទិកឲ្យអ្នកទោសថប់ដង្ហើម។ ជាញឹកញាប់ អ្នកទោសបានស្លាប់ដោយសារការធ្វើទារុណកម្ម។ សាក្សីម្នាក់បានរៀបរាប់ពីការធ្វើទារុណកម្មទៅលើស្ត្រីបីនាក់នៅមន្ទីរសន្តិសុខថា "គេឲ្យដោះអាវ ហើយយកដង្កាប់មកគាបច្រមុះ ស្លឹកត្រចៀក ហើយយកទឹកអាស៊ីតមកក្រវាត់ ហើយចាក់ទឹក អូសចេញទៅត្រាំ ទៅទាំងស្រាត គេវះយកថ្លើមទៅឆា។

[១៣:៤៨:១៣]

ដូចដែលខ្ញុំបានបញ្ជាក់នៅខាងដើមរួចមកហើយថា ចម្លើយសារភាពត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណខ្មាំងបន្ថែមទៀត។ ជាឧទាហរណ៍នៅមន្ទីរសន្តិសុខសង់ ចម្លើយសារភាពត្រូវបានប្រធានពិនិត្យជាថ្មីឡើងវិញ ហើយបន្ទាប់មកវិធាននោះបានរៀបចំជាសំណុំរឿងនូវជនទាំងឡាយដែលត្រូវបានគេឆ្លើយដាក់ថាមានការជាប់ពាក់ព័ន្ធ។ ប្រធានឲ្យគេយកចម្លើយសារភាពទាំងនោះទៅឲ្យសហករណ៍ឃុំ កងចល័ត និងមន្ទីរសន្តិសុខផ្សេងៗទៀត។ ក្រោយមក មានការចាប់ខ្លួនជាបន្តបន្ទាប់ ទៀតនៅគោកក្តួចចំណាររបស់អ្នកសួរចម្លើយ និងចម្លើយសារភាពត្រូវបានគេបញ្ជូនទៅកាន់មន្ទីរស្រុកហើយនៅក្នុងករណីពិសេស បញ្ជូនទៅកាន់មន្ទីរតំបន់ ប្រធាននៅគោកក្តួចបានចូលរួមប្រជុំប្រចាំខែនៅមន្ទីរស្រុកជាមួយនឹងប្រធានសហករណ៍ និងប្រធានកងទទួលបន្ទុកផ្នែកសន្តិសុខ។ មន្ទីរសន្តិសុខក៏បានបញ្ជូនរបាយការណ៍ប្រចាំខែឲ្យទៅមន្ទីរស្រុកផងដែរ។ ថ្នាក់ដឹកនាំស្រុកនានាបានចូលរួមប្រជុំមួយខែ ពីរខែនៅមន្ទីរតំបន់ដែលពួកគាត់បានរាយការណ៍ពីបញ្ហានានាដូចជា៖ បញ្ហាម្ហូបអាហារ និងបញ្ហាសន្តិសុខជាដើម ហើយបានទទួលបញ្ជាមកវិញអំពីមកថា តើអ្នកណាត្រូវកម្ទេច អ្នកណាត្រូវទុក ការធ្វើទារុណកម្ម

ការអត់ឃ្លាន កង្វះខាតការថែទាំផ្នែកវេជ្ជសាស្ត្រ និងការដាក់នៅក្នុងមន្ទីរឃុំឃាំនៅក្នុងលក្ខខណ្ឌដែលមិនមានអនាម័យល្អបណ្តាលឲ្យមានការស្លាប់ជាច្រើននៅក្នុងមន្ទីរសន្តិសុខទាំងនេះ។

[១៣:៥០:០០]

ដូច្នេះមានមនុស្សស្លាប់អស់ជាច្រើន សូម្បីតាំងពីមុនពេលដែលជនរងគ្រោះត្រូវបានគេយកចេញទៅសម្លាប់ទៀត។ នៅមានករណីអ្នកទោសធ្វើអត្តឃាតជាច្រើនអ្នកផងដែរ ក្នុងការដែលពួកគាត់អស់សង្ឃឹមនឹងរត់គេចចេញឲ្យផុតពីទុក្ខលំបាកក្នុងចិត្ត ពីការដាក់ក្នុងមន្ទីរឃុំឃាំង និងពីការធ្វើទារុណកម្មនេះ។ នៅស-២១ សូម្បីតែអ្នកយាមក៏បានធ្វើអត្តឃាតផងដែរ ព្រោះខ្លាចគេចាប់ និងធ្វើទារុណកម្ម។ នៅអូរកន្សែងមានអ្នកទោសជាច្រើនអ្នកបានសម្លាប់ខ្លួនដោយចងក។ នៅសង់ ខោអាវត្រូវបានគេយកចេញពីអ្នកទោស ដើម្បីការពារកុំអ្នកទោសយកមកធ្វើអត្តឃាត។ អ្នកទោសភាគីច្រើនដែលមិនបានស្លាប់ដោយសារការអត់ឃ្លាន ជំងឺ ធ្វើការហួសកម្លាំង ឬការធ្វើទារុណកម្មទេនោះ ក្រោយមកត្រូវបានគេយកទៅសម្លាប់ចោល។

ជាតួយ៉ាងទីតាំងជាក់លាក់ដែលនៅឆ្ងាយពីបរិវេណធំ ត្រូវបានគេប្រើប្រាស់សម្រាប់ជាកន្លែងសម្រាប់សម្លាប់មនុស្ស និងជាកន្លែងកប់សាកសពរួម។ ការសម្លាប់ គឺមានការរៀបចំយ៉ាងត្រឹមត្រូវតាមវិធីសាស្ត្រ ហើយជាទូទៅគឺច្រើនកើតនៅពេលយប់ជាញឹកញាប់បំផុត។ ពួកអ្នកទោសត្រូវបានគេរុំមុខហើយចងភ្ជាប់គ្នា បន្ទាប់មកដាក់ក្នុងឡានធំៗ ហើយដឹកចេញទៅជាក្រុម។ ទោះបីជាការសម្លាប់ត្រូវបានគេធ្វើឡើងដោយសម្ងាត់បំផុតក៏ដោយ ក៏ភស្តុតាងនៃព្រឹត្តិការណ៍ដ៏រន្ធត់នេះត្រូវបានបន្សល់ទុកនៅឡើយ។

[១៣:៥១:៤៤]

លោកប្រធាន លោក លោកស្រីចៅក្រមនឹងបានស្តាប់នូវរឿងរ៉ាវជាច្រើនអំពីរបៀបកម្មាភិបាលបានសម្រេចលើពួកដែលគេបានសន្មតថា ជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ របៀបសម្លាប់ គឺមានលក្ខណៈស្ទើរតែដូចគ្នា នៅឯកន្លែងសម្លាប់ ពួកអ្នកទោសត្រូវបានគេបញ្ជាឲ្យអង្គុយ បំពង់ករបស់ពួកត្រូវបានអារកាត់ផ្តាច់ ឬមួយក៏អ្នកទោសត្រូវបានគេវាយត្រង់កញ្ចឹងកនឹងរបស់ធ្ងន់ៗ ដូចជា កំណាត់ឈើ ឬដែកគ្នៀរទេះ។ សាកសពត្រូវបានគេកប់នៅក្នុងរណ្តៅដែលមិនបានគូសសម្គាល់ ដែលជាច្រើនលើករណីជនរងគ្រោះខ្លួនឯងត្រូវបានគេបង្ខំឲ្យជីករណ្តៅ។ សាក្សីម្នាក់បានរៀបរាប់ពីការសម្លាប់អ្នកទោសមកពីមន្ទីរសន្តិសុខក្រាំងតាចាន់ថា៖ ឧបករណ៍ដែលគេប្រើសម្រាប់សម្លាប់អ្នកទោស គឺប្រើចប

ដែលមានដងប្រវែងប្រហែលមួយម៉ែត្រ វាយពីក្រោយកញ្ចឹងក។ ពេលអ្នកទោសដួលហើយគេយកដាវអារផ្តាច់កតែម្តង។ សាក្សីម្នាក់មកពីមន្ទីរសន្តិសុខសង់ បានរៀបរាប់ពីការសម្លាប់ដូចតទៅ៖ គេវាយនឹងភ្លៅរទេះ ដែលមានប្រវែងប្រហែលជិតមួយម៉ែត្រ រួចវាយចំកញ្ចឹងក ហើយចាប់បោចសក់ងើយកឡើង និងចាក់ផ្តាច់បំពង់កដោយចំពុះទុង រួចវះពោះចាប់ពីចុងដង្ហើមរហូតដល់ក្រោម ទើបស្រាយពីចំណងហើយបោះចូលទៅក្នុងរណ្តៅ។

[១៣:៥៣:២៣]

លោកប្រធាន លោក លោកស្រីចៅក្រម នឹងបានស្តាប់នូវអ្វីដែលជនរងគ្រោះដែលគ្មានអ្វីទីពឹងដូចជាកូនក្មេងត្រូវបានគេសម្លាប់ចោលទាំងឈាមត្រជាក់ដែរ។ ក្មេងៗជាទូទៅត្រូវបានគេបោកក្បាលវានឹងគល់ឈើ។ សាក្សីម្នាក់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ បានរៀបរាប់ពីការធ្វើឃាតលើរូបកូនក្មេងស្រីពីរនាក់ នៅក្រោយពេលដែលឪពុកម្តាយរបស់វាត្រូវបានគេសម្លាប់ថា៖ ក្មេងស្រីទាំងពីរនេះបងអាយុប្រហែលជាបីឆ្នាំ ត្រូវឈ្មោះ សាំង ជា អ្នកវាយសម្លាប់។ ឯប្អូនស្រីដែលមានឈ្មោះប្រហែលពីរឆ្នាំ ឌុចតូច បានចាប់ជើងទាំងពីរ ហើយបោកក្បាលទៅនឹងគល់អម្ពិល។

[១៣:៥៤:០៨]

សាក្សីម្នាក់ផ្សេងទៀតមកពីមន្ទីរសន្តិសុខសង់ បានរំឭកឡើងវិញពីអ្វីដែលគាត់បានឃើញនៅកន្លែងសម្លាប់មនុស្ស។ ខ្ញុំឃើញស្នាមឈាម និងខួរក្បាលក្មេងហ្នឹងនៅលើដើមឈើ ហើយនៅជុំវិញគល់ឈើ។ ខ្ញុំបានឃើញសាកសពកុមារនៅវាយប៉ាយនៅជិតដើមឈើ គឺដើមក្រសាំងនេះឯង។ កុមារនោះជាក្មេងទើបចេះដើរអាយុពីរទៅបីឆ្នាំ។

ថ្ងៃនេះគេមិនអាចកំណត់បានទេថា ជនរងគ្រោះមានចំនួនប៉ុន្មាននាក់ពិតប្រាកដ ដែលបានទទួលរងនូវការឈឺចាប់ និងបានស្លាប់នៅឯមន្ទីរសន្តិសុខទាំង១១កន្លែងនេះ។ យ៉ាងណាក៏ដោយសក្ខីកម្ម និងភស្តុតាងជារូបវ័ន្តបានបញ្ជាក់ថា មានការស្លាប់រហូតដល់រាប់ម៉ឺននាក់ឯណោះ។

[១៣:៥៤:៥៧]

ជាឧទាហរណ៍ វាទំនងជាមានការស្លាប់ជាង១៥.០០០នាក់នៅ ស-២១ ចំនួនសាកសពដែលបានរកឃើញមកពីកន្លែងកប់សាកសពរួមនានានៅក្រាំងតាចាន់ អាចនឹងមានច្រើនរហូតដល់ទៅ១៧.០០០នាក់។ ការគាស់ទីតាំងរណ្តៅ សាកសពនានាធ្លាប់បានប្រើប្រាស់ដោយមន្ទីរសន្តិសុខ ភូមិភាគឧត្តរ មានសាកសពប្រមាណជា ៦.០០០នាក់ សំណល់សាកសពចំនួនរាប់ពាន់ត្រូវបានគេគាស់ចេញនៅឯមន្ទីរ

សន្តិសុខសង់ ដូចជាការដែលពួកគាត់មានការភ័យរន្ធត់ដូច្នេះដែរ។ តួលេខដែលអាចរកបាននេះ គឺតំណាងឲ្យតែចំនួនសមាមាត្រមួយនៃចំនួនអ្នកស្លាប់។

[១៣:៥៥:៤៦]

អំពើប្រល័យពូជសាសន៍៖

ឥឡូវនេះខ្ញុំសូមបន្តទៅលើបទចោទស្តីពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាប់ចោទ ដែលបានកើតចេញពីយុទ្ធនាការបំបាត់ក្រុមជាតិពន្ធចាមនិងវៀតណាមនៅក្នុងប្រទេសកម្ពុជា។ ភស្តុតាងដែលយើងនឹងដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បង្ហាញពីជនជាតិចាម នៅក្នុងខេត្តកំពង់ចាម និងជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ដែលទទួលរងក្នុងការសម្លាប់រង្គាលជាប្រព័ន្ធបញ្ជាដោយគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមានចេតនាបំផ្លាញក្រុមទាំងពីរនេះចោល។

យើងនឹងដាក់ជូននៅចំពោះមុខលោកប្រធាន លោក លោកស្រីចៅក្រម នូវភស្តុតាងដែលបង្ហាញសក្ខីកម្មពីការបំផ្លាញដោយមានការរៀបចំជាប្រព័ន្ធទៅលើក្រុមទាំងពីរនេះ ក្រោមការបញ្ជារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ ភស្តុតាងនៃការបញ្ជាបំផ្លាញក្រុមទាំងពីររួមមាន៖ ទស្សនាវដ្ដីទង់បក្ស សុន្ទរ-កថារបស់ជនជាប់ចោទ សេចក្តីថ្លែងការណ៍ផ្លូវការរបស់រដ្ឋាភិបាល និងសារទូរលេខរាយការណ៍ពីបទល្មើសផ្ញើទៅគណៈមជ្ឈិម។

[១៣:៥៦:៥៦]

ជាបឋមខ្ញុំនឹងជូនសេចក្តីសង្ខេបនៃភស្តុតាងពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ចំពោះជនជាតិចាម។ អំពើប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាម ត្រូវបានចោទប្រកាន់ អំពើប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម ដែលបានប្រព្រឹត្តនៅឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ ជនជាតិចាម ជាបញ្ញាជននៃនគរចម្ប៉ាដែលបានរស់នៅជាច្រើនសតវត្សរ៍នៅលើទឹកដីកម្ពុជានាពេលបច្ចុប្បន្ននេះ។ តាំងពីពេលដំបូងពួកគេបានរស់នៅផ្តុំគ្នា ភាគច្រើនជាសហគមន៍នៅខេត្តកំពង់ចាម កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ មុនពេលបក្សកុម្មុយនីស្តឡើងកាន់អំណាច ជនជាតិចាមគោរពប្រតិបត្តិសាសនាឥស្លាម និយាយភាសារបស់ខ្លួន និងស្លៀកសម្លៀកបំពាក់ប្រពៃណីរបស់ខ្លួន ពួកគេបានកំណត់ថា ជាក្រុមជាតិពន្ធមួយដាច់ដោយឡែកដែលមានសាសនាផ្សេងគ្នា ហើយប្រជាជនខ្មែរភាគច្រើនក៏ធ្វើការកំណត់ដូច្នេះដែរ។

ដូចដែលខ្ញុំបានធ្វើការកត់សម្គាល់ពីខាងលើរបស់បក្សកុម្មុយនីស្តកម្ពុជា បានធ្វើការប្រកាសទទួលស្គាល់ជាសាធារណៈគ្រប់សាសនាទាំងអស់ ដោយធ្វើការប្រកាសតាមវិទ្យុថា ជនជាតិចាម គឺជាខ្មែរ

មូស្លីមដែលជាបងប្អូន។ បក្សព្យាយាមធ្វើការបង្ហាញនូវរូបភាពសង្គមមួយ ដែលជនជាតិភាគតិចមិនត្រូវបានគេរើសអើង យ៉ាងណាមិញការពិតដែលស្ដែងឡើង គឺវាផ្សេងទៅវិញ។ នៅក្នុងសន្និបាតបក្ស ខែឧសភា ឆ្នាំ១៩៧៥ ដែលសហការីរបស់ខ្ញុំនឹងរៀបរាប់នៅពេលក្រោយ ប៉ុល ពត និង នួន ជា បានបង្គាប់ទៅលេខាភូមិភាគតំបន់ ស្រុក និងអង្គភាពយោធានៅទូទាំងប្រទេសឲ្យលុបបំបាត់សាសនាទាំងអស់។ ជនជាតិចាមត្រូវបានគេបង្ខំឲ្យចិញ្ចឹមជ្រូក និងហូបសាច់ជ្រូក ដែលជាអំពើផ្ទុយនឹងជំនឿសាសនារបស់ពួកគេ អ្នកដែលបដិសេធត្រូវគេសម្លាប់។

[១៣:៥៨:៥៦]

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក៏ដាក់ផែនការធ្វើឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានជាតិពន្ធតែមួយ ការណ៍នេះនឹងនាំមកនូវបច្ច័យគ្រោះមហន្តរាយដល់ជនជាតិចាម ដូចដែលលោកស្រីអេលីហ្សាប៊ែត បេកយ័រ ពន្យល់។ គោលនយោបាយរបស់ខ្មែរក្រហម គឺដើម្បីបំបាត់ភាពផ្សេងគ្នានៃជាតិពន្ធ និងបង្កើតនូវជាតិសាសន៍ថ្មីមួយ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរបំផុតដល់ជនជាតិចាម។ ជនជាតិភាគតិចទាំងនេះ បានទទួលមហន្តរាយចំនួនពីរដង ដោយសារតែពូជសាសន៍បរទេស និងជំនឿសាសនាប្រតិកិរិយា។ នៅក្នុងតំបន់ត្រួតត្រារបស់ពួកគេ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្ដើមធ្វើការបំបែកសហគមន៍ជនជាតិចាម និងធ្វើការគាបសង្កត់សេរីភាព សាសនា និងសិទ្ធិស៊ីវិលតាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ។ នៅក្នុងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ ជនជាតិចាមសឹងតែទាំងអស់នៅក្នុងភូមិភាគនិរតីរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានប្ដូរទីលំនៅទៅភូមិភាគឧត្តរ។

[១៤:០០:០១]

លោក ប៊ែន ឃៀរនិន ដែលបានធ្វើការស្រាវជ្រាវលម្អិតអំពីការធ្វើទុក្ខបុកម្នេញរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើជនជាតិចាម បានធ្វើការកត់សម្គាល់លើឯកសារនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាជាមួយចុងខែកុម្ភៈ ឆ្នាំ១៩៧៤ ដែលត្រូវបានផ្សព្វផ្សាយនៅភូមិភាគឧត្តរ។ ឯកសារដែលមានចំណងជើងថា “សេចក្ដីសម្រេចទាក់ទងនឹងមាគ៌ាសហករណ៍បក្សក្នុងតំបន់៣១” លើកឡើងថាការដាក់បញ្ចូលជនជាតិចាមនៅក្នុងសហករណ៍ត្រូវពន្យារដោយសារតែ ការបំបែកក្រុមនេះគឺជាការចាំបាច់កុំឲ្យពួកវាផ្ដុំគ្នាច្រើនក្នុងតំបន់តែមួយ។ ជាការឆ្លើយតបទៅនឹងការធ្វើបុកម្នេញរបស់បក្សកុម្មុយនីស្តកម្ពុជា សហគមន៍ជនជាតិចាមបានប៉ះបោរនៅតាមតំបន់មួយចំនួន។ ការប៉ះបោរលើកទីមួយ កើតមាននៅក្នុងតំបន៣១ នៅចុងឆ្នាំ១៩៧៤ ការចាប់មេដឹកនាំជនជាតិចាម បណ្ដាលឲ្យមានការបះបោរនៅស្រុក

ក្រូចឆ្មារ ក្នុងខេត្តកំពង់ចាម។ នៅចុងឆ្នាំ១៩៧៤ ជនជាតិចាមដែលជាសមាជិកក្រុមខ្មែរក្រហម ក្នុងតំបន់២១ បានជួយបង្កើតក្រុមផ្តាច់ខ្លួនមួយឈ្មោះថា "ខ្មែរស" ហើយបានរត់ចូលព្រៃ។

សូមរង់ចាំមើល វហ្សូតដល់វីដេអូ!

*(ការបង្ហាញឯកសារជារូបភាពវីដេអូ ចាប់ពីម៉ោង ១៤:០១:៣៩ ដល់ ១៤:០៣:៤០)*

[១៤:០៣:៤០]

**លោកស្រី ជា លាង៖**

ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ មកការធ្វើទុកបុកម្នេញជាប្រព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា មកលើជនជាតិចាមរួមមានការហាមឃាត់ការគោរពប្រតិបត្តិសាសនាអ៊ីស្លាម និងភាសាចាម។ ការដុតបំផ្លាញគម្ពីរសាសនា ការបំផ្លាញព្រះវិហារ និងប្រែក្លាយព្រះវិហារទាំងនេះ សម្រាប់ការប្រើប្រាស់ដទៃទៀត និងការសម្លាប់មេដឹកនាំជនជាតិចាម។ ជនទាំងឡាយណាដែលបដិសេធមិនអនុវត្តតាមបញ្ជាឲ្យលះបង់សាសនារបស់ខ្លួន។ ស្ត្រីជនជាតិចាមត្រូវបានគេហាមឃាត់មិនឲ្យពាក់កន្សែងគ្របក្បាលតាមលក្ខណៈប្រពៃណីរបស់ខ្លួនឡើយ។ អ្នកដែលនិយាយភាសាចាមត្រូវបានគេសម្តុតគំរាមសម្លាប់។

ជាលទ្ធផលនៅឆ្នាំ១៩៧៩ កុមារជនជាតិចាមលែងចេះនិយាយភាសាចាមទៀតហើយ សាក្សីនានានឹងផ្តល់សក្ខីកម្មថា ជនជាតិចាមបានរស់នៅក្នុងភាពភ័យខ្លាចជាប្រចាំ ដោយសារតែការខកខានមិនគោរពតាមបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា នឹងត្រូវគេចាប់ខ្លួន ហើយសម្លាប់។

[១៤:០៤:៤៩]

ក្នុងចំណោមខ្មាំងរបស់ខ្លួន បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកជនជាតិចាមក្នុងប្រភេទពិសេសមួយ គឺគេចាត់ទុកជនជាតិចាម ជាប្រជាជនដែលទាបជាងប្រជាជន ១៧មេសា ទៅទៀត។

នៅចុងឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានបន្តបន្លាស់ទីសហគមន៍ជនជាតិចាមពីភូមិកំណើតរបស់ខ្លួន ហើយបំបែកឲ្យទៅតាមភូមិដែលជនជាតិខ្មែរភាគច្រើន។ យើងនឹងដាក់បង្ហាញនៅចំពោះមុខលោកប្រធាន លោក លោកស្រីចៅក្រម នូវភស្តុតាងដែលបង្ហាញថាជនជាតិចាមរាប់ពាន់ម៉ឺននាក់ត្រូវបានបញ្ជូនទៅភូមិភាគឧត្តរ និងពាយ័ព្យដែលជាផ្នែកមួយនៃនយោបាយបំបែកជនជាតិចាមមួយសែននាក់ដែលកំពុងរស់នៅក្នុងភូមិភាគបូព៌ា។ នៅខេត្តកំពង់ចាម ជាញឹកញាប់បុរសត្រូវបានបំបែកចេញពីស្ត្រី និងកុមារជនជាតិចាមត្រូវបានបញ្ជូនទៅតំបន់ផ្សេងដែលជាផ្នែកមួយនៃកងចល័ត។

នៅខែកញ្ញា ឆ្នាំ១៩៧៥ ដែលខែរ៉ាម៉ាដាន់ ការប៉ះបោររបស់ជនជាតិចាមប្រឆាំងនឹងបក្សកុម្មុយ

នីស្តកម្ពុជាកើតមានឡើងនៅភូមិកោះផល និងស្វាយឃ្លាំង ក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។

ការប៉ះបោរទាំងពីរនេះ ត្រូវបានកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាកម្ទេច ដូចដែលយើងនឹងឃើញនៅពេលក្រោយចាប់តាំងពីឆ្នាំ១៩៧៧មក។ ស្រុកក្រូចឆ្មារបានក្លាយជាមុខសញ្ញាចម្បងនៅក្នុងយុទ្ធនាការប្រល័យពូជសាសន៍របស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងជនជាតិចាម។ ចាប់តាំងពីឆ្នាំ១៩៧៧ មកបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តនូវយុទ្ធនាការរួមមួយ ដើម្បីបំផ្លាញជនជាតិចាមដែលនៅសេសសល់ក្នុងខេត្តកំពង់ចាម ដែលនៅពេលនោះ ស្ថិតនៅក្រោមភូមិភាគបូព៌ា និងភូមិភាគកណ្តាល។ ការអនុវត្តផែនការនេះត្រូវបានសម្របសម្រួលជាលក្ខណៈប្រព័ន្ធ ដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាជាន់ខ្ពស់ដែលអ្នករាយការណ៍ទៅគណៈមជ្ឈិមរួមមាន កែ ពក ដែលជាលេខាភូមិភាគកណ្តាល។ ការសម្លាប់រង្គាលត្រូវបានអនុវត្តដោយកងអន្តរាគមន៍ពិសេសរបស់គណៈមជ្ឈិម ដែលបានរាយការណ៍ដោយផ្ទាល់ទៅ សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិ។ លេខាតំបន់៤១ និងជាលេខារងភូមិភាគកណ្តាលមានតួនាទីសកម្មក្នុងការអនុវត្តផែនការនេះ។

[១៤:០៧:២០]

សាក្សីមួយរូបរៀបរាប់អង្គប្រជុំមួយ នៅស្រុកកងមាស ដែលនៅពេលប្រជុំនោះ លេខាតំបន់៤១ និងជាលេខារងភូមិភាគកណ្តាលបាននិយាយថា ជនជាតិចាមត្រូវតែប្រមូលផ្តុំ ហើយបញ្ជូនទៅមូលដ្ឋានរបស់ពួកគេ។ នៅក្នុងភាសារបស់បក្សកុម្មុយនីស្តកម្ពុជា “នេះ” មានន័យថា ជាការបញ្ជាឲ្យសម្លាប់ជនរងគ្រោះទាំងនោះ។ ដប់ថ្ងៃក្រោយពីប្រជុំ ជនជាតិចាមត្រូវបានគេដកចេញពីការដ្ឋាន ហើយបញ្ជូនទៅមន្ទីរសន្តិសុខនៅតាមស្រុករៀងៗខ្លួន។ សាក្សីមួយរូបដែលបានលាក់អត្តសញ្ញាណជនជាតិចាមរបស់ខ្លួន ដើម្បីរស់រានមានជីវិត បានរៀបរាប់អំពីអង្គប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាមួយនៅស្រុកចម្ការលើនៅឆ្នាំ១៩៧៧ ដែលបានពិភាក្សាពីផែនការកម្ទេចខ្មាំង។ ប្រធានអង្គប្រជុំបានប្រកាសថា ខ្មាំងរបស់បដិវត្តមានច្រើន ប៉ុន្តែខ្មាំងធំបំផុតរបស់យើងគឺជនជាតិចាម ដូច្នេះហើយទើបមានផែនការកម្ទេចជនជាតិចាមមុនឆ្នាំ១៩៨០។

[១៤:០៨:២៤]

សាក្សីដដែលនេះ បានលួចអានការបោះពុម្ពផ្សាយជាផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមានចំណងជើងថា “ផែនការសម្រាប់សហករណ៍ជឿនលឿន” ដែលលើកឡើងថាជនជាតិ គឺជាខ្មាំងធំបំផុតដែលត្រូវតែកម្ទេចចោលទាំងស្រុង មុនឆ្នាំ១៩៨០។ មានសាក្សីម្នាក់ទៀត ដែលបានរស់នៅក្នុង

ស្រុកក្រូចឆ្មារក្នុងឆ្នាំ១៩៧៧ ដែលកម្មាភិបាលសន្តិសុខម្នាក់បានប្រាប់គាត់ ដោយមិនដឹងថាគាត់ជាជនជាតិចាមថា ជនជាតិចាមដែលនៅសេសសល់គឺត្រូវសម្លាប់ក្នុងពេលឆាប់ៗនេះ។ មានភស្តុតាងដទៃផ្សេងនៅក្នុងសំណុំរឿងដែលបង្ហាញពីការកំណត់គោលដៅជនជាតិចាម ដោយមានការរៀបចំនៅក្នុងខេត្តកំពង់ចាម។ នៅស្រុកកងមាស ថ្នាក់លើបានបញ្ជាឲ្យធ្វើការកត់ឈ្មោះជនជាតិចាមនៅតាមការដ្ឋាននានា ប៉ុន្តែខែក្រោយមក ជនជាតិចាមទាំងនោះត្រូវបានគេដកចេញពីការដ្ឋានទាំងនោះ។ ជនជាតិចាមត្រូវបានគេកំណត់គោលដៅ ដោយសារតែជាតិពន្ធុរបស់ខ្លួន ហើយមិនមែនដោយសារថាពួកគេត្រូវបានសង្ស័យថាជាខ្មាំងរបស់របបនោះឡើយ។

[១៤:០៩:៣២]

អតីតសមាជិកក្រុមឈ្លបដាវវែងម្នាក់ ដែលក្រុមឈ្លបនេះបានបង្កើតឡើងដោយកម្មាភិបាលភូមិភាគនិរតីធ្វើប្រតិបត្តិការក្នុងស្រុកកងមាស។ ប្រជាជនចាស់ដូចខ្ញុំអត់មានគេចាប់ទេ ប្រជាជនថ្មីក៏ដូចគ្នាដែរ មានតែជនជាតិចាមប៉ុណ្ណោះដែលត្រូវគេចាប់។ នៅក្នុងស្រុកកងមាស និងស្រុកក្រូចឆ្មារ ជនជាតិចាមត្រូវបានគេប្រមូលជាប្រព័ន្ធ និងបញ្ជូនទៅមន្ទីរសន្តិសុខស្រុកចំនួនពីរគឺ មន្ទីរសន្តិសុខវត្តអូរត្រកួន ក្នុងស្រុកកងមាស និងមន្ទីរសន្តិសុខក្រូចឆ្មារ។ នៅថ្ងៃមួយក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ជនជាតិចាមទាំងអស់ចំនួន៣០០នាក់នៅឃុំពាមជីកងត្រូវបានចាប់ខ្លួន និងបញ្ជូនទៅវត្តអូរត្រកួន។ ការចាប់ខ្លួនទ្រង់ទ្រាយធំនេះ ធ្វើឡើងតាមបញ្ជាលេខាស្រុក។ សាក្សីម្នាក់ដែលត្រូវបានគេជ្រើសឲ្យទៅចាប់ខ្លួននោះរៀបរាប់ពីព្រឹត្តិការណ៍ដូចខាងក្រោម៖

អ្នកភូមិទាំងអស់នោះ មានការភ័យខ្លាច អ្នកខ្លះយំ ប៉ុន្តែមិនមាននរណាម្នាក់ហ៊ានលួចរត់ទេ។ ខ្ញុំមានការអាណិតអាសូរអ្នកភូមិទាំងអស់នោះណាស់ ព្រោះភាគច្រើនជាមនុស្សដែលខ្ញុំបានស្គាល់ ធ្លាប់រកត្រីជាមួយគ្នា។ បន្ទាប់មក ជនរងគ្រោះទាំងនោះត្រូវបានគេសម្លាប់នៅក្នុងចម្ការមួយក្បែរគុក កូនក្មេងត្រូវបានគេសម្លាប់ដោយបោកនឹងដើមឈើ ហើយពេជ្ឈឃាដទាំងនេះបានប្រកួតប្រជែងគ្នា ដើម្បីស្វែងរកអ្នកដែលអាចសម្លាប់មនុស្សបានលឿនបំផុត។

ប្រធានសន្តិសុខឃុំ ដែលជនរងគ្រោះទាំងនេះត្រូវគេចាប់ខ្លួន បានពន្យល់ថា ជនជាតិចាមជាពូជសាសន៍ផ្សេងដូច្នេះហើយត្រូវតែកម្ទេច។ សាក្សីជនជាតិចាមម្នាក់ទៀត បានលួចរត់នៅពេលគេបញ្ជូនទៅវត្តអូរត្រកួនជាមួយនឹងជនជាតិចាមដទៃទៀត។ គាត់បានរត់រួចខ្លួនដោយបានលាក់ខ្លួននៅក្នុងវាលភក់។ គាត់រំឭកពីយប់នៃការធ្វើទារុណកម្មមុននឹងគាត់រត់រួច។ "ខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ តែខ្ញុំបានឮ

សម្រែក ខ្ញុំបានឮប្អូនប្រុសរបស់ខ្ញុំស្រែក ខ្ញុំដឹងថា ជាសំឡេងរបស់ប្អូនខ្ញុំ។ មុនត្រូវគេសម្លាប់អ្នកទាំងនោះបានស្រែកឲ្យព្រះជួយ ស្រែករកម្ដាយរបស់ខ្លួន ដោយពួកគេស្រែកជាភាសាចាម ហើយក៏មានសម្រែកដោយសារការឈឺចាប់ដែរ។ ម្ដាយ និងប្អូនប្រុសរបស់ខ្ញុំស្ថិតនៅក្នុងចំណោម អ្នកដែលត្រូវគេសម្លាប់នោះ។ ការសម្លាប់ត្រូវបានរួចរាល់មុនពេលជិតភ្លឺ។"

[១៤:១២:១៦]

ការចាប់ខ្លួនទ្រង់ទ្រាយធំ និងការសម្លាប់ជនជាតិចាមក្នុងស្រុកក្រូចឆ្មារ ត្រូវបានអនុវត្តជាប្រព័ន្ធដូចគ្នា។ ស្ត្រីជនជាតិចាមម្នាក់ ដែលនៅឆ្នាំ១៩៧៧ ជាក្មេងស្រីម្នាក់ធ្វើការក្នុងកងចល័តក្នុងស្រុកក្រូចឆ្មារបានរៀបរាប់ថា ក្មេងស្រីជនជាតិចាម ដែលមិនទាន់រៀបការចំនួន៣៥នាក់ ត្រូវបានគេនាំយកទៅផ្ទះមួយដែលគេបោះបង់ចោល ដើម្បីសម្លាប់។ ពេលដែលពួកគេអង្គុយរង់ចាំ ពួកគេបានឮសំឡេងសំលៀងកាំបិត ហើយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និយាយថា សំលៀងកាំបិតនោះឲ្យមុត ព្រោះជ្រូកធំៗណាស់ថ្ងៃនេះ។ ក្មេងស្រីទាំងនោះត្រូវបានគេសួរថា ជាជនជាតិចាម ខ្មែរ ឬកូនកាត់? ហើយត្រូវគេបំបែកផ្សេងៗគ្នា។ នេះជាការរៀបរាប់ព្រឹត្តិការណ៍ដែលបានកើតឡើង។ ក្រោយមកកម្មាភិបាលម្នាក់បានស្រែកបញ្ជាឲ្យចាមទៅម្ខាង ខ្មែរទៅម្ខាង ហើយកូនកាត់ទៅម្ខាង។ ខ្ញុំបានកុហកគេថា ខ្មែររួចទៅហើយដូច្នេះខ្ញុំទៅខាងខ្មែរ។ តាមពិតក្មេងស្រី៣៦នាក់ ជាមិត្តភក្តិដ៏ល្អរបស់ខ្ញុំ ហើយពួកយើងជាជនជាតិចាមសុទ្ធ។ ខ្ញុំកុហកដើម្បីរស់រានមានជីវិតប៉ុណ្ណោះ។

[១៤:១៣:៣២]

អ្នកដែលប្រកាសថា ខ្លួនជាជនជាតិចាម ឬកូនកាត់ត្រូវគេនាំចេញពីផ្ទះ ហើយឲ្យទៅដេកលើក្ដារបន្ទះនៅម្ខាងរណ្ដៅ។ ក្មេងស្រីម្នាក់ៗដេកផ្កាប់មុខនៅលើបន្ទះក្ដារ បន្ទះក្ដារត្រូវបានគេអារពីក្រោយហើយទម្លាក់ចូលក្នុងរណ្ដៅ ដោយរណ្ដៅនោះរាក់ សាក្សីអាចមើលឃើញដៃ និងជើងរបស់ក្មេងស្រីទាំងនោះកន្ត្រាក់។ ពួកគេស្លាប់ម្ដងមួយៗ មិនមាននរណាម្នាក់ហ៊ានស្រែក ឬយំឡើយ។ ក្មេងស្រីខ្លះ ត្រូវគេសម្រាតខោអាវអស់ ហើយរំលោភមុននឹងសម្លាប់។ ក្មេងស្រីដទៃទៀតកុហកថា ជាខ្មែរមិនត្រូវបានគេសម្លាប់ទេ តែត្រូវបានគេឲ្យបរិភោគសាច់ជ្រូក ដើម្បីបញ្ជាក់ថា ពួកគេកុហកឬអត់។

យើងនឹងដាក់នៅចំពោះមុខលោកប្រធាន លោកស្រីចៅក្រម នូវភស្តុតាងដែលសម្លាប់ជនជាតិចាមទ្រង់ទ្រាយធំនៅក្នុងស្រុកក្រូចឆ្មារ បានបន្តនៅក្នុងឆ្នាំ១៩៧៨ បុរសជនជាតិចាមម្នាក់ដែលបានលួចរត់ពីការសម្លាប់ជនជាតិចាមទ្រង់ទ្រាយធំមួយ នៅភូមិទ្រា បានរៀបរាប់ពីរបៀបដែលកម្មាភិបាលបក្ស

កុម្មុយនីស្តកម្ពុជាបានចង ហើយជ្រមុជទឹកក្រុមបុរសជនជាតិចាមឲ្យលង់ស្លាប់ក្នុងទន្លេមេគង្គ។

[១៤:១៤:៥៣]

នៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ គាត់នៅចាំថា “ខ្ញុំមានការតក់ស្លុតបំផុតនៅពេលដែលខ្ញុំឃើញបុរសទាំងនោះខ្លះយំ ខ្លះទៀតស្រែកនៅពេលដែលពួកគាត់ ពួកគេដួលលើដី ហើយរមៀល នៅពេលដែលទូកទាញពួកគេទៅកណ្តាលទន្លេ។ នៅកណ្តាលទន្លេ ខ្មែរក្រហមម្នាក់បានស្រាយខ្សែចេញពីទូក។ ពេញមួយថ្ងៃទូកនោះបានបន្តសកម្មភាពបែបនេះម្តងហើយម្តងទៀត”។ បន្ថែមពីលើការសម្លាប់រង្គាលនេះ ការសម្លាប់រាប់សិបទៀតបានកើតមានឡើងនៅភូមិភាគ នៅភូមិទ្រាំងស្រុកក្រូចឆ្មារ។ សាក្សីនានានឹងផ្តល់សក្ខីកម្មបញ្ជាក់ថា នៅពេលពួកគេត្រឡប់ទៅតំបន់នោះវិញក្នុងឆ្នាំ១៩៧៩ ពួកគេបានឃើញរណ្តៅជាច្រើនដែលមានសាកសពជនជាតិចាម ឥទ្ធិពលនៃយុទ្ធនាការប្រល័យពូជសាសន៍នៅស្រុកក្រូចឆ្មារមានទំហំធំធេងណាស់។ សាក្សីម្នាក់ទៀតបានរៀបរាប់ថា ពួកគេតាមស្រាវជ្រាវជនជាតិចាមដើម្បីសម្លាប់កុំឲ្យសល់ម្នាក់។ សមាជិកប្រាំបីនាក់ក្នុងគ្រួសារខ្ញុំត្រូវបានគេសម្លាប់ទាំងអស់លើកលែងតែខ្ញុំម្នាក់គត់ ដោយសារខ្ញុំបន្លំធ្វើជាជនជាតិផ្សេង។

[១៤:១៦:០៥]

ក្រុមការពារក្តីនឹងជម្រាបលោកប្រធាន លោក លោកស្រីចៅក្រមថា នៅក្នុងគណៈមជ្ឈិមមានអំណាចតិចតួចបំផុត ឬមានការដឹងតិចតួចបំផុតអំពីការសម្លាប់ទ្រង់ទ្រាយធំទាំងនេះ។ ក្រុមការពារក្តីនឹងជម្រាបលោកប្រធាន លោក លោកស្រីចៅក្រមថាជនជាប់ចោទមិនមានបំណងបំផ្លាញជនជាតិចាមជាក្រុមនោះទេ។ ប៉ុន្តែ គ្រាន់តែជាការអនុវត្តនូវច្បាប់ថ្មីដែលហាមឃាត់ការគោរពសាសនាប៉ុណ្ណោះ។ ប៉ុន្តែជំហរនេះមិនមានមូលដ្ឋានគាំទ្រទេ។ ការសម្លាប់រង្គាលត្រូវបានគេរៀបចំផែនការ និងរាយការណ៍ទៅថ្នាក់ខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា។

កម្រិតនៃការរៀបចំការសម្លាប់ និងការបំផ្លាញសហគមន៍ចាមទាំងអស់នៅក្នុងខេត្តកំពង់ចាមបង្ហាញឲ្យឃើញថា នេះមិនមែនជាឧក្រិដ្ឋកម្មដែលកើតឡើងដោយព្រាវៗនោះឡើយ។ ប៉ុន្តែជាផ្នែកមួយនៃការប៉ុនប៉ងជាប្រព័ន្ធដើម្បីបំផ្លាញគ្រប់ជនជាតិចាមនៅស្រុកក្រូចឆ្មារ និងស្រុកកងមាស ក្នុងខេត្តកំពង់ចាម។

ក្នុងអំឡុងពេលនៃការសម្លាប់រង្គាលនោះ ជនជាតិចាមមិនត្រូវបានគេស៊ើបអង្កេតចំពោះបទល្មើសណាមួយប្រឆាំងនឹងរបបនោះឡើយ។ ការសួរចម្លើយគឺគ្មានអ្វីក្រៅពី ដើម្បីបញ្ជាក់ឲ្យច្បាស់ថាជន

រងគ្រោះទាំងនោះ ជាជនជាតិចាមប៉ុណ្ណោះ។ ហើយនៅពេលដែលជាតិពន្ធរបស់ពួកគេត្រូវបានរកឃើញ ហើយ ជនរងគ្រោះត្រូវគេសម្លាប់ដោយជៀសមិនរួចឡើយ។

សមាជិកនៃសហគមន៍ទាំងអស់ត្រូវបានគេកំណត់គោលដៅទាំងបុរស ស្ត្រី និងកុមារ។ លោកប្រធានលោកស្រីចៅក្រមជាទីគោរព យុទ្ធនាការធ្វើឲ្យវិនាសសាបសូន្យជនជាតិចាមនៅខេត្តកំពង់ចាមបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរបំផុតដល់សហគមន៍នេះ។ លទ្ធផលចុងក្រោយគឺជាការបំបាត់ចោលផ្នែកដ៏ធំមួយនៃជនជាតិចាមនៅក្នុងខេត្តនេះ។ ជាឧទាហរណ៍ប្រជាជនចាមទាំងអស់ដែលរស់នៅក្នុងភូមិចាមទាំងបួននៅក្នុងស្រុកកងមាស មានតែពីរនាក់ប៉ុណ្ណោះដែលនៅរស់រានមានជិវិត។ ជនជាតិចាមចំនួនប្រហែលជាមួយម៉ឺននាក់ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួន។ ជនជាតិចាមប្រហែលជា៩០ភាគរយដែលរស់នៅភូមិកោះផល និងស្វាយឃ្លាំង ក្នុងស្រុកក្រូចឆ្មារបានបាត់បង់ជីវិតនៅចុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៤:១៨:២៨]

ភស្តុតាងដែលយើងនឹងដាក់នៅចំពោះមុខលោកប្រធាន លោក លោកស្រីចៅក្រមនឹងបង្ហាញផងដែរនូវការហួសពីវិមតិសង្ស័យថាទាំងនេះគឺជាអំពើប្រល័យពូជសាសន៍ដែលជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម។ ឥឡូវនេះខ្ញុំនឹងលើកពីការចោទប្រកាន់អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម។ ដូចគ្នានឹងជនជាតិចាមដែរ ជនជាតិវៀតណាមគឺជាក្រុមជាតិពន្ធមួយនៅក្នុងប្រទេសកម្ពុជា។ ហើយពួកគេមានលក្ខណៈខុសពីប្រជាជនទូទៅ ដោយសាររាងកាយ ភាសា និងវប្បធម៌។ ពួកគេចាត់ទុកខ្លួនឯងថាជាជនជាតិវៀតណាម ហើយប្រជាជនខ្មែរក៏ទទួលស្គាល់ដូច្នេះដែរ។ មុនឡើងកាន់អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា សហគមន៍ជនជាតិវៀតណាមភាគច្រើន បានប្រមូលផ្តុំគ្នានៅតាមភូមិជុំវិញទន្លេសាប និងនៅតាមតំបន់ព្រំដែនវៀតណាមដូចជានៅខេត្តព្រៃវែង និងខេត្តស្វាយរៀង។

ក្នុងឆ្នាំ១៩៧០ ជនជាតិវៀតណាមរស់នៅប្រទេសកម្ពុជាមានចំនួនសរុបប្រហែលជាបួនសែននៅ៤៥០.០០០នាក់។ ប្រហែលពាក់កណ្តាលនៃចំនួននេះត្រូវបាននិរទេសទៅប្រទេសវៀតណាម ដោយរបបសាធារណរដ្ឋលន់ នល់ ហើយចំនួនទៀតត្រូវបានសម្លាប់។ នៅពេលប៉ុល ពត និងជនជាប់ចោទបានឡើងកាន់អំណាច។ ជនជាប់ចោទបានបង្កើតនូវគោលនយោបាយរបស់ខ្លួន ដើម្បីបំបាត់ជនជាតិ

វៀតណាមក្នុងប្រទេសកម្ពុជា។

[១៤:២០:០០]

ផែនការនេះត្រូវបានបង្ហាញជាលើកដំបូង តាមរយៈការបញ្ជូនជនជាតិវៀតណាមចំនួនមួយសែនប្រាំម៉ឺននាក់ ទៅពីរសែននាក់ចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥។ ជនជាតិវៀតណាមទាំងនេះ ភាគច្រើនត្រូវបាននិរទេសទៅវៀតណាម ហើយនៅក្នុងករណីជាច្រើនពួកគេបានប្តូរជាមួយអំបិល ឬអង្ករ។ ជនជាតិវៀតណាមប្រហែលជាពីរម៉ឺននាក់ នៅសល់នៅក្នុងប្រទេសនៅចុងឆ្នាំ១៩៧៥ ដែលភាគច្រើនជាសមាជិកគ្រួសារកូនកាត់ ចលនានៃការធ្វើឲ្យពួកគេវិនាសសាបសូន្យបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៧ យុទ្ធនាការនេះត្រូវបានធ្វើឡើងជាប្រព័ន្ធ និងប្រកបដោយមានរបៀបបំផុតដែលមកត្រឹមខែមករា ឆ្នាំ១៩៧៩ ជនជាតិវៀតណាមដែលនៅសេសសល់ស្ទើរតែទាំងអស់ត្រូវបានបោសសម្អាត។

ចាប់តាំងពីឆ្នាំ១៩៧៧ មកបក្សកុម្មុយនីស្តកម្ពុជាបានអំពាវនាវឲ្យប្រជាជនខ្មែរស្អប់ខ្ពើមជនជាតិវៀតណាមដែលជាអ្នកជិតខាង។ ក្នុងខែមេសា ឆ្នាំ១៩៧៧ ក្រុមដឹកនាំបក្សបានប្រើភាសាអំពើប្រល័យពូជសាសន៍ជាចំហចំពោះជនជាតិវៀតណាម។ ពួកគេបានធ្វើការប្រកាសថា "វាជាការចាំបាច់ត្រូវបំផុសមហាជនឲ្យបោសសម្អាតថែមទៀតឲ្យស្អាតជាស្ថាពរ"។ ក្នុងទស្សនាវដ្តីទង់បក្សបដិវត្តន៍ ខែសីហា ឆ្នាំ១៩៧៨ ក្រុមដឹកនាំបក្សបានអះអាងដោយមោទនភាពថា "ពីដើមជិតមួយលាននាក់ ឥឡូវរកមួយគ្រាប់គ្មានទេ"។

[១៤:២១:៣៩]

លោកប្រធាន លោក លោកស្រីចៅក្រម នឹងបានឮក្នុងការអនុវត្តផែនការប្រល័យពូជសាសន៍នេះ ក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានកំណត់ទស្សនៈថា "ជនជាតិវៀតណាមជាពូជសាសន៍ទាបជាង ហើយមើលឃើញការសម្លាប់រង្គាលគឺជាទម្រង់មួយនៃបន្សុទ្ធពូជសាសន៍"។ ជនជាប់ចោទបានព្យាយាមឲ្យជនដែលដល់ទាំងអស់មានទស្សនៈជ្រុលនិយម ដោយបំភ្លៃ ឬកេងចំណេញពីជំនឿប្បធម៌បុរាណកាល និងទម្លាប់នៃការប្រកាន់ពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម។

ចាប់តាំងពីឆ្នាំ១៩៧៧ មកនៅក្នុងការសរសេរឆ្លើយឆ្លង និងសេចក្តីថ្លែងការណ៍ផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ជនជាតិវៀតណាមត្រូវបានគេហៅថា "យួន" ដែលជាមនុស្សសាហាវយង់ឃ្នងចង់លេបទឹកដីកម្ពុជា។ របបនោះមានទស្សនៈយល់ឃើញថា "អត្ថិភាពនៃមនុស្សសាហាវយង់ឃ្នងទាំងនេះជានិមិត្តរូបតំណាងឲ្យការគំរាមកំហែង ដល់ការរស់រានមានជីវិតរបស់ពូជសាសន៍ខ្មែរ"។ តាមការពិត

ពួកគេមានចេតនាមោះមុតបំផុតក្នុងការបំផ្លាញរាល់សញ្ញាណ នៃជាតិពន្ធវៀតណាមនៅក្នុងប្រទេសកម្ពុជា ហើយសូម្បីតែខ្មែរកម្ពុជាក្រោមក៏ក្លាយជាគោលដៅរបស់របបនោះដែរ ដោយសារតែពួកគេមានទំនាក់ទំនងជាមួយនឹងប្រទេសវៀតណាម។

[១៤:២៣:០០]

ការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមត្រូវបានប្រព្រឹត្តទៅជាប្រព័ន្ធ និងដោយមានរបៀប។ ដំបូងប្រជាជនវៀតណាមត្រូវគេ បានឲ្យទៅចុះឈ្មោះជាមួយនឹងប្រធានភូមិ ដើម្បីដឹងចំនួន។ បញ្ជីដែលត្រូវគេរៀបចំទុកជាមុន ត្រូវបានគេយកប្រើនៅពេលក្រោយ គឺនៅពេលធ្វើការចាប់ខ្លួន និងសម្លាប់។

នៅខណៈដែលយុទ្ធនាការប្រល័យពូជសាសន៍បានចាប់ផ្តើម អ្នកភូមិជាជនជាតិវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀងត្រូវបានគេស្វែងរកជាប្រព័ន្ធនាំខ្លួន និងសម្លាប់ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ជួនកាលជនជាតិវៀតណាមត្រូវបានគេចាប់ខ្លួនដោយយកលេសថា "យកទៅរៀនសូត្រ ទៅកាប់រល្លី ឬទៅស្ទូងស្រូវ"។ មិនមាននរណាម្នាក់បានត្រឡប់មកវិញទេ។

ភស្តុតាងនៃអំពើប្រល័យពូជសាសន៍នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង រួមទាំងករណីជាច្រើននៃការសម្លាប់សមាជិកគ្រួសារកូនកាត់ ខាងក្រោមនេះគឺជាសម្តីរបស់សាក្សីម្នាក់ដែលរៀបរាប់ពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានអនុវត្តនៅក្នុងខេត្តនេះ។ បើម្តាយជាជនជាតិវៀតណាម ឪពុកជាខ្មែរ ទាំងម្តាយទាំងកូនត្រូវគេសម្លាប់នៅសល់តែឪពុក បើម្តាយជាខ្មែរ ឪពុកជាវៀត-ណាម ឪពុកជាវៀតណាមត្រូវគេយកទៅសម្លាប់តែម្នាក់ឯង នៅសល់តែម្តាយនិងកូន។

[១៤:២៤:២៦]

សាក្សីម្នាក់បានស្តាប់ពួកម្នាភិបាលនិយាយថា "មូលដ្ឋាននយោបាយនេះគឺដោយសារតែកូននៅបៅទឹកដោះម្តាយ" នេះមានន័យថា "ការចាប់កំណើតជាមួយម្តាយជាជនជាតិវៀតណាមជាមូលហេតុគ្រប់គ្រាន់សម្រាប់សម្លាប់ក្មេងនោះហើយ"។ ព្រឹត្តិការណ៍នៅក្នុងខេត្តព្រៃវែងគឺគ្មានមេត្តាបន្តិចទាល់តែសោះ សូម្បីតែប្រជាជនខ្មែរក៏ភ័យខ្លាចមិនហ៊ានបង្ហាញពីអារម្មណ៍របស់ខ្លួនឡើយ។ នៅពេលដែលសមាជិកគ្រួសារជនជាតវៀតណាមត្រូវបានគេនាំចេញទៅ ប្រជាជនខ្មែរដែលបង្ហាញពីការលំបាកចិត្ត ឬការសោកស្តាយក្រោយពីសាច់ញាតិរបស់ខ្លួនជាជនជាតិវៀតណាមត្រូវបានគេសម្លាប់នោះ ត្រូវបានគេបញ្ជូនទៅឲ្យកសាង។ អ្នករស់នៅជិតខាង ដែលបានរស់នៅដោយសន្តិភាពជាច្រើនឆ្នាំមកហើយជា

មួយគ្នា ត្រូវបានគេបង្ខំរាយការណ៍ពីគ្នាទៅវិញទៅមក។ សាក្សីម្នាក់បានរស់នៅក្នុងភូមិជាមួយបុរសម្នាក់ ដែលបានយកប្រពន្ធ និងកូនរបស់សាក្សីរូបនេះទៅសម្លាប់។ សាក្សីរូបនោះមិនបានធ្វើទុក្ខទោសដល់បុរសនោះទេ សាក្សីរូបនោះរង់ចាំយុត្តិធម៌មិនមែនការសងសឹកទេ។ ចេតនារបស់ក្រុមដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើឲ្យវិនាសសាបសូន្យក្រុមជាតិពន្ធវៀតណាមនៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង ត្រូវបានបញ្ជាក់កាន់តែច្បាស់តាមរយៈការសម្លាប់រង្គាលជនជាតិវៀតណាមជាច្រើនកន្លែងទៀតនៅទូទាំងប្រទេស។

[១៤:២៥:៥៨]

សាក្សីម្នាក់បានលួចមើលការសម្លាប់រង្គាលនៅវត្តខ្សាច់នៅខេត្តសៀមរាប។ សាក្សីម្នាក់គាត់នឹងរៀបរាប់ប្រាប់តុលាការអំពីការសម្លាប់បុរស ស្ត្រី និងកុមារជនជាតិវៀតណាម ដែលមនុស្សចាស់ត្រូវគេវាយសម្លាប់នឹងដំបងឫស្សី ហើយកូនក្មេងត្រូវគេបោកផ្ទប់នឹងដើមដូង។ កម្មាភិបាលខ្មែរក្រហមសួរថាពួកឯងទាំងអស់ជាយួនមែនទេ? មុននឹងសម្លាប់។ មានស្ត្រីម្នាក់បានរួចខ្លួន ដោយគាត់បានធ្វើឲ្យកម្មាភិបាលនោះជឿថាគាត់ជាចិន មិនមែនជាវៀតណាមទេ។

ការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍នៅទូទាំងប្រទេស ក្នុងអំឡុងពេលដដែលនេះសបញ្ជាក់ឲ្យឃើញថា បទឧក្រិដ្ឋទាំងនេះពុំមែនប្រព្រឹត្តឡើងដោយគ្មានការអនុញ្ញាត ឬធ្វើឡើងដោយចៃដន្យនោះទេ។ បទឧក្រិដ្ឋទាំងនេះត្រូវបានណែនាំពីមជ្ឈិម។ ការបម្រុងកម្ទេចជនជាតិវៀតណាម ២០.០០០នាក់ដែលនៅសេសសល់ ឲ្យអស់ពីប្រទេសកម្ពុជា គឺភស្តុតាងគួរឲ្យជឿជាក់បានស្តីពីផែនការដែលបានរៀបចំទុក ដើម្បីកម្ទេចជនជាតិវៀតណាមឲ្យផុតពូជ។ ជនជាតិវៀតណាម ក៏ដូចជាជនជាតិចាមដែរ គឺសុទ្ធតែជាក្រុមគោលដៅដែលត្រូវសម្លាប់ ដោយសារតែហេតុផលនៃជាតិពន្ធរបស់ពួកគេ។

[១៤:២៧:១៥]

ភស្តុតាងមិនមែនត្រឹមតែបង្ហាញឲ្យឃើញថា ជនជាប់ចោទមានបញ្ជា បែបមានបញ្ជានិងរៀបចំយុទ្ធនាការសម្លាប់ជាប្រព័ន្ធប៉ុណ្ណោះទេ វានឹងបង្ហាញផងដែរថាជនជាប់ចោទមានចេតនាធ្វើដូច្នេះ ដើម្បីកម្ទេចជនជាតិវៀតណាមទាំងអស់នៅកម្ពុជា។ បទឧក្រិដ្ឋទាំងនេះបានកើតឡើងគាប់ចួនគ្នានឹងសុន្ទរកថានិងបញ្ជាចេញពីមេដឹកនាំបក្ស ដែលអំពាវនាវឲ្យកម្ទេចជនជាតិវៀតណាម។ ប៉ុល ពត បានឯកភាពតាមគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា។ យើងជាប្រជាជនកម្ពុជាទាំងប្រុសទាំងស្រីនឹងបន្តកាប់ចិញ្ច្រាំពួកវា។ នៅទីបំផុតយើងនឹងដើរចូលនៅក្នុងដីកដីរបស់ពួកវា នឹងសម្លាប់ប្រពន្ធ និងកូនចៅវាទាំង

ប្រុសទាំងស្រី និងទាំងកូនង៉ា។ ធ្វើដូច្នេះ ពូជសាសន៍បីសាចយួននឹងត្រូវបានបោសសម្អាតឲ្យអស់ពីភពផែនដីនេះ។

[១៤:២៨:១៣]

លោក លោកស្រី ចៅក្រមជាទីគោរពគ្មានអ្វីដែលត្រូវមន្ទិលសង្ស័យនោះទេ គឺជនជាប់ចោទពិតជាមានចេតនារួមគ្នាដូច្នេះមែន។ ហើយយើងខ្ញុំនឹងយកភស្តុតាងមកបង្ហាញឲ្យឃើញថា ពិតដូច្នេះនៅក្នុងសវនាការជំនុំជម្រះអង្គសេចក្តី។ ភស្តុតាងទាំងនេះនឹងបង្ហាញឲ្យឃើញថា ការកម្ទេចជនជាតិវៀតណាម ជាប្រព័ន្ធនៅក្នុងខេត្តព្រៃវែង និងស្វាយរៀង គឺបង្កើតជាអំពើប្រល័យពូជសាសន៍ដែលជនជាប់ចោទត្រូវតែទទួលខុសត្រូវដោយផ្ទាល់។

សម្រាកបន្តិច ម៉េចក៏?

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណច្រើនលោកសហព្រះរាជអាជ្ញាជាតិ។ ឥឡូវនេះពេលវេលាសមល្មមនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ប្រាំ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោក ឌុច ផារី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣០នាទី ដល់ម៉ោង ១៤:៥១នាទី)*

[១៤:៥១:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងសូមប្រគល់វេទិកាទៅលោកជំទាវសហព្រះរាជអាជ្ញាជាតិ ដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់។

សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

សូមអនុញ្ញាតបន្តទៀត។ បទឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងក្នុងជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម។ ជនជាប់ចោទ ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញា

ក្រុងហ្សឺណែវ ដែលបានប្រព្រឹត្តឡើងដោយកងកម្លាំងដែលស្ថិតនៅក្រោមបញ្ជាក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធរវាងកងកម្លាំងរបស់ប្រជាធិបតេយ្យកម្ពុជា និងកងកម្លាំងរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម។ ក្នុងសំណុំរឿង០០១ លោក លោកស្រីចៅក្រមបានសម្រេចថា "អរិភាពនៃជម្លោះប្រដាប់អាវុធបានកើតមានឡើងរវាងប្រទេសកម្ពុជា និងវៀតណាម ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មែន"។

យើងខ្ញុំនឹងបង្ហាញថា ជម្លោះប្រដាប់អាវុធអន្តរជាតិមួយបានកើតឡើងក្នុងអំឡុងពេលនោះ និងបង្ហាញថា ច្បាប់សង្គ្រាមបានចូលជាធរមានសម្រាប់គ្រប់គ្រងការប្រព្រឹត្តរបស់ភាគីទាំងសងខាង។ នៅរវាងខែឧសភា ឆ្នាំ១៩៧៥ និងខែមីនា ឆ្នាំ១៩៧៨ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានចូលរួមវាយលុកចូលទៅក្នុងទឹកដីវៀតណាម និងបើកការវាយប្រហារលើភូមិដ្ឋាននានានៅក្នុងខេត្តតៃនីង ដុងថាប់ អានយ៉ាង និងគាងយ៉ាង។ ការចូលលុកលុយនេះបានប្រព្រឹត្តឡើងជាមួយនឹងការសម្លាប់ទ្រង់ទ្រាយធំ ការឆក់ប្លន់ និងការកម្ទេចដោយគ្មានរើសមុខទៅលើប្រជាជនស៊ីវិល។

[១៤:៥៣:៥២]

ជាលទ្ធផលប្រជាជនជាង បីម៉ឺននាក់បានស្លាប់ និងបាត់ខ្លួន និងប្រជាជន បួនសែននាក់ទៀតត្រូវជម្លៀសចេញពីផ្ទះសម្បែង។ ជនស៊ីវិល និងទាហានវៀតណាមរាប់រយនាក់ ត្រូវបានកងកម្លាំងប្រជាធិបតេយ្យចាប់ខ្លួននៅក្នុងអំឡុងពេលនៃការវាយប្រហារនោះ ដូចដែលយើងបានឃើញនៅក្នុងវីដេអូនេះ។

*(ការបង្ហាញឯកសារជារូបភាពវីដេអូចាប់ពីម៉ោង ១៤:៥៤:១៦ ដល់ម៉ោង ១៤:៥៤:៥០)*

[១៤:៥៤:៥០]

ពួកគេត្រូវបានបញ្ជូនទៅកាន់ ស-២១ ដើម្បីសួរចម្លើយ និងសម្លាប់។ ចម្លើយសារភាពរបស់ពួកគេត្រូវបានយកមកប្រើប្រាស់ធ្វើជាការឃោសនា របស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបញ្ជាក់អំពីការឈ្លានពានរបស់ប្រទេសវៀតណាមមកលើកប្រទេសកម្ពុជា។ ក្នុងចំណោមជនរងគ្រោះវៀតណាមដែលត្រូវបានកត់ត្រាក្នុងទាំង៣៤៥នាក់ មាន១២២នាក់ត្រូវបានចុះឈ្មោះជាឈ្លើយសឹក និង៧០នាក់ទៀតជាជនស៊ីវិល។ ការចាប់ខ្លួនទាំងនេះ ត្រូវបាន សុន សេន និងអ្នកដទៃទៀតរាយការណ៍ត្រឡប់ទៅថ្នាក់លើ ដោយជូនដំណឹងទៅដល់ជនជាប់ចោទឲ្យបានដឹងអំពីបទឧក្រិដ្ឋទាំងនេះ។ លោក ណាយ៉ាន់ ចាន់ដា អ្នកឆ្លើយឆ្លងព័ត៌មានសង្គ្រាមដែលធ្វើការនៅក្នុងប្រទេសវៀតណាម ពិពណ៌នាអំពីព្រឹត្តិការណ៍

នៅក្រោយថ្ងៃវាយប្រហារនៅហាទៀងថា នៅជាប់នឹងផ្ទះបាក់បែកខ្ទេចខ្ទីមួយ មានសាកសពមនុស្ស ១៥នាក់ មានប្រុស ស្រី និងកូនក្មេង។ ចម្រៀកឈើដែលគេវាយសំពងទៅលើអ្នកទាំងនោះ ត្រូវបានគេទុកចោលទៅក្បែរនោះ។ ឈើមួយចម្រៀកត្រូវបានគេដោតនៅក្នុងអវយវៈភេទរបស់ស្ត្រីម្នាក់ដែលដេកផ្ងារទាំងកាយអាក្រាត។ កូនតូចៗពីរនាក់របស់គាត់ ត្រូវបានគេកាប់ដាច់ជាកំណាត់ៗ។ សាកសពខ្លះអត់មានក្បាល ខ្លះទៀតត្រូវបានគេវះពោះ និងមានរុយក្បាលខៀវរោមអ៊ូ។

[១៤:៥៦:២៤]

ពីផ្ទះមួយទៅផ្ទះមួយសុទ្ធតែមានដិតដាមទៅដោយទិដ្ឋភាពគួរឱ្យរន្ធត់នេះ។ អតីតទាហានកម្ពុជាប្រជាធិបតេយ្យម្នាក់ នឹងពិពណ៌នាអំពីការដែលគេបានបញ្ជូនគាត់ទៅវៀតណាម ដោយគេបញ្ជាឱ្យដុតនិងកម្ទេចចោលឱ្យអស់ ទោះជាអ្វីក៏ដោយ។ នៅក្រោមបញ្ជាទាំងនេះ កងទ័ពបានបំផ្លាញផ្ទះសម្បែង មន្ទីរពេទ្យ និងរោងចក្រ។ អង្គភាពរបស់គាត់ បានបញ្ជូនឈ្លើយសឹកវៀតណាមភាគច្រើនជាស្ត្រី ទៅកាន់ ស-២១ ដើម្បីធ្វើទារុណកម្ម និងសម្លាប់ចោល។ យុទ្ធជនម្នាក់ទៀត បានពិពណ៌នាអំពីបញ្ជាទៅឱ្យអង្គភាពគាត់ ឱ្យតែជនជាតិវៀតណាមសម្លាប់ចោលទាំងអស់ មិនថាទាហាន ឬជនស៊ីវិលនោះទេ។ នៅមានសក្សីមួយរូបទៀត គាត់បានឮទាហានខ្មែរក្រហមជជែកគ្នាអំពីការវាយលុយចូលក្នុងទឹកដីវៀតណាម និងអួតគ្នាអំពីការចាប់កូនក្មេងបោះទៅលើ រួចលើកចំពុះទង់ចាក់។

ភស្តុតាងដែលយើងខ្ញុំនឹងយកមកបង្ហាញជូនចំពោះអង្គជំនុំជម្រះ នឹងបង្ហាញឱ្យឃើញបទឧក្រិដ្ឋទាំងនេះ ត្រូវបានប្រព្រឹត្តឡើងទៅតាមបញ្ជាពីមជ្ឈិមបក្ស បក្សកុម្មុយនីស្តកម្ពុជា។ ជនជាប់ចោទបានចូលរួមក្នុងការចេញបញ្ជា ឬបានដឹងឮទាំងអស់អំពីបទឧក្រិដ្ឋទាំងនេះ។ ក្នុងឋានៈជាមេដឹកនាំថ្នាក់លើពួកខ្លួនមិនអាចចាត់វិធានការបង្ក្រាបបទឧក្រិដ្ឋទាំងនេះ ឬមិនបានដាក់ទណ្ឌកម្មចារីទេ។

ការជម្លៀសដោយបង្ខំលើកទីបី និងការបោសសម្អាតភូមិភាគបូព៌ា។ ទិដ្ឋភាពឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តចុងក្រោយគេ មុនការដួលរលំនៃបក្សកុម្មុយនីស្តកម្ពុជា មានការបោសសម្អាតទ្រង់ទ្រាយធំនៅភូមិភាគបូព៌ា និងការជម្លៀសដោយបង្ខំប្រជាជនដែលនៅក្នុងភូមិភាគនេះ ស្ទើរតែទាំងអស់ចេញដោយឱ្យនៅទីណាកន្លែងផ្សេងនៅក្នុងប្រទេសកម្ពុជា។ នេះគឺជាបទឧក្រិដ្ឋមួយទៀតចុងក្រោយ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ និងជាចំណុចដែលខ្ញុំនឹងលើកយកមកក្នុងពេលនេះ។ ចំណុចនេះសហការីអន្តរជាតិនឹងពិពណ៌នាឱ្យបានពិស្តារជាងនេះ មានព្រឹត្តិការណ៍ដែលមិននឹកស្មានដល់មួយចំនួនដែលបានធ្វើឱ្យថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាសង្ស័យក្នុងឆ្នាំ១៩៧៦ ថាជាបក្សកំពុងរងការគំរាមធ្វើ

រដ្ឋប្រហារ។ ព្រឹត្តិការណ៍ទាំងនេះ បានបណ្តាលឲ្យមានការចាប់ខ្លួន និងសួរចម្លើយជនទាំងឡាយដែលបានចោទថា កម្មាភិបាលជាន់ខ្ពស់ជាច្រើននៅភូមិភាគបូព៌ាថា ជាជនក្បត់។

[១៤:៥៩:១២]

នៅឆ្នាំ១៩៧៧ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា និងជាអនុប្រធានរបស់ ខៀវ សំផន ដែលជាគណៈប្រធានរដ្ឋ ត្រូវបានគេឆ្លើយដាក់។ មេដឹកនាំដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងជនជាប់ចោទផង បានសម្រេចថាភូមិភាគបូព៌ាសម្បូរទៅដោយជនក្បត់ ហើយ សោ ភឹម ខ្លួនឯង ក៏មិនស្មោះត្រង់។ គេទើបតែដឹងច្បាស់ថាការណ៍នេះ គឺវាពិតដូច្នេះមែន នៅពេលកងកម្លាំងវៀតណាមវាយលុកដោយជោគជ័យចូលភូមិភាគបូព៌ានៅក្នុងខែធ្នូ ឆ្នាំ១៩៧៧។

[១៥:00:00]

ការបោសសម្អាតដែលត្រូវបានផ្តួចផ្តើមឡើងដោយមជ្ឈិមបក្ស ត្រូវបានធ្វើឡើងទូទាំងភូមិភាគបូព៌ា និងជាលទ្ធផលមានមនុស្សស្លាប់ចន្លោះពីមួយសែននាក់ដល់ពីពីរសែនប្រាំម៉ឺននាក់។ នេះទំនងជាប្រតិបត្តិការដែលសម្លាប់មនុស្សច្រើនបំផុតក្នុងប្រតិបត្តិការតែមួយករណី ដែលរៀបចំឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ ប្រតិបត្តិការនេះត្រូវបានអនុវត្តដោយកម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហម ដូចជាសុន សេន, កែ ពក និង តាម៉ុក។ ជនជាប់ចោទពាក់ព័ន្ធយ៉ាងជិតស្និទ្ធក្នុងដំណើរការ និងបានដឹងឮច្បាស់អំពីព្រឹត្តិការណ៍មហាប្រល័យនេះ ដែលបានធ្វើឡើងនៅក្រោមបញ្ជារបស់ពួកខ្លួន។

[១៥:00:៤៥]

នួន ជា កាន់តំណែងដឹកនាំក្នុងការរៀបចំផែនការបោសសម្អាត និងណែនាំកម្មាភិបាលយោធាដែលត្រូវបញ្ជូនទៅចូលរួមក្នុងការបោសសម្អាតនេះ។ ប្រតិបត្តិការនេះ នាំឲ្យមានការចាប់ខ្លួនកងកម្លាំងភូមិភាគបូព៌ាជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធ។ ទាហានសក្តិទាបត្រូវបានបញ្ឈប់ពីការងារទ័ព និងបញ្ជូនទៅកាន់ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ចំណែកឯកម្មាភិបាលជាន់ខ្ពស់ ត្រូវបានបញ្ជូនទៅ ស-២១។ តាមការពិតមានមន្ត្រីជាន់ខ្ពស់ជាច្រើននាក់ ត្រូវបានបញ្ជូនមកភ្នំពេញ ដែលត្រូវបាន នួន ជា បញ្ជាឲ្យ ឌុច សម្លាប់ចំនួន៣00នាក់ ដោយមិនចាំបាច់សួរចម្លើយ។ កម្មាភិបាលថ្នាក់ទាបជាច្រើននាក់ជារឿយៗ មានទាំងប្រពន្ធ និងកូនរបស់ពួកគេផង ត្រូវបានសម្លាប់ចោលភ្លាមៗនៅជាយភូមិរបស់ពួកគេ។

ភូមិបុស្ស ក្នុងស្រុកពញាក្រែក ខេត្តកំពង់ចាម ត្រូវបានចាត់ទុកជាគោលដៅពិសេស ក្នុងការបោសសម្អាតនៅភូមិភាគបូព៌ា ដោយសារតែភូមិនេះមានទំនាក់ទំនងជាយូរមកហើយ ជាមួយនឹង សោ ភឹម។ ភូមិនេះគឺជាតំបន់មូលដ្ឋានតាំងពីយូរមកហើយ និងធ្លាប់បានផ្តល់ជាទីជម្រកដល់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដូចជា ប៉ុល ពត, នួន ជា និង យុន យ៉ាត ក្នុងទសវត្សរ៍ទី៦០។ ភូមិនេះ ត្រូវបានគេចាត់ទុកថាជាភូមិគំរូ ដែលសាកសមសម្រាប់បង្ហាញភ្ញៀវដែលមកធ្វើទស្សនកិច្ច។ ភូមិគំរូរបស់អ្នកមូលដ្ឋានដែលធ្លាប់តែមានស្មោះត្រង់ចំពោះខ្មែរក្រហម ឥឡូវនេះត្រូវបានគេបោសសម្អាតដោយសារតែគេគិតថា ភូមិនេះធ្លាប់មានទំនាក់ទំនងជាមួយ សោ ភឹម។

[១៥:០២:៣៣]

ភស្តុតាងនឹងបង្ហាញឲ្យយើងឃើញ អំពីរបៀបដែលអ្នកភូមិបុស្ស ប្រហែលនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៨ ត្រូវបានគេប្រមូលឲ្យមកនៅផ្តុំគ្នា និងត្រូវបានគេប្រាប់ឲ្យចាកចេញពីភូមិ ដោយយកលេសថា គេប្តូរឲ្យទៅនៅភូមិថ្មី។ គេបានឲ្យពួកគាត់ឡើងជិះរថយន្ត និងដឹកទៅទិសខាងកើតសំដៅទៅទីកន្លែងមួយក្នុងព្រៃស្តុកឈ្មោះថា "ស្ទឹងតូច"។ ពេលទៅដល់ទាហានបានព័ទ្ធចាប់ និងចងពួកគាត់។ ពួកគាត់ត្រូវបានគេចោទថា ជាភ្នាក់ងារ សេ.អ៊ី.អា និងកូនចៅ អាភឹម។ ដំបូងគេប្រមូលអ្នកភូមិប្រុសៗដាក់ជាក្រុមមានគ្នាពី៥ទៅ៨នាក់ រួចហើយគេចងខ្សែចងជាប់គ្នា និងបណ្តើរជាជួរដើរតម្រង់ទៅព្រៃទៅកន្លែងរណ្តៅ ដែលគេជីកទុកដើម្បីសម្លាប់។

[១៥:០៣:៣០]

សាក្សីមួយរូបដែលនៅរស់រានមានជីវិត ពិពណ៌នាអំពីការសម្លាប់រង្គាលនោះថា ពួកទាហានបានវាយអ្នកភូមិនឹងដំបងទម្លាក់ចូលក្នុងរណ្តៅព្រមៗគ្នា។ ចំណែកឯរណ្តៅដែលគេវាយខ្ញុំ គេទើបនឹងជីកវាថ្មីៗ មានចម្ងាយប្រហែល៦០ម៉ែត្រពីផ្លូវដើរ ក្នុងរណ្តៅមានសាកសព៨នាក់រួចហើយ។ សាកសពទាំងនោះបានប្រឡាក់ឈាមស្រោចពេញខ្លួន គេវាយខ្ញុំទម្លាក់នៅក្នុងរណ្តៅគរពីលើសាកសពទាំង៨នាក់នោះ។ ប្រហែលម៉ោង៧យប់ នៅថ្ងៃដដែល ខ្ញុំងើបឡើងពីរណ្តៅ ហើយរត់ទៅរកកន្លែងពួននៅក្នុងព្រៃក្បែរៗនោះ។ ខ្ញុំឮសម្រែកជនរងគ្រោះ ដែលពួកទាហាននាំយកទៅទីនោះស្រែកប្រាប់ថា ពួកគាត់អត់មានធ្វើអ្វីខុសទេ និងសួរថា តើហេតុអ្វីបានជាគេចង់សម្លាប់ពួកគាត់? ពួកទាហានឆ្លើយតបវិញថា ពួកគាត់ទាំងអស់សុទ្ធតែជាភ្នាក់ងារ សេ.អ៊ី.អា និងថាខំឃុំអង្ករក៏អត់ប្រយោជន៍ដែរ។ អ្នកភូមិម្នាក់ទៀតបានរកវិធីជួយខ្លួន និងកូនគាត់ឲ្យរួចជីវិតបាន ដោយសារការគាត់ធ្វើឲ្យពួកម្នាភិបាលភូមិភាគកណ្តាល

ជាអ្នកសម្លាប់អ្នកភូមិនោះ ជឿថា កូនគាត់ម្នាក់ធ្វើទាហាននៅភូមិភាគកណ្តាល។ ទោះជាយ៉ាងនេះក្តី អ្នកស្រីបានពិពណ៌នា អំពីការឃើញគេនាំប្តីគាត់ទៅជាមួយប្រុសៗផ្សេងៗទៀត យកទៅសម្លាប់។ គាត់មានការសោកស្តាយខ្លាំងណាស់ រហូតដល់ថ្នាក់គាត់លែងហ៊ានត្រឡប់ទៅមើលផ្ទះ ឬគាស់សាកសពប្តីរបស់គាត់។

[១៥:០៥:០៨]

លោក លោកស្រីចៅក្រម នឹងសួរសំណួរមួយថាតើហេតុអ្វីបានជាគេយកអ្នកភូមិសម្លាប់ចោលយ៉ាងដូច្នេះ?

តាំងពីដើមទសវត្សរ៍ទី៦០មកម្ល៉េះ ដែលអ្នកភូមិបុស្សមានស្វាមីភក្តិចំពោះបដិវត្តន៍ខ្មែរក្រហម។ អ្នកភូមិទាំងនេះត្រូវបានគេចាត់ទុកថាជាប្រជាជនគំរូ។ ជាចម្លើយថានៅក្នុងចិត្តរបស់ជនជាប់ចោទ និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត អ្នកភូមិគ្រាន់តែសេពគប់ជាមួយជនម្នាក់ដែលគេចាត់ទុកថាជាជនក្បត់ គឺគ្រប់គ្រាន់សម្រាប់ផ្តន្ទាទោសប្រហារជីវិតអ្នកភូមិនោះបាន។ បន្ទាប់មានការសម្លាប់រង្គាលនៅភូមិភាគបូព៌ារួច គេបានអនុវត្តដំណាក់កាលបោសសម្អាតចុងក្រោយមួយទៀត ដោយជម្លៀសប្រជាជនភូមិភាគនេះទៅកាន់ទីកន្លែងផ្សេងៗទៀតក្នុងប្រទេស រួមទាំងភូមិភាគពាយ័ព្យ កណ្តាលពោធិ៍សាន និងឧត្តរ។ ភាគច្រើននៃប្រជាជនភូមិភាគបូព៌ាត្រូវបានគេជម្លៀសទៅតំបន់ពីរ និងប្រាំពីរនៅខេត្តពោធិ៍សាត់ ក្នុងភូមិភាគពាយព្យ។

[១៥:០៦:២០]

លោក លោកស្រីចៅក្រមនឹងបានដឹងឮអំពីរបៀបដែលគេចាត់ទុកអ្នកជម្លៀសថាជាពួកក្បាលយួន ខ្លួនខ្មែរ និងចោទថាជាអ្នកក្បត់អង្គការ។ លោក លោកស្រីចៅក្រមនឹងបានឮអំពីរបៀបដែលអ្នកតវ៉ាប្រឆាំងនឹងការជម្លៀសនោះត្រូវបានគេបាញ់សម្លាប់នៅនឹងកន្លែងភ្លាម។ ភស្តុតាងនឹងលាតត្រដាងឲ្យដឹងអំពីការពិតមួយ គឺនៅពេលដែលបោសសម្អាតបានបញ្ចប់ទៅនៅភូមិភាគបូព៌ា ស្ទើរតែលែងមានប្រជាជនរស់នៅ។ អ្នកជម្លៀសពីភូមិភាគបូព៌ាត្រូវបានគេប្រើក្រមាពណ៌ខៀវ នៅក្នុងអំឡុងពេលជម្លៀសចេញពីភូមិភាគបូព៌ា។ ក្រមាខៀវទាំងនេះត្រូវបានគេនាំចូលមកពីប្រទេសចិន គឺក្នុងគោលបំណងច្បាស់លាស់មួយក្នុងការសម្គាល់ជនរងគ្រោះ។ លោក ប៉ែន យៀវនិន បានដកស្រង់សម្តីសាក្សីមួយរូបថា អង្គការចាប់ផ្តើមចែកខោអាវឲ្យពួកយើង ជាពិសេសគេចែកក្រមា និងភួយ។ ក្រមាមានតែពណ៌ខៀវឆ្នូត និងបៃតងឆ្នូតសប៉ុណ្ណោះ។ ម្នាក់ៗគេចែកក្រមាឲ្យមួយ ដោយសារខ្វះភួយ មួយគ្រួសារគេ

ចែកភួយឲ្យតែមួយប៉ុណ្ណោះ។ ប៉ុន្តែចំពោះក្រមាគេចែកឲ្យម្នាក់មួយ ខ្ញុំឃើញគេដឹកពេញឡាន ឡានមួយដឹកមក ពេលអស់មានឡានមួយទៀតដឹកមកទៀត។ ក្រមាមានច្រើន ម្នាក់ៗត្រូវតែមានក្រមាមួយ មិនអាចអត់បានទេ។

[១៥:០៧:៥៤]

ភស្តុតាងនឹងបង្ហាញឲ្យឃើញថាក្រមាខៀវទាំងអស់នេះត្រូវបានគេប្រើ ដើម្បីធ្វើជាសញ្ញាសម្គាល់ក្នុងការកំណត់អ្នកជម្លៀសមកពីភូមិភាគបូព៌ា ដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់។ អ្នកជម្លៀសពីភូមិភាគបូព៌ាត្រូវបានគេសម្លាប់ចោលជាប្រចាំ និងចំពោះថាពួកគេត្រូវបានបញ្ជូនទៅកាន់ភូមិភាគណាមួយនោះទេ។ ខាងក្រោមនេះគឺសម្តីរបស់លោក ហ្វីលីព ស៊ត ដែលបានពិពណ៌នាអំពីព្រឹត្តិការណ៍ទាំងនេះថាមនុស្សរាប់ពាន់នាក់ត្រូវបានគេដឹកចេញទៅភូមិភាគកណ្តាល ឧត្តរ និងពាយ័ព្យ ដែលនៅទីនោះប្រជាជនជាច្រើនត្រូវបានគេសម្លាប់ ពុំមាននរណាដឹងច្បាស់អំពីចំនួនមនុស្សស្លាប់សរុបនោះទេ។ ប៉ុន្តែពិតណាស់មានមនុស្សជាងមួយសែននាក់ ឬប្រហែលជាពីរសែនប្រាំម៉ឺននាក់ត្រូវបានគេសម្លាប់។ មិនចំពោះថាតួលេខនេះវាច្បាស់ជាងនេះ ឬយ៉ាងម៉េចនោះទេ ព្រឹត្តិការណ៍នោះគឺជាទិដ្ឋភាពនៃការសម្លាប់រង្គាលដ៏ធំជាងគេបំផុតក្រោមការដឹកនាំរបស់ប៉ុល ពត។

[១៥:០៩:០០]

អ្នកជម្លៀសពីភូមិភាគបូព៌ា ដែលត្រូវបានគេបញ្ជូនទៅភូមិភាគពាយ័ព្យបានទៅដល់ និងរស់នៅក្នុងខេត្តពោធិ៍សាត់ ត្រូវបានគេបញ្ជូនទៅសហករណ៍ និងការដ្ឋាន។ នៅទីនោះត្រូវបានគេបង្ខំឲ្យជីកប្រឡាយ និងធ្វើស្រែ។ ប្រវត្តិរូបរបស់ពួកគេត្រូវបានតាមដាន ដើម្បីរកមើលក្រែងធ្លាប់ធ្វើជាប្រធានភូមិ មេឃុំ ឃុំរងគ្រូបង្រៀន នគរបាល និងទាហាន។ ប្រសិនបើគេរកឃើញដូច្នោះមែន អ្នកទាំងនោះនឹងត្រូវគេចាប់ខ្លួននឹងយកទៅសម្លាប់ចោលភ្លាមៗ។

មុននេះបន្តិច មុនពេលវៀតណាមចូលមក ក្នុងឆ្នាំ១៩៧៩ អ្នកជម្លៀសពីភូមិភាគបូព៌ារាប់ពាន់នាក់ដែលនៅសេសសល់ត្រូវបានគេព័ទ្ធចាប់ និងសម្លាប់ចោល។ ប្រធានកងអនុសេនាតូចនៃបក្សកុម្មុយនីស្តកម្ពុជាម្នាក់ពិពណ៌នាអំពីការបញ្ជូនជនរងគ្រោះទៅវាលបាក់ជញ្ជីង ដែលនៅទីនោះមានមនុស្សរាប់ពាន់នាក់ត្រូវបានគេសម្លាប់។

[១៥:១០:០៥]

គាត់គូសបញ្ជាក់ថា យើងប្រមូលរទេះគោបានប្រហែល៣០រទេះ ទុកសម្រាប់ដឹកជញ្ជូនមនុស្ស

ទម្រាំដឹកអ្នកទាំងនោះអស់ យើងត្រូវប្រើពេលបួនថ្ងៃ។ មានមនុស្សច្រើននាក់ណាស់ រាប់ពាន់នាក់នៅពេលយើងមកដល់វាលបាក់ជញ្ជីង។ យើងឃើញពួកខ្មែរក្រហមកំពុងសំងំលាក់ខ្លួនបាំងដើមប៉ប្រកនៅក្បែរនោះ។ ក្រុមខ្ញុំបានដាក់មនុស្ស និងអីវ៉ាន់ចុះនៅក្បែរនោះ បន្ទាប់មកខ្ញុំឃើញទាហានខ្មែរក្រហមបណ្ដើរមនុស្សទាំងនោះចេញទៅ និងបាញ់សម្លាប់ចោលនៅកន្លែងមួយប្រហែលចម្ងាយ១០០ម៉ែត្រពីទីនោះ។

អ្នកទាំងនេះត្រូវបានពួកខ្មែរក្រហមដឹកមកពីគ្រប់សហករណ៍ ដើម្បីយកមកសម្លាប់នៅក្នុងត្រពាំងវាលបាក់ជញ្ជីង។ អ្នកទាំងនោះមានទាំងក្មេងចាស់ ស្រី និងប្រុស។ យើងខ្ញុំនឹងបង្ហាញជូនផងដែរនូវភស្តុតាងនៃការសម្លាប់រង្គាលទៅលើអ្នកជម្លៀសចំនួន៣០០នាក់ ដែលជាប្រជាជនភូមិភាគបូព៌ានៅទីតាំងវត្តច័ន្ទរង្សី នៅក្នុងភូមិរំលេច។ នេះគឺជាអ្វីដែលសាក្សីមួយរូបពិពណ៌នាអំពីការកត់សម្គាល់របស់គាត់ក្នុងឆ្នាំ១៩៧៩ ពាក់ព័ន្ធនឹងទិដ្ឋភាពក្នុងរណ្ដៅសាកសពរួមនៃការសម្លាប់រង្គាល។ សាកសពបានស្អុយរលួយ និងសម្លៀកបំពាក់នៅរាយប៉ាយពាសពេញវាលស្រែ ក្រមាពណ៌ខៀវនៅមិនទាន់ពុកផុយដែលធ្វើឱ្យយើងស្គាល់ថា អ្នកដែលគេសម្លាប់ទាំងនោះគឺជាប្រជាជនមកពីខេត្តព្រៃវែង និងស្វាយរៀង។ រណ្ដៅសាកសពនៅកូនត្នោតនៅមានរហូតមកដល់សព្វថ្ងៃនេះ។

[១៥:១១:៤៧]

លោកលោកស្រីចៅក្រមជាទីគោរព ការបោសសម្អាតនៅភូមិភាគបូព៌ាសបញ្ជាក់ឲ្យឃើញនូវចំណុចកំពូលនៃភាពវង្វេងស្មារតីក្នុងការកម្ទេចខ្មាំងរបស់មេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា។ យើងខ្ញុំនឹងបង្ហាញភស្តុតាងឲ្យឃើញថាឧក្រិដ្ឋកម្មដ៏អសោចទាំងនេះ គឺកើតឡើងដោយសារជំងឺមិនទុកចិត្តគ្នារបស់មេដឹកនាំដែលរួមមានជនជាប់ចោទផង ដោយគេគិតថាខ្មាំងបានជ្រៀតចូលក្នុងជួរបក្ស។ ទ្រង់ទ្រាយនៃប្រតិបត្តិការនេះឆ្លុះបញ្ចាំងឲ្យឃើញនូវការពិតមួយដែលបញ្ជាក់បានថាជាការបញ្ជា និងការចាត់តាំង គឺធ្វើឡើងដោយមេដឹកនាំរបស់បក្ស។ កម្មាភិបាលជាន់ខ្ពស់ជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជាគឺជាអ្នករាយការណ៍ដោយផ្ទាល់ទៅមជ្ឈិមបក្ស និងមានវត្តមានផ្ទាល់ និងបានដឹកនាំប្រតិបត្តិការប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា។

[១៥:១២:៤០]

ដូចខ្ញុំបានបញ្ជាក់មុននេះបន្តិចរួចមកហើយ សក្ខីកម្មរបស់សាក្សីម្នាក់បានថា “នួន ជា បានចូលរួមចំណែកដោយផ្ទាល់ក្នុងការណែនាំយោធា” ការបោសម្អាតនៅភូមិភាគបូព៌ាគឺជាទិដ្ឋភាពនៃសោកនាដកម្ម

ចុងក្រោយមួយ ក្នុងការអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានធ្វើឱ្យមនុស្សរាប់រយពាន់នាក់បានស្លាប់បាត់បង់ជីវិត។

យើងខ្ញុំនឹងបង្ហាញឱ្យឃើញផងដែរថា ជនជាប់ចោទបានចូលរួមយ៉ាងសកម្មក្នុងផែនការឧក្រិដ្ឋដែលបណ្ដាលឱ្យកើតមានឧក្រិដ្ឋកម្មទាំងនេះ និងបង្ហាញឱ្យឃើញថាជនជាប់ចោទត្រូវតែទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។

[១៥:១៣:២៤]

ការកំណត់បទចោទនិងសេចក្ដីសន្និដ្ឋានៈ

លោក លោកស្រី ចៅក្រមជាទីគោរពខ្ញុំនឹងបញ្ចប់ការសន្និដ្ឋានរបស់ខ្ញុំបន្ទាប់ពីរៀបរាប់ត្រួសៗអំពីការកំណត់បទល្មើសដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទ។ ជនជាប់ចោទម្នាក់ៗគឺសុទ្ធតែត្រូវបានចោទប្រកាន់ដាច់ដោយឡែកពីគ្នា ពីបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម ដោយអនុលោមតាមមាត្រា៤ មាត្រា៥ និងមាត្រា៦ នៃច្បាប់ អ.វ.ត.ក។ ការកម្ទេចជនជាតិវៀតណាម និងជនជាតិចាមបង្កើតបានជាបទប្រល័យពូជសាសន៍ដែលមានចែងនៅក្នុងមាត្រា៤ នៃច្បាប់ អ.វ.ត.ក។ ជនជាប់ចោទបានចូលរួមយ៉ាងច្រើនក្នុងផែនការឧក្រិដ្ឋដែលបណ្ដាលឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនេះកើតឡើង ហើយជនជាប់ចោទមានចេតនាធ្វើដូច្នេះ ដើម្បីកម្ទេចក្រុមជាតិពន្ធទាំងពីរនេះ។ ភស្តុតាងនឹងបង្ហាញឱ្យលើសពីវិមតិសង្ស័យថា ចារីផ្ទាល់ក្នុងការសម្លាប់នេះ បានប្រព្រឹត្តតាមបញ្ជារបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ បញ្ជាចេតនាកម្ទេចក្រុមទាំងពីរនេះឱ្យផុតពូជ និងបង្កើតសង្គមមួយដែលបរិសុទ្ធគ្មានជាតិពន្ធពីរទេ។

[១៥:១៤:៣៩]

ភស្តុតាងនឹងបង្ហាញឱ្យឃើញផងដែរថា ធាតុផ្សំចាំបាច់ផ្នែកយុត្តាធិការដែលមានចែងក្នុងមាត្រា ៤ នៃច្បាប់ អ.វ.ត.ក ចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិត្រូវបានបំពេញសព្វគ្រប់។ បទឧក្រិដ្ឋមកលើប្រជាជនកម្ពុជាគឺជាផ្នែកមួយនៃការវាយប្រហារទូទៅ និងជាប្រព័ន្ធមកលើប្រជាជនកម្ពុជាទាំងអស់នៅទូទាំងប្រទេស ដែលនៅខែមេសា ឆ្នាំ១៩៧៥ មានប្រជាជនចន្លោះពីប្រាំពីរលានប្រាំបីសែននាក់ ទៅប្រាំបីលានមួយសែននាក់។

ការវាយប្រហារនេះមានលក្ខណៈទូទៅ ដោយមូលហេតុទ្រង់ទ្រាយធំ រយៈពេលយូរ តំបន់ភូមិសាស្ត្រធំ និងជនរងគ្រោះច្រើននាក់។ ការវាយប្រហារនេះប្រើរយៈពេលជាងបីឆ្នាំប្រាំខែ និងម្ភៃថ្ងៃ

និងប្រព្រឹត្តទូទាំងប្រទេស។ ការប្រហារនេះពាក់ព័ន្ធនឹងកងកម្លាំងយោធា និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជារាប់ពាន់នាក់នៅទូទាំងប្រទេស។ ការវាយប្រហាររបស់បក្សកុម្មុយនីស្តកម្ពុជាមកលើកប្រជាជនកម្ពុជាទាំងមូល គឺពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនជាងពីរលាននាក់ឲ្យចាកចេញពីទីប្រជុំជនដោយបង្ខំ និងដាក់ប្រជាជនទាំងអស់ឲ្យទៅជាទាសករនៅក្នុងសហករណ៍ និងការដ្ឋាន មន្ទីរសន្តិសុខជាង ២០០កន្លែងបានដំណើរការ និងដើរតួជាផ្នែកមួយសំខាន់ក្នុងការវាយប្រហារមកលើប្រជាជនស៊ីវិល។

[១៥:១៦:១២]

មនុស្សរាប់រយពាន់នាក់ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ ទទួលរងការធ្វើទារុណកម្ម និងសម្លាប់។ ចំនួនមនុស្សស្លាប់ដោយសារការវាយប្រហារនេះ ត្រូវបានគេប៉ាន់ប្រមាណមានប្រហែលពីចន្លោះមួយលានប្រាំពីរសែននាក់ ទៅពីរលានពីរសែននាក់។ ក្នុងនោះមានមនុស្សប្រហែលប្រាំបីសែននាក់ទៅមួយលានបីសែននាក់បានបាត់បង់ជីវិតដោយហិង្សា។ ការវាយប្រហារមកលើប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា ជាការវាយប្រហារជាប្រព័ន្ធផងដែរ។ ការប្រហារនេះត្រូវបានធ្វើឡើងទៅតាមគោលនយោបាយដែលសម្រេច និងសម្របសម្រួលដោយមជ្ឈិម ដើម្បីប្រព្រឹត្តអំពើហិង្សាដែលមានទ្រង់ទ្រាយធំទូទាំងប្រទេស។

[១៥:១៧:០១]

ការវាយប្រហារនេះបានរៀបចំផែនការ និងចាត់តាំងយ៉ាងច្បាស់លាស់ និងធ្វើតាមបញ្ជាដោយចេញដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលរួមមានជនជាប់ចោទផងដែរ។ ការវាយប្រហារនេះបានកើតឡើងដោយមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងនៅទូទាំងប្រទេស។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានចូលរួមក្នុងបទឧក្រិដ្ឋទាំងនេះនៅគ្រប់កម្រិត និងបានរាយការណ៍អំពីសកម្មភាពរបស់ខ្លួនទៅមជ្ឈិមបក្ស។ ការវាយប្រហារទូលំទូលាយ និងដោយប្រព័ន្ធមកលើប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា គឺមានលក្ខណៈរើសអើងផ្នែកនយោបាយ ដោយសារតែការវាយប្រហារនេះត្រូវបានធ្វើឡើងដោយសំអាងលើមូលហេតុនៃបដិវត្តន៍នយោបាយជ្រុលនិយម។

[១៥:១៧:៥០]

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជារិះរកបំបែកក្រុមនយោបាយ ដែលប្រឆាំងនឹងការដឹកនាំរបស់ខ្លួន។ គេបានចាត់ទុកថា ជនស៊ីវិលណាក៏ដោយក៏អាចថាជាខ្មាំងរបស់ពួកគេ និងបានរើសអើងជនស៊ីវិលទាំងនោះ ដោយសារតែមូលហេតុរើសអើង។ ការវាយប្រហារនេះបានធ្វើឡើងដោយសារតែហេតុផល

សាសនាផងដែរ។ បានបណ្តាលឲ្យមានការលុបបំបាត់ចោលសាសនាទាំងស្រុង។ ជាចុងក្រោយការប្រហារនេះបានធ្វើឡើងដោយសារតែហេតុផលជាតិពន្ធ ដែលពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញ និងការកម្ទេចក្រុមជនជាតិភាគតិច រួមទាំងជនជាតិចាម និងវៀតណាម។

[១៥:១៨:៣២]

សហព្រះរាជអាជ្ញានឹងបង្ហាញនូវភស្តុតាង ដើម្បីបញ្ជាក់ថា ជនជាប់ចោទពិតជាទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ដទៃទៀត។

បទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្តឡើងក្នុងរយៈពេល ដែលមានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅតាមផ្នែកដែលពាក់ព័ន្ធនឹងបណ្តុំនៃព្រឹត្តិការណ៍នីមួយៗ ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយ។ បទឧក្រិដ្ឋទាំងនេះ បានប្រព្រឹត្តឡើងទៅតាមផែនការរួម ដែលជនជាប់ចោទបានព្រមព្រៀង និងបានចូលរួមយ៉ាងច្រើន។

[១៥:១៩:១៩]

យោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ គោលបំណងរួមនៃពាក់ព័ន្ធនឹងគោលនយោបាយដូចខាងក្រោម។ ការជម្លៀសប្រជាជនច្រើនលើកច្រើនសា ការបង្កើត និងដាក់ឲ្យដំណើរការសហករណ៍ និងការដ្ឋានការងារ ការអប់រំកសាងសមាសភាពមិនល្អ និងការសម្លាប់ខ្មាំង ទាំងនៅក្នុងជួរបក្ស និងក្រៅជួរបក្ស។ ការកំណត់គោលដៅពិសេស រួមទាំងជនជាតិចាម វៀតណាម និងពុទ្ធសាសនិកជន ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជនជាប់ចោទបានរួមគ្នាបង្កើត និងអនុវត្តគោលនយោបាយទាំងអស់នេះ ហើយបានដឹងយ៉ាងច្បាស់ពីបច្ច័យរបស់វា។

[១៥:២០:០០]

ជនជាប់ចោទបានដាក់ឲ្យអនុវត្តប្រព័ន្ធរាយការណ៍ដ៏តឹងរ៉ឹងមួយ ដើម្បីធានាថាកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជានៅគ្រប់កម្រិតជូនដំណឹងឲ្យពួកខ្លួនបានដឹងជាប់ជានិច្ច អំពីការអនុវត្តគោលនយោបាយរបស់ខ្លួន។ ដូច្នេះ ជនជាប់ចោទពិតជាត្រូវបានជូនដំណឹងជាប្រចាំអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មនៅទូទាំងប្រទេសរួមទាំងបទឧក្រិដ្ឋ ដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជនជាប់ចោទគឺជាកម្លាំងចលករនៅពីក្រោយសហកម្មឧក្រិដ្ឋកម្មរួម និងជាអ្នកចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តក្នុង

សកម្មភាពទាំងនេះ។ ដោយសារតែមូលហេតុនេះ ពួកគេត្រូវតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋនីមួយៗ និងរាល់បទឧក្រិដ្ឋទាំងអស់ដែលត្រូវបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[១៥:២០:៥៤]

ជនជាប់ចោទ ទទួលខុសត្រូវផងដែរចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុញ្ញាទីក្រុងហ្សឺណែវ ដែលមានចែងនៅក្នុងមាត្រា៦ នៃច្បាប់ អ.វ.ត.ក។ ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ដែលបានកើតឡើងរវាងខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ឧក្រិដ្ឋកម្មទាំងនេះរួមមាន មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តអំពើអមនុស្សធម៌ និងការឃុំខ្លួនដោយខុសច្បាប់។ ជនរងគ្រោះជាជនស៊ីវិល និងឈ្លើយសឹកវៀតណាម ដែលមានឋានៈជាជនដែលទទួលរងបានការការពារដោយអនុសញ្ញានៃទីក្រុងហ្សឺណែវ។ ឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃកងកម្លាំងយោធា និងកម្មាភិបាលផ្នែកសន្តិសុខធ្វើតាមបញ្ជារបស់ជនជាប់ចោទ។

[១៥:២១:៤៩]

ជាថ្មីម្តងទៀត ភស្តុតាងនឹងបង្ហាញឲ្យឃើញថា ជនជាប់ចោទបានចូលរួមចំណែកក្នុងផ្នែកផែនការឧក្រិដ្ឋដែលនាំឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះឡើង។ ដូច្នេះ គេត្រូវតែទទួលខុសត្រូវចំពោះការប្រព្រឹត្តទាំងនេះ។

លោក លោកស្រីចៅក្រម ជាទីគោរព! ភស្តុតាងដែលលោក លោកស្រីចៅក្រមនឹងធ្វើសវនាការនឹងបង្ហាញឲ្យឃើញថា របបដែលត្រូវបានដឹកនាំដោយជនជាប់ចោទ គឺជារបបមួយដ៏សែនឃោរឃៅ និងមហាភ័យរន្ធត់មួយនៅក្នុងប្រវត្តិសាស្ត្រនៃយុគសម័យទំនើបនេះ។ ក្នុងរយៈពេលបីឆ្នាំប្រាំបីខែ និងម្ភៃថ្ងៃ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ប្រជាជនទាំងអស់ឲ្យទៅជាទាសករ។ មានមនុស្សមួយនាក់ក្នុងចំណោមបួននាក់បានស្លាប់បាត់បង់ជីវិតក្រោមការដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា។ ការបង្ខំឲ្យចាកចេញពីលំនៅដ្ឋាន ព្រាត់ប្រាសគ្រួសារ ត្រូវគេដកហូតសិទ្ធិសេរីភាពក្នុងការដើរហើរ និយាយស្តី និងសាសនា ធ្វើការដោយបង្ខំ ការបង្អត់អាហារ រងនូវការធ្វើទារុណកម្ម និងវាយដំ រស់នៅក្នុងស្ថានភាពខ្លាចគេយកទៅសម្លាប់ជាប្រចាំ និងការដកហូតលែងឲ្យមានអត្តសញ្ញាណនៃសេចក្តីថ្លៃថ្នូរជាមនុស្ស។ ទាំងអស់នេះ គឺជាសុបិនអាក្រក់មួយដែលបានក្លាយជាការពិតដែលកើតមានចំពោះប្រជាជនកម្ពុជាទូទៅរាប់លាននាក់ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់

ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ជនកម្ពុជាគ្រប់រូបដែលបានរស់ឆ្លងកាត់របបនោះ គឺសុទ្ធតែបានទទួលរងផលប៉ះពាល់ដោយសារតែគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៥:២៣:៤៤]

បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ក្នុងករណីនេះ គឺជាបទឧក្រិដ្ឋដែលតំណាងឲ្យសេចក្តីរងទុក្ខវេទនា សូម្បីតែកន្លែងដែលកើតហេតុមានចំនួនជាក់លាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះយ៉ាងណាក្តី ក៏សេចក្តីរងទុក្ខវេទនា និងការឈឺចាប់ដែលត្រូវបានគេប្រព្រឹត្តមកលើជនរងគ្រោះមានទំហំធំធេងណាស់។ ស្នាមរបួសដែលប្រទេសនេះបានទទួលរងគ្រោះ នឹងត្រូវប្រើពេលច្រើនជំនាន់ដើម្បីព្យាបាល។

បច្ច័យដែលគួរឲ្យខ្លោចផ្សាដែលកើតឡើងពីបទឧក្រិដ្ឋ ដែលប្រព្រឹត្តឡើងដោយរបបនៃបក្សកុម្មុយនីស្តកម្ពុជា គឺរងគ្រោះរាប់រយពាន់នាក់ដែលបានស្លាប់កប់ក្នុងដីនៅកន្លែងដែលពុំមាននរណាដឹងដែលក្រុមគ្រួសារ និងសាច់ញាតិមិនអាចគាស់យកអដ្ឋិធាតុ និងកំណត់អត្តសញ្ញាណ និងធ្វើពិធីបុណ្យដើម្បីបញ្ចុះអដ្ឋិធាតុឲ្យបានត្រឹមត្រូវទេ។ រហូតមកដល់សព្វថ្ងៃនេះនៅមានប្រជាជនរាប់ពាន់នាក់ នៅបន្តឈឺចាប់ដោយពុំដឹងថា តើសាច់ញាតិ និងមិត្តភក្តិរបស់ខ្លួនបានស្លាប់បាត់បង់ជីវិតនៅទីកន្លែងណាមួយនៅឡើយទេ? ទោះបីយ៉ាងណាក៏ដោយការជំនុំជម្រះក្តីនេះ មិនមែនជាការសងសឹកទេ ការជំនុំជម្រះក្តីនេះ គឺជាការស្វែងរកការពិត និងការកំណត់អំពីពិរុទ្ធភាព។ នៅក្នុងដំណើរការនេះ ជនជាប់ចោទមានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ពួកគេមានសិទ្ធិទទួលបាននូវសន្មតថាគ្មានទោស និងសិទ្ធិទទួលបានមេធាវីការពារក្តីដែលខុសពីប្រជាជនកម្ពុជារាប់លាននាក់ ដែលបានទទួលរងទុក្ខវេទនានៅក្រោមកណ្តាប់ដៃនៃបក្សកុម្មុយនីស្តកម្ពុជា។

[១៥:២៥:២៨]

យើងនឹងបង្ហាញភស្តុតាងឲ្យឃើញថា ជនជាប់ចោទមានពិរុទ្ធភាពនៅក្នុងតុលាការនេះ ដែលប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិបានព្រមព្រៀងគ្នាបង្កើតឡើង ដើម្បីធានាក្នុងការផ្តល់នូវភាពយុត្តិធម៌មួយជូនប្រជាជនកម្ពុជារាប់លាននាក់ ដែលបានរងទុក្ខវេទនា។ យើងនឹងជួយបរិច្ចាគនូវចំណែកតូច ប៉ុន្តែសំខាន់ដើម្បីជួយធ្វើឲ្យស្នាមរបួសរបស់ប្រជាជនបានជាសះស្បើយ។ យើងនឹងផ្ញើសារមួយដល់ឧក្រិដ្ឋជន និងចារីដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនេះ នៅជុំវិញពិភពលោកឲ្យបានដឹងថា យុត្តិធម៌មិនភ្លេចទេ។ សំខាន់ជាងនេះ យើងខ្ញុំនឹងធានាឲ្យបានថា ពិតជាត្រូវបានលាតត្រដៀង និងយុត្តិធម៌ត្រូវតែឈ្នះ។

[១៥:២៦:១៤]

ពុទ្ធដីការបស់ព្រះពុទ្ធថា "យកឈ្នះលើភាពខឹងសម្បា ដោយការខន្តី យកឈ្នះលើមនុស្សអាក្រក់ ដោយអំពើល្អ យកឈ្នះលើមនុស្សកំណាញ់ ដោយចិត្តសម្បុរសធម៌ យកឈ្នះលើមនុស្សកុហក ដោយការពិត"។

ចាស, សូមអរគុណ ហើយលោក-- សុំលោកប្រធាន លោក លោកស្រីចៅក្រម ឥឡូវនេះ ខ្ញុំនឹងអនុញ្ញាតប្រគល់ទៅឲ្យសហការីរបស់ខាងអន្តរជាតិរបស់ខ្ញុំ គឺលោក អាន់ឌ្រូ ខេលី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកជំទាវ សហព្រះរាជអាជ្ញាជាតិ។ បាទ, ជាបន្ត សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ បាទ។

[១៥:២៧:០៥]

**លោក អាន់ឌ្រូ ខេលី៖**

សូមគោរពលោកតុលាការ លោក លោកស្រីចៅក្រម ជាទីគោរព! ខ្ញុំយល់ឃើញថានៅក្នុងពេលចុងក្រោយសម្រាប់ថ្ងៃនេះ ខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ហើយមុននឹងខ្ញុំចាប់ផ្តើម ខ្ញុំសូមអនុញ្ញាតពន្យល់អ្វីដែលខ្ញុំនឹងពន្យល់នៅក្នុងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់នេះ។ ជាពិសេស ការបែងចែករវាងលោកជំទាវ ជា លាង ហើយនិងខ្ញុំ ដែលថាលោកស្រីនឹងពិភាក្សាអំពីមូលដ្ឋានបទល្មើស ហើយខ្ញុំនឹងផ្តោតអារម្មណ៍ទៅលើតួនាទី ហើយនិងការទទួលខុសត្រូវរបស់ជនជាប់ចោទ។ ខ្ញុំនឹងនិយាយអំពីតួនាទីរបស់ជនជាប់ចោទ មុនឆ្នាំ១៩៧៥។ តួនាទីរបស់ពួកគាត់ មុនឆ្នាំ១៩៧៥ រហូតទៅដល់១៩៧៩។

រចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយការអនុវត្តនូវគោលនយោបាយប្រាំយ៉ាង ដែលចែងនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះ ហើយនិងនិយាយអំពីកថាខណ្ឌទីមួយ នៃដីការបស់លោក លោកស្រីចៅក្រម ទីមួយនៅក្នុងឆ្នាំ២០១១ ដែលត្រូវលើកឡើងនៅក្នុងដីកាសន្និដ្ឋានបើកការចោទប្រកាន់នេះ។

[១៥:២៨:៣៤]

ខ្ញុំសូមអនុញ្ញាតចាប់ផ្តើម រឿងក្តីនៅចំពោះសវនាការ ហើយនិងលោក លោកស្រី សម្រេចនេះគឺផ្អែកទៅលើគោលការណ៍ច្បាប់ និងគោលការណ៍សីលធម៌ដ៏រឹងមាំ ដែលថាមនុស្សម្នាក់ៗ បុរស ស្ត្រី

កុមារ នៅគ្រប់ទីកន្លែងទាំងអស់ គឺជាមូលដ្ឋាននៃតម្លៃដែលចែងនៅក្នុងសង្គម ដែលថារដ្ឋ ហើយនិងសង្គមត្រូវតែបម្រើផលប្រយោជន៍ ហើយមិនមែនជាអត្ថប្រយោជន៍របស់អ្នកគ្រប់គ្រងទេ។ អ្នកទាំងអស់គ្នានោះ គឺថាសិទ្ធិរបស់ពលរដ្ឋ សិទ្ធិសេរីភាព ហើយនិងសុវត្ថិភាពមិនមែនកើតចេញអំពីសេចក្តីសម្បុរសរដ្ឋទេ តែផុសចេញពីច្បាប់។ លើសពីអ្វីៗទាំងអស់ រឿងក្តីនេះនឹងបង្ហាញ និងរំឭកពិភពលោកអំពីកំហុស និងសេចក្តីអាណិតរបស់បុគ្គលក្នុងការលើកឡើង លើកតម្កើង និងសរសើររដ្ឋ សេចក្តីត្រូវការ ផែនការ គោលដៅ និងអំពើផ្តួតលើលាខ្ពស់ជាងសេចក្តីត្រូវការ និងសិទ្ធិរបស់មនុស្សលោកម្នាក់ៗ។

[១៥:២៩:៥៤]

ជនជាបចោទទាំងបីរូប ចំពោះមុខលោក លោកស្រីចៅក្រមនេះ គឺជាជនចាស់ជរា។ អាយុច្រើនរបស់ពួកគេអាចជាការប៉ុនប៉ងសុំការអាណិតអាសូរ ឬសេចក្តីមេត្តា។ ប៉ុន្តែសូមយើងកុំបំភ្លេចឲ្យសោះថា មរតកមហន្តរាយដែលជនចាស់ជរាទាំងបីនេះបានប្រព្រឹត្តឡើង។ នៅក្នុងរយៈពេលតិចជាងបួនឆ្នាំ ពួកគេបានដកហូតចេញពីពលរដ្ឋកម្ពុជានូវសេចក្តីថ្លៃថ្នូរសេរីភាព ដែលជាសិទ្ធិពីកំណើត ហើយនិងសិទ្ធិដែលយើងមិនអាចដកហូតបានពីមនុស្សលោកម្នាក់ៗ។ ពួកគេបានកាប់សម្លាប់ធ្វើទារុណកម្មបំភិតបំភ័យប្រជាពលរដ្ឋរបស់ខ្លួន។ ពួកគេអនុវត្តកម្មវិធីកំណែទម្រង់ជ្រុលនិយម ពួកគេបានប្តូរ និងប្រើប្រាស់ធនធានមនុស្ស និងសម្ភារៈដើម្បីបង្កើតសុបិនអាក្រក់សម្រាប់ប្រជាពលរដ្ឋខ្មែរទាំងមូល។

[១៥:៣០:៥០]

ពួកគេបានដកចេញពីប្រជាពលរដ្ឋនូវអ្វីៗទាំងអស់ ដែលធ្វើឲ្យគេអាចរស់រានបាន គ្រួសារ ជំនឿ ការអប់រំ ទីកន្លែងចិញ្ចឹមកូន ទីកន្លែងសម្រាក ដូចជា កន្ទេល ពូក ខ្នើយ។ ពួកគេបានបង្អត់អាហារដាក់ប្រជាជនទៅជាទាសករ។ ពួកគេបានស្វែងរកខ្មាំងដែលគេថា ជាខ្មាំងរបស់ប្រទេស បញ្ញវន្ត មូលធនវណ្ណៈកណ្តាល សមាជិកនៃរបបចាស់ដែលគេហៅថា ជាខ្មាំង។ ចាម វៀតណាម ក៏គេចាត់ជាគោលដៅនៃការបំផ្លិចបំផ្លាញ។ ពួកគេហាមឃាត់សេចក្តីស្នេហារវាងមនុស្ស និងមនុស្ស ដែលនេះជាគុណភាពដ៏ឧត្តម ដែលស្ថិតនៅក្នុងដួងចិត្តមនុស្សខ្លាំងជាងអ្វីៗទាំងអស់។ យើងកុំបំភ្លេចនៅក្នុងករណីនេះគឺសវនាការនេះចូរយើងកុំបំភ្លេចថា ការហាមឃាត់ទាំងនេះគឺជាកម្លាំងដ៏អាក្រក់ ហើយជាអំពើដែលប្រព្រឹត្តឡើងដោយជនចាស់ជរាទាំងបីរូបនេះឯង។

[១៥:៣១:៥៧]

មុនខ្ញុំ សូមអនុញ្ញាតលើកឡើងពីកម្មវត្ថុនៃរឿងក្តីនេះ ខ្ញុំសូមជម្រាបជូនលោក លោកស្រីចៅក្រម និងសាធារណជនអំពីមូលដ្ឋានទូលំទូលាយ នៃច្បាប់តុលាការនេះ។ តុលាការនេះតាមពិតគឺជាស្ថាប័ន របស់តុលាការក្រោមច្បាប់កម្ពុជា ហើយនិងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ។ តុលាការនេះ អនុវត្តនូវក្រមព្រហ្មទណ្ឌកម្ពុជា ហើយនិងក៏ត្រូវអនុវត្តនូវខបញ្ញត្តិជាច្រើន នៃច្បាប់មនុស្សធម៌អន្តរជាតិ ផងដែរ អ្វីដែលគេហៅថា ជាច្បាប់ព្រហ្មទណ្ឌអន្តរជាតិទំនើបនោះ។ អ្វីជាប្រភពនៃបទប្បញ្ញត្តិអន្តរជាតិ ទាំងអស់នេះ? នៅក្នុងឆ្នាំ១៩៤១ នៅពេលដែលសង្គ្រាមលោកលើកទីពីរ ឈានដល់កំពូលនោះ មានកិច្ច ប្រជុំមួយនៅលើនាវាចម្បាំង នៅជិតសមុទ្រមួយនៅញូវហ្វោនឡែន ប្រទេសកាណាដា។ នៅក្នុងកិច្ច ប្រជុំនេះគឺប្រធានាធិបតីសហរដ្ឋអាមេរិកឈ្មោះថា ហ្វ្រង់គ្លែន ដាណេល្លូរ៉ូស្វែល *(Franklin Delano Roosevelt)* ហើយនិងនាយករដ្ឋមន្ត្រីអង់គ្លេសឈ្មោះថា សឺវិលសុន ឆឺឈីល *(Winston Churchill)*។

[១៥:៣៣:១២]

ក្នុងចំណោមបញ្ហាទាំងអស់នោះ បុគ្គលពីរនាក់នេះបានរៀបចំសេចក្តីព្រាងមួយទំព័រ ដែលគេ ហៅថា "ធម្មនុញ្ញអាត្លង់ទិក" ដែលបានទទួលស្គាល់នៅពេលនោះថា រដ្ឋគឺមិនត្រូវមិនគោរពច្បាប់នោះ ទេ ហើយមិនត្រូវបង្កច្បាប់ធ្វើមនុស្សឃាត ទារុណកម្មប្រជាជនរបស់ខ្លួនឯងដោយគ្មានពិរុទ្ធភាពនោះ ទេ។ ពួកគេបានប្តេជ្ញាចងក្រងគំនិតយល់ឃើញទាំងនេះ ទៅជាគោលការណ៍រួមសម្រាប់សណ្តាប់ធ្នាប់ ពិភពលោក។ ធម្មនុញ្ញនេះមានសរសរទ្រូងសំខាន់ៗបី ដែលថិតនៅក្នុងការប្តេជ្ញាចិត្តគោរពសិទ្ធិមនុស្ស ហើយនិងការគោរពនូវសេចក្តីថ្លៃថ្នូរ និងសិទ្ធិស្មើភាពគ្នាចំពោះសមាជិក នៃមនុស្សលោក។

[១៥:៣៤:០២]

ក្នុងរវាងឆ្នាំ១៩៤១ និងឆ្នាំ១៩៤៩ ធម្មនុញ្ញអាត្លង់ទិច ត្រូវបានដាក់បញ្ចូលទៅក្នុងធម្មនុញ្ញអង្គការ សហប្រជាជាតិឆ្នាំ១៩៤៥ និងសេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្សឆ្នាំ១៩៤៨ អនុសញ្ញាប្រល័យ ពូជសាសន៍ឆ្នាំ១៩៤៨ អនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ធម្មនុញ្ញតុលាការនូរឹមប៊ឺក ហើយនិងធម្មនុញ្ញ តុលាការយោធាឆ្នាំ១៩៤៥ ហើយកាត់ក្តីរបបណាហ្ស៊ីពួកឧក្រិដ្ឋជនរបបណាហ្ស៊ី។ លិខិតុបករណ៍ទាំង អស់នេះ និងច្បាប់ទាំងអស់នេះបានបញ្ជាក់ អំពីគោលការណ៍មូលដ្ឋាននៃសិទ្ធិមនុស្ស ការទប់ស្កាត់ ហើយនិងការដាក់ទណ្ឌកម្មបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ប្រល័យពូជសាសន៍ ហើយកម្រិតអំពីវិធី សាស្ត្រសង្គ្រាម។ នៅទីបំផុត គឺការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ នឹងត្រូវដាក់ទៅលើអ្នកប្រព្រឹត្ត បទឧក្រិដ្ឋ និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ ដូច្នេះ ចូរយើងកុំទទួលរងគ្រោះពីការអះអាងដែលថា

មិនមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះទាំងនោះ។ យើងកំពុងចេញដំណើរតាមគន្លងច្បាប់ដែលមិនធ្លាប់មានពីមុនមក។ នៅក្នុងករណីភាគច្រើន មានទំហំធំធេងជាងអ្វីៗដែលមានពីមុនៗ ប៉ុន្តែសំខាន់បំផុត គឺជនរងគ្រោះ ពលរដ្ឋនៃរាជាណាចក្រនេះបានរង់ចាំជាយូរណាស់មកហើយ ជាពិសេសមួយជំនាន់មនុស្សរង់ចាំឲ្យកង់ប្រវត្តិសាស្ត្រយុត្តិធម៌វិលទៅមុខ។ ឆន្ទៈនេះគឺថាមិនមានបញ្ហាអ្វីឲ្យឆ្ងល់ទេ គឺថាការជំនុំជម្រះដ៏ធំធេងនៅក្នុងពិភពលោកហ្នឹង គឺបានកើតឡើង ប្រហែលថាមានតែការជំនុំជម្រះបីទេនៅក្នុងយុត្តិសាស្ត្រអន្តរជាតិ ដែលអាចប្រៀបធៀបអំពីទំហំនៃរឿងក្តីដែលស្ថិតនៅក្នុងចំពោះមុខលោក លោកស្រីចៅក្រមនៅពេលនេះ។ គឺការជំនុំជម្រះនៃមេដឹកនាំរបបណាហ្ស៊ី រវាងឆ្នាំ១៩៤៥ និងឆ្នាំ១៩៤៦ ការជំនុំជម្រះអ្នកដែលទទួលខុសត្រូវបទប្រល័យពូជសាសន៍លើជនជាតិទូតស៊ី ប្រាំមួយសែននាក់នៅក្នុងប្រទេសរវ៉ាន់ដាក្នុងឆ្នាំ១៩៩៤។ ហើយនិងការជំនុំជម្រះរបស់ ស្លូបូដាន មីឡូសឺវិច អតីតប្រធានាធិបតីយូហ្គោស្លាវី ឆ្នាំ២០០២ និងឆ្នាំ២០០៦។

[១៥:៣៦:៤២]

ការជំនុំជម្រះទាំងអស់នេះ ដែលលោក លោកស្រីចៅក្រមត្រូវវិនិច្ឆ័យនោះ គឺទាក់ទងទៅនឹងជនរងគ្រោះ១.៧ ឬ២លាននាក់។ ការចោទប្រកាន់ប្រឆាំងជនជាប់ចោទទាំងអស់ គាំទ្រដោយសំណុំរឿងដែលមានឯកសាររាប់រយពាន់ទំព័រ ហើយនិងចម្លើយសាក្សី និងភស្តុតាងផ្សេងៗទៀតជាច្រើន។ក្នុងចំណោមខ្មែរបួននាក់ មានម្នាក់ដែលត្រូវបានកម្ទេចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នេះគឺជាអំពើដែលមិនធ្លាប់កើតមានចំពោះប្រជាជាតិ ដែលថាការកាប់សម្លាប់ ការដាក់ឲ្យទៅជាទាសករ គឺជាអំពើនៅក្នុងកោះមីឡូស ដែលកើតឡើង២៤០០ឆ្នាំកន្លងមកហើយ។ នៅពេលដែលយើងវិនិច្ឆ័យនូវគំនិតគឺថាពួកសមាមាត្រនៃប្រជាពលរដ្ឋដែលបានស្លាប់ដោយការសម្លាប់ គឺមានទំហំធំធេងដែលប្រព្រឹត្តឡើងដោយជនជាប់ចោទទាំងនេះ គឺគ្មានអ្វីប្រៀបបានទេនៅក្នុងសម័យទំនើបនេះ។

សូមយើងច្បាស់ទាំងអស់គ្នាចាប់ពីចំណុចផ្តើមនេះ ឧក្រិដ្ឋភាពដែលបានកើតឡើងក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ មិនមែនជាការចៃដន្យ ឬក៏កើតឡើងដោយឯកឯងនោះទេ។ ផែនការដែលនាំឲ្យមរណភាពប្រជាជនពីរលាននាក់ ហើយនិងការបំផ្លិចបំផ្លាញនៃប្រទេសនេះត្រូវបានត្រៀមរៀបចំ ហើយនិងគ្រោងទុកជាយូរមុនឆ្នាំ១៩៧៥។

[១៥:៣៨:១៦]

ការជម្លៀសដោយបង្ខំ ការដាក់ជាទាសករ ឃាតកម្ម អំពើហិង្សា ត្រូវបានអនុវត្តទៅលើខ្មាំង

របស់បក្សកុម្មុយនីស្តកម្ពុជា ហើយការអនុវត្តនូវអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាលទ្ធផលនៃការរៀបចំផែនការដោយជនចាស់ជរាទាំងបីនាក់នេះ។ ហើយជាលទ្ធផលនៃវិធីសាស្ត្រយ៉ាងច្បាស់បំផុតដែលមិនធ្លាប់ពីមុន ហើយបានគ្រោងទុកជាមុននោះទៀតផង។ កម្មវត្ថុសំខាន់នៃរឿងក្តីប្រឆាំងនឹងជនជាប់ចោទនេះ គឺជាបញ្ហាសាមញ្ញ និងច្បាស់។ ក្នុងឋានៈខ្លួនជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជានួន ជា អៀង សារី និងខៀវ សំផន បានបង្កើត និងអនុវត្តនូវគោលការណ៍ឧក្រិដ្ឋនៅក្នុងប្រទេសជាតិទាំងមូល ហើយបណ្តាលឲ្យមរណភាពដល់ប្រជាជនជាងពីរលាននាក់ ហើយនិងដាក់ឲ្យប្រជាពលរដ្ឋរបស់ខ្លួនស្ថិតនៅក្នុងអំពើដ៏អមនុស្សធម៌បំផុត។

[១៥:៣៩:១១]

ជនជាប់ចោទបានធ្វើផែនការឧក្រិដ្ឋនេះជាមួយគ្នាទាក់ទងទៅនឹងបញ្ហានោះ គឺតាំងពីទសវត្សរ៍ឆ្នាំ ១៩៥០ និង១៩៦០។ នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ មេសា ១៩៧៥ រហូតទៅដល់៧ មករា ១៩៧៩ នៅពេលដែលខ្លួនមានអំណាចនោះ ពួកគេរស់នៅ និងធ្វើការជាមួយគ្នាអនុវត្តគោលនយោបាយនៅក្នុងឋានានុក្រមរចនាសម្ព័ន្ធខ្ពស់បំផុត ហើយទទួលរបាយការណ៍ពីថ្នាក់ក្រោម ហើយនិងផ្តល់ការណែនាំដោយផ្ទាល់ទៅអ្នកទាំងអស់នោះ ដូចដែលបានឃើញក្នុងរូបថតដែលថាបុគ្គលទាំងបីរូបនេះ គឺបានចូលរួមនៅក្នុងមហាមិទ្ទីងរបស់គេ។ ប្រធានបទពីរដែលនឹងលើកឡើងនៅក្នុងការជំនុំជម្រះនេះ ទីមួយគឺការណែនាំ ហើយនិងការត្រួតត្រាដ៏ងប់ងុលទៅលើទិដ្ឋភាពទាំងអស់នៃជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទីពីរ គឺការយល់ដឹងរបស់ពួកគាត់អំពីបទឧក្រិដ្ឋដែលប្រព្រឹត្តទៅនៅក្រោមការណែនាំរបស់គេ និងក្នុងនាមរបស់ពួកគេនោះ។

[១៥:៤០:១៦]

សហព្រះរាជអាជ្ញាជាតិបានរៀបចំអំពើឃោរឃៅ ដែលមានការរៀបចំរបស់កម្ពុជាប្រជាធិប-តេយ្យថា ជាសហឧក្រិដ្ឋកម្មរួមដែលមានគោលនយោបាយសំខាន់ប្រាំយ៉ាងដូចខាងក្រោមនេះ ដែលរួមមាន៖ ទី១) ការប្តូរទីលំនៅដោយបង្ខំនូវប្រជាពលរដ្ឋកម្ពុជាចេញពីរដ្ឋធានីទីប្រជុំជនទៅទីជនបទ ទី២) ការដាក់ទៅជាទាសករនូវពលរដ្ឋកម្ពុជាឲ្យទៅធ្វើការតាមការដ្ឋាន សហករណ៍កសិកម្មនានា។ ទី៣) ការប្រើប្រាស់អំពើហិង្សាដើម្បីលុបបំបាត់ ឬកម្ទេចខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាតាមបណ្តាញអប់រំកែប្រែ ឬមន្ទីរសន្តិសុខទូទាំងប្រទេស។ ទី៤) ការកំណត់ទិសដៅ ឬក៏ការធ្វើទុក្ខបុកម្នេញក្រុមមនុស្សជាក់លាក់រួមទាំងពុទ្ធសាសនិកជនចាម ហើយនិងជនជាតិភាគតិចវៀតណាម។ និងទី៥) ការអនុវត្ត

នូវអាពាហ៍ពិពាហ៍ដោយបង្ខំជាមធ្យោបាយដើម្បីសម្រេចបានកំណើនប្រជាពលរដ្ឋ។

យើងដឹងប្រាកដថាតាមមតិរបស់យើង គឺក្នុងចំណោមមនុស្សទាំងបីរូបនៃជនជាប់ចោទនេះ គាត់នឹងអះអាងថា មិនមានសហកម្មឧក្រិដ្ឋកម្មរួមនោះទេ។ បើសិនជាមានមែនក៏ពួកគេមិនបានចូលរួមដែរ ប៉ុន្តែភស្តុតាងនឹងបង្ហាញផ្ទុយពីនេះដែលខ្ញុំនឹងជម្រាបជូនលោកលោកស្រីចៅក្រម។

[១៥:៤២:០៥]

ខ្ញុំសូមដកស្រង់សម្តីរៀបចំដ៏ល្អរបស់ចៅក្រម រ៉ូប៊ឺត ជេកសិន *(Robert Jackson)* នៅក្នុងតុលាការនូរឹមប៊ឺក ឆ្នាំ១៩៤៦ ខែកក្កដា ដែលជាអាចគំរូនៅក្នុងករណីរបស់យើងបាន។ ខ្ញុំសូមដកស្រង់៖ “ទោះបីជាមានបទល្មើស សមគំនិតក្តីក៏ជនជាប់ម្នាក់ៗប្រកាន់ជំហរចុងក្រោយរស់ខ្លួនថា ខ្លួនមិនបានចូលរួម។ ដូច្នេះ ប្រការ សំខាន់យើងត្រូវពិនិត្យការប៉ុនប៉ងរបស់ពួកគេក្នុងការចៀសវាងពីការទទួលខុសត្រូវជាបឋម ដើម្បីឲ្យដឹងថាការសមគំនិតនិយាយអំពី នឹងត្រូវផ្តន្ទាទោស ដូចម្តេច? ក្នុងបទសមគំនិតយើងមិនផ្តន្ទាទោសបុគ្គលម្នាក់អំពីបទល្មើសរបស់ជនម្នាក់ទៀតទេ។ យើងព្យាយាមផ្តន្ទាទោសម្នាក់ៗពីបទល្មើស ដែលគេបានប្រព្រឹត្តនៃការចូលរួមធ្វើផែនការក្នុងឧក្រិដ្ឋកម្មរួម ដែលជនផ្សេងទៀតបានចូលរួមដែរ។ ដូច្នេះតាមការពិតវិធានការនៃភាពឧក្រិដ្ឋកម្មក្នុងផែនការពិរុទ្ធភាពរបស់ពួកគេម្នាក់ៗ ចំនួនសរុបនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តដោយសមាជិកទាំងអស់ដែលអនុវត្តផែនការ។ ប៉ុន្តែ ខ្លឹមសារនៃបទល្មើសគឺជាការចូលរួមក្នុងការបង្កើតនិងការអនុវត្តផែនការ។ នេះគឺជាវិធានការដែលសង្គមនីមួយៗយល់ឃើញថា មានការចាំបាច់ដើម្បីឈានដល់បុគ្គលមួយចំនួនដូចជាជនជាប់ចោទទាំងនេះ ដែលបាតដៃរបស់ពួកគេមិនដែលប្រឡាក់ឈាមទេ ប៉ុន្តែជាអ្នកធ្វើផែនការដែលបណ្តាលឲ្យមានការបង្ហូរឈាម”។ ចប់សេចក្តីដកស្រង់។

[១៥:៤៣:៤៣]

ជនជាប់ចោទម្នាក់ៗទាំងអស់នេះ មិនបានបង្ហាញថាខ្លួនមានបាតដៃប្រឡាក់ឈាមទេ ប៉ុន្តែពួកគេម្នាក់ៗបានធ្វើផែនការ ហើយបណ្តាលឲ្យមានការបង្ហូរឈាមនៅក្នុងប្រទេសដែលក្លាយទៅជាសមុទ្រ។ ហើយខ្ញុំនឹងសូមឈានចូលទៅពិនិត្យករណីនេះដែលថាមេធាវី
ការពារនឹងបង្វែរការស្តីបន្ទោសទៅលើអ្វីដែលបានកើតឡើងទាំងអស់ថា ជាស្នាដៃរបស់អ្នកស្លាប់ ជាពិសេស គឺថាអំពើភេរវកម្មបំភិតបំភ័យនឹងកើតមានឡើងគឺត្រូវរក្សាទុកនៅក្នុងផ្ទះរបស់ សាឡុត ស ឬ ប៉ុល ពត គឺគាត់ជាទទួលខុសត្រូវម្នាក់ឯង។

[១៥:៤៤:២៥]

ចៅក្រម រ៉ូប៊ឺត ដេកសិន ក៏បាននិយាយដូចខាងក្រោមនេះដែរ៖

ទោះបីជាយើងដេញដោលជំហរជនជាប់ចោទទាំងនេះខ្លាំងយ៉ាងណាក្តី ពួកគេមិនដែលឆ្លើយដាក់បុគ្គលនៅរស់ថា មានពិរុទ្ធភាពឡើយ ត្បិតនេះជាសេចក្តីល្បងដែលពួកគេសញ្ជឹងគិតដំណើរការជោគវាសនាដ៏អស្ចារ្យដែលថា មនុស្សអាក្រក់ស្លាប់ មនុស្សល្អនៅរស់។ គំនិតនេះស្ទើរតែគួរឲ្យយើងមានការចាប់អារម្មណ៍បំផុត។ មេដឹកនាំអាក្រក់ដែលជនជាប់ចោទមួយចំនួនប្រជែងគ្នាដើម្បីទម្លាក់កំហុសនិងស្តីបន្ទោសនោះ គឺហ៊ីត្លែរ។ គាត់គឺជាមនុស្សដែលជនជាប់ស្ទើរតែទាំងអស់បានឆ្លើយទម្លាក់កំហុសដាក់។ ខ្ញុំមិនបានមានគំនិតផ្ទុយពីគំនិតទាំងនេះទេ ហើយខ្ញុំក៏មិនបដិសេធទស្សនៈដែលថាមេដឹកនាំស្លាប់ និងអ្នកបាត់ខ្លួនទាំងនោះក៏មានពិរុទ្ធភាពដែរ។ បើឧក្រិដ្ឋកម្មដែលមានពិរុទ្ធភាពកម្រិតខ្ពស់បែបនេះបែរជាបាត់បង់សារៈសំខាន់នោះ វាអាចជាផ្នែកដ៏អាក្រក់បំផុត។ ប៉ុន្តែពិរុទ្ធភាពរបស់ពួកគេមិនអាចដោះបន្ទុកជនជាប់ចោទដែលនៅរស់ឡើយ។ ហ៊ីត្លែមិនបាននាំយកការទទួលខុសត្រូវទាំងអស់ចូលក្នុងផ្នូររបស់គាត់ឡើយ។ ពិរុទ្ធភាពទាំងអស់ត្រូវបានវេចខ្ចប់ជាមួយសាកសពហ៊ីត្លែបានទេ គឺអ្នកស្លាប់ដែលរស់ *(ស៊ីក)*។ ដូច្នេះ អ្នកដែលនៅរស់ក៏ត្រូវទទួលខុសត្រូវចំពោះមនុស្សមួយលាននាក់ ដែលមិនមែន ប៉ុល ពត ម្នាក់ទេ។ បុរសទាំងបីនេះ គឺជាតួអង្គសំខាន់ជាមួយ ប៉ុល ពត។ ពួកគាត់បានរៀបចំកម្មវិធីជាច្រើនឆ្នាំជាមួយ ប៉ុល ពត មុននឹងគេចូលកាន់អំណាច។ ភស្តុតាងនឹងបង្ហាអំពីការចូលរួមម្នាក់ៗក្នុងផែនការឧក្រិដ្ឋក្នុងការអនុវត្តនូវផែនការដែលនាំឲ្យមានបទឧក្រិដ្ឋដ៏អាក្រក់នេះ។

[១៥:៤៦:២៥]

លោក លោកស្រីនឹងមិនបានឮអំពីពាក្យថ្មីៗ អំពីការជំទាស់អំពីអ្នកណាម្នាក់ អំពីបទឧក្រិដ្ឋដែលថាមិនបានកើតឡើងចំពោះមុខពួកគាត់ក្នុងឆ្នាំ១៩៧៥ និង៧៩ទេ។ សូមចងចាំថា នៅពេលដែលអ្នកណាម្នាក់ព្យាយាមអះអាងថា អំណាចគឺថាខ្លួនមិនបានដឹងទាំងអស់ ខ្លួនបានដឹងខ្លះ ហើយបណ្តាលឲ្យមានការបំផ្លាញ និងទារុណកម្មលើពលរដ្ឋខ្លួនឯងនោះ។

ខ្ញុំសូមសង្កត់ធ្ងន់នូវចំណុចទីនេះ គឺថាការជំនុំជម្រះត្រូវតែយុត្តិធម៌។ សហព្រះរាជអាជ្ញាមានបន្ទុកបង្ហាញភស្តុតាងឲ្យលើសពីវិមតិ-- ហើយយើងត្រូវបញ្ជាក់ថា ហេតុការណ៍នៅក្នុងដីកាដំណោះស្រាយពិតជាបានកើតឡើង។ ជនជាប់ចោទទាំងបីត្រូវចាត់ទុកថាជាជនគ្មានទោសរហូតទាល់តែរកឃើញពិរុទ្ធភាព។ ជនជាប់ចោទមានសេរីក្នុងការមានមេធាវីការពារ ដែលយើងគិតថាពួកគាត់មាន។ គេអាច

ដេញដោលភស្តុតាងដែលប្រឆាំងពួកគេ ហើយមិនមានជនណាម្នាក់នឹងត្រូវបង្ខំឲ្យទទួលស្គាល់ភស្តុតាងប្រឆាំងនឹងគាត់ទេ។

មនុស្សជាច្រើននៅក្នុងប្រទេសនេះអាចយល់ថា បើផ្អែកសោកនាដកម្មលើមនុស្សជាតិ ដែលពួកគេបានប្រព្រឹត្ត យើងមិនគប្បីផ្តល់សិទ្ធិរបស់ទៅបុរសទាំងបីនេះទេ។ តែសូមយើងស្រមៃថា បើត្រូវកាត់ទោសពួកគាត់ ហើយយើងត្រូវធ្វើទារុណកម្មសាក្សី ដើម្បីយកការប្តឹងទៅលើពួកគាត់ទាំងបីនេះវិញ វាអាចនឹងជាកំហុសមួយ។ ជាការល្អយើងត្រូវតែថ្លែងអំណរគុណដល់ប្រជាជនកម្ពុជា ដែលថាពួកគេផ្តល់សិទ្ធិ គេរង់ចាំដ៏យូរឲ្យអ្នកទាំងបីនេះមានការកាត់ទោសដោយច្បាប់។

[១៥:៤៨:១៤]

ខ្ញុំនឹងបញ្ជាក់អំពីសារៈសំខាន់នៃគោលការណ៍យុត្តិធម៌ ហើយយើងត្រឡប់ទៅឆ្នាំ១៩៧៩ ដែលថាតើពលរដ្ឋកម្ពុជាបានឃើញអ្វីខ្លះ ពេលដែលគេត្រឡប់មកផ្ទះកំណើតរបស់គេវិញ ក្រោយពីខ្មែរក្រហមបានធ្លាក់ពីអំណាចទៅនោះ? ទីក្រុងភ្នំពេញ ហើយនិងទីប្រជុំជននៅក្នុងក្រុង គឺមិនមានសញ្ញាថាមានជីវិតរស់នៅទេ មន្ទីរស-២១ ជាមន្ទីរសន្តិសុខនៅភ្នំពេញ បង្ហាញអំពីការងារដែលស្ថិតនៅក្នុងដៃផលិតនគរបាលរបស់ខ្មែរក្រហម។ គឺមានមនុស្សត្រូវបានសម្លាប់ ទារុណកម្មដោយរបបនេះ ការបំផ្លាញនូវទីកន្លែងមួយចំនួន សាកសពមនុស្សដែលស្លាប់ អ្នកដែលបាត់បង់អ្នកជាទីស្រឡាញ់ និងសមាជិកក្រុមគ្រួសារត្រូវបានកប់រាយប៉ាយទូទាំងប្រទេស។

[១៥:៤៩:១៣]

ទាំងអស់នេះ គឺជាចំនួនខ្លះៗមួយផ្នែកតូច ដែលលោក នួន ជា, អៀង សារី, នួន ជា បានប្រព្រឹត្តទៅលើប្រជាជនរបស់ខ្លួន។ ឥឡូវនេះខ្ញុំនឹងចាប់ផ្តើមលើកឡើងអំពីតួនាទី និងទំនាក់នៃជនជាប់ចោទទាំងបីមុនឆ្នាំ៧៥។ ទំនាក់ទំនងដ៏ជិតស្និទ្ធរវាងជនជាប់ចោទទាំងនេះ កើតមានតាំងពីទសវត្សរ៍ឆ្នាំ១៩៥០ នៅអៀង សារី, ខៀវ សំផន និង ប៉ុល ពត ដែលនៅពេលនោះមានឈ្មោះថា សាឡុត ស ជានិស្សិតនៅទីក្រុងប៉ារីស និងនៅពេលជនទាំងនេះបានបង្កើតសមាគមនិស្សិតម៉ាក្ស-លេនីន ដើម្បីជំរុញនូវបដិវត្តន៍កុម្មុយនីស្តក្នុងគោលបំណងធ្វើជាមធ្យោបាយ ដើម្បីទទួលបានឯករាជ្យសម្រាប់ប្រទេសកម្ពុជា។ ប៉ុល ពត និង អៀង សារី បានក្លាយជាបងប្អូនថ្លៃនឹងគ្នា ដោយជនទាំងពីរបានរៀបការជាមួយ ខៀវ ប៉ុណ្ណារី និង ខៀវ ធីរិទ្ធ ដែលនៅពេលនេះមានឈ្មោះថា អៀង ធីរិទ្ធ។

ក្រោយពីវិលត្រឡប់មកពីប្រទេសបារាំងវិញជនទាំងនេះបានរួបរួមកម្លាំងគ្នាជាមួយនឹង នួន ជា

ដែលបានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជាមុនគេ នៅក្នុងពេលរស់នៅប្រទេសថៃក្នុងទសវត្សរ៍ទីឆ្នាំ ១៩៤០ ហើយធ្វើការ និងសិក្សាភាសាច្បាប់នៅក្រសួងការបរទេស។ នៅទីនោះ នួន ជា បានសិក្សាច្បាប់ និងបម្រើការងារនៅក្រសួងការបរទេស។ នួន ជា នៅតែចូលរួមយ៉ាងសកម្មក្នុងចលនាកុម្មុយនីស្តក្រោយពីវិលត្រឡប់មកពីប្រទេសកម្ពុជាវិញ។

[១៥:៥០:៥៦]

សមាជិកមួយក្នុងចំណោមនោះ យើងឃើញមាន ប៉ុល ពត ដែលក្រោយមកមាន អៀង សារី ចូលរួមផងដែរ។ ជនទាំងនេះបានរួមគ្នាបានចាប់ផ្តើមរៀបចំការបង្កើតបក្សកុម្មុយនីស្តថ្មីមួយនៅក្នុងប្រទេសកម្ពុជា។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ប៉ុល ពត, នួន ជា និង អៀង សារី បានចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមតូចមួយនៅទីស្នាក់ការកម្មករក្នុងស្ថានីយរថភ្លើងក្នុងទីក្រុងភ្នំពេញ ដើម្បីបង្កើតបក្សពលករកម្ពុជា ដែលជាបក្សរៀមច្បងនៃបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងពេលសន្និបាតបក្សលើកទីមួយ នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខា ពោលគឺបងទីពីរដែលជាតួនាទីទីមួយឲ្យជនរូបនេះកាន់កាប់អំណាចជាងទសវត្សរ៍ក្រោយពីពេលនោះ។ នៅពីក្រោមនោះ នួន ជា មាន ប៉ុល ពត ដែលត្រូវបានជ្រើសតាំងជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង អៀង សារី ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការមជ្ឈិម និងសមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍។

[១៥:៥២:០១]

លោក លោកស្រីចៅក្រម ខ្ញុំបានរៀបរាប់នូវហេតុការណ៍នេះដែលបានកើតឡើង១៥ឆ្នាំមុនពេលជម្លៀសទីក្រុងភ្នំពេញដោយបង្ខំ ពីព្រោះតែសេចក្តីសម្រេចកំណត់ជោគវាសនាបានធ្វើឡើងដោយជនជាប់ចោទទាំងនេះនៅក្នុងកិច្ចប្រជុំពេលនោះ ដើម្បីអនុម័តមាគ៌ាចម្បងរបស់បក្សអនុញ្ញាតឲ្យការប្រើប្រាស់អំពើហិង្សាប្រដាប់អាវុធ ដើម្បីកម្ចាត់ចោលពួកសក្តិភូមិ ពួកមូលធន និងខ្មាំងផ្សេងទៀត។ ផែនការនេះមានអនុភាពរហូតមកទល់ពេលជនជាប់ចោទក្តោបក្តាប់អំណាចនៅក្នុងខែមេសា ឆ្នាំ១៩៧៥។

[១៥:៥២:៣៥]

គោលនយោបាយសម្លាប់រង្គាលនេះ បានរៀបចំឡើងដោយជនជាប់ចោទទាំងនេះ ដែលកំពុងអង្គុយក្នុងបន្ទប់នេះកាលពីជាង៥០ឆ្នាំមុន ហើយគោលនយោបាយនេះបានធ្វើឲ្យមានការកាប់សម្លាប់ពលរដ្ឋកម្ពុជារាប់សែននាក់ គឺសម្លាប់ឲ្យអស់។ ចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៦០ រហូតមកដល់ខែមេសា ឆ្នាំ១៩៧៥ ជនជាប់ចោទទាំងនេះ បានបន្តធ្វើការងាររួមគ្នា ដើម្បីសម្រេចគោលបំណងរួមនៃការធ្វើ

បដិវត្តន៍នៅកម្ពុជា។ មកទល់ត្រឹមសន្និបាតបក្សលើកទីពីរ ក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ លេខាបក្ស ទូ សាមុត ត្រូវបានចាប់ខ្លួន។ នួន ជា ខ្លួនឯងជាអ្នកឧទ្ទេសនាម សូមឲ្យ ប៉ុល ពត ក្លាយជាលេខាបក្សថ្មី ឬបងទីមួយ។ នួន ជា នៅតែធ្វើជាអនុលេខា ហើយ អៀង សារី ត្រូវបានក្លាយជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ ពោល គឺជាសមាជិកបក្សដែលមានឋានៈខ្ពស់បំផុតទីបី។ រយៈពេលប៉ុន្មានខែក្រោយមក អៀង សារី, ប៉ុល ពត, សុន សេន និងមេដឹកនាំបក្សផ្សេងទៀតបានបោះពុម្ពផ្សាយឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីវាយនាមពួកឆ្វេងនិយម។ ជនទាំងអស់នេះបានរត់ចូលព្រៃ ជាដំបូងទៅជំរំទ័ពវៀតណាមនៅព្រំដែន និងក្រោយមករត់ទៅតំបន់ដាច់ស្រយាលមួយក្នុងខេត្តរតនគិរី។

[១៥:៥៣:៤៨]

មូលដ្ឋានថ្មីរបស់បក្សនៃជនទាំងនេះត្រូវបានកំណត់ឈ្មោះថាជាមន្ទីរ១០០ ចាប់ពីពេលនេះហើយ រចនាសម្ព័ន្ធបក្សសាំញ៉ាំមួយបានរីករាលដាលនៅក្នុងប្រទេសកម្ពុជា។ នួន ជា ដែលមានអត្តសញ្ញាណជាមេដឹកនាំបក្សមួយរូបនោះ នៅបន្តលាក់ខ្លួនក្នុងអំឡុងពេលនោះបានស្នាក់នៅក្នុងទីក្រុងភ្នំពេញ និងទទួលខុសត្រូវលើប្រតិបត្តិការរបស់បក្សលើតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា។ ជនជាប់ចោទទាំងនេះបានជួបប្រជុំនៅក្នុងអំឡុងឆ្នាំទាំងនោះ ដើម្បីធ្វើសេចក្តីសម្រេចសំខាន់ៗតាមរយៈគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម។ នៅពាក់កណ្តាលឆ្នាំ១៩៦៧ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចបើកការតស៊ូប្រដាប់អាវុធជាចំហមួយឆ្នាំក្រោយមកនៅក្នុងខែមករា ឆ្នាំ១៩៦៨ គឺ នួន ជា ដែលជាអ្នកបញ្ជូនបញ្ជាឲ្យកងកម្លាំងទ័ពព្រៃរបស់បក្សកុម្មុយនីស្តកម្ពុជាវាយប្រហារជាលើកដំបូងទៅលើមូលដ្ឋានទ័ពរបស់រដ្ឋាភិបាលនៅខាងត្បូងខេត្តបាត់ដំបង។ នៅក្នុងថ្ងៃនោះហើយ ដែលបក្សកុម្មុយនីស្តកម្ពុជាប្រារព្ធពិធីនៃថ្ងៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា។

[១៥:៥៥:០០]

ជនជាប់ចោទ ខៀវ សំផន ត្រូវបានគេជឿជាក់ថា បានចូលរួមជាមួយបក្សនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៥០ ខណៈនៅប្រទេសបារាំង ក៏ប៉ុន្តែជននេះបានបិទបាំងការស្មោះស្ម័គ្ររបស់ខ្លួនក្រោយពីវិលត្រឡប់មកពីប្រទេសកម្ពុជាវិញ នៅក្នុងឆ្នាំ១៩៥៩ ដើម្បីទទួលតួនាទីសកម្មមួយក្នុងកិច្ចសាធារណៈរបស់ប្រទេសនេះ។ នៅក្នុងឆ្នាំ១៩៦២ ខៀវ សំផន បានចូលរួមជាមួយនឹងបក្សសង្គមរាស្ត្រនិយមដែលជាបក្សកាន់អំណាច ហើយត្រូវបានជ្រើសតាំងជាសមាជិករដ្ឋសភា ព្រមទាំងតែងតាំងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ ទោះបីជាយ៉ាងនេះក្តី ដោយសារមានភាពសង្ស័យជាមួយភាពពួកឆ្វេងនិយម ខៀវ

សំផន ត្រូវបានបង្ខំឲ្យលាឈប់ពីតំណែងរបស់ខ្លួន ហើយបានស្ថិតនៅក្រោមការគំរាមកំហែងនៃការចាប់ខ្លួនជាដរាប។ ដោយត្រូវបានគេដៅទុកចំពោះជំនឿនយោបាយរបស់ខ្លួន ខៀវ សំផន បានដឹងយ៉ាងច្បាស់អំពីផលវិបាកនៃការផែនការបក្សកុម្មុយនីស្តកម្ពុជានៅក្នុងការចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ខ្មាំងនយោបាយ។ នៅក្នុងខែមេសា ឆ្នាំ១៩៦៧ ដោយប្រឈមនឹងការស្តីបន្ទោសចំពោះកុបកម្មរបស់និស្សិត និងការកោះហៅឲ្យចូលខ្លួននៅមុខតុលាការយោធា ខៀវ សំផន រួមជាមួយនិងបុគ្គលពីររូបបានរត់គេចពីភ្នំពេញចូលព្រៃក្រោមការពាររបស់សមាជិកគណៈមជ្ឈិមកុម្មុយនីស្តកម្ពុជា គឺតាម៉ុក។

[១៥:៥៦:១០]

ដោយបាត់មុខមតិទស្សនៈ និងដោយសន្មតជាទូទៅថា ស្លាប់ ខៀវ សំផន ហ៊ូ នឹម និងហ៊ូ យន់ បានលេចមុខសាជាថ្មីនាពេលបីឆ្នាំក្រោយមក ដោយហៅឈ្មោះ "បិសាចបីរូបនៃខ្មែរក្រហម" នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ជាថ្ងៃដែលចង់ចាំមួយនៅជំនាន់នោះ ព្រះមហាក្សត្រជីវិតតម្កល់លើត្បូងព្រះបាទនរោត្តមសីហនុ ជាព្រះវរបិតានាពេលនោះ ត្រូវបាន លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ពីតំណែង។ របបសាធារណរដ្ឋខ្មែរបានចូលកាន់អំណាច ប្រវត្តិសាស្ត្របានបើកផ្លូវឲ្យបក្សកុម្មុយនីស្តកម្ពុជាចូលកាន់អំណាច ដែលជនជាប់ចោទទាំងអស់នោះពុំស្ទាក់ស្ទើរក្នុងការចាប់យកអំណាចឡើយ។ បក្សបានបង្កើតសម្ព័ន្ធភាពជាមួយព្រះបាទនរោត្តម សីហនុ ដែលរួមមានចលតតស៊ូមួយគឺ រណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលនិរទេសនៅក្រុងប៉េកាំង គឺរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ក្នុងពេលតស៊ូនឹងបដិវត្តន៍ ជនជាប់ចោទបានទទួលតួនាទីបន្ថែមដោយពង្រីនូវវង្វង់ឥទ្ធិពលនិងរចនាសម្ព័ន្ធគ្រប់គ្រងនាពេលចុងក្រោយ។ នួន ជា បានចាកចេញពីភ្នំពេញដើម្បីរួបរួមជាមួយកម្មាភិបាលរបស់ខ្លួននៅទីស្នាក់ការបក្សក្នុងខេត្តរតនគិរី។

[១៥:៥៧:៣៥]

មន្ទីរ១០០ ត្រូវបានផ្លាស់ប្តូរទីតាំងម្តងទៀតទៅព្រំដែនខេត្តកំពង់ចាមនិងកំពង់ធំ។ មកទល់ត្រឹមខែឧសភា ឆ្នាំ១៩៧០ ខៀវ សំផន បានកាន់កាប់តួនាទីជាន់ខ្ពស់ក្នុងរចនាសម្ព័ន្ធស៊ីវិល និងយោធា នៃចលនាតស៊ូដោយកាន់កាប់តួនាទីជាឧបនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិ។ តាមភស្តុតាង ខៀវ សំផន បានបម្រើបក្សល្អ ហើយនៅពេលសន្និបាតបក្សលើកទីបី ក្នុងឆ្នាំ១៩៧០ ខៀវ សំផន ត្រូវបានដំឡើងតំណែងជាសមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍។ មកត្រឹមខែធ្នូ ឆ្នាំ១៩៧០ អៀង សារី ស្នាក់នៅហាណូយ និងបានបង្កើតស្ថានីយវិទ្យុផ្សាយគាំទ្រចលនា

តស៊ូ។ មកត្រឹមខែមេសា ឆ្នាំ១៩៧១ អៀង សារី បានប្តូរទៅស្នាក់នៅទីក្រុងប៉េកាំង ដែលជាអាសនៈនៃរដ្ឋាភិបាលនិរទេស ដើម្បីប្រមូលការគាំទ្រដល់បក្សកុម្មុយនីស្តកម្ពុជាពីបរទេស ហើយ អៀង សារី បានតាមដាន និងគ្រប់គ្រងចលនាតស៊ូជំនួសមុខឲ្យបក្ស។ អៀង សារី បានត្រឡប់មកកម្ពុជាដើម្បីចូលរួមប្រជុំនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។

[១៥:៥៨:៤៥]

នៅក្នុងពេលប្រជុំមួយនោះ ក្នុងខែមិថុនា ឆ្នាំ១៩៧៤ មេដឹកនាំបក្សបានឯកភាពគ្នាជាលើកដំបូងលើយុត្តិសាស្ត្រជម្លៀសភ្នំពេញ ក្រោយពីការរំដោះរបស់ខ្លួន។

លោក លោកស្រីចៅក្រម នៅពេលនេះគឺខ្ញុំបញ្ចប់ផ្នែកមួយរបស់ខ្ញុំ គឺផ្នែកទីមួយ ដែលគិតថាគួរត្រឹមថ្ងៃនេះ ហើយចាំថ្ងៃស្អែកទើបខ្ញុំចូលទៅដល់ផ្នែមួយទៀត។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអន្តរជាតិ លោកមានពេលវេលា១៥នាទីទៀត ដើម្បីក្នុងការធ្វើបទបង្ហាញអំពីបទចោទប្រកាន់នេះ។

[១៥:៥៩:៣៤]

**លោក អាន់ឌ្រូ ខេលី៖**

នៅពេលនេះ គឺខ្ញុំសូមបង្ហាញចាប់ពីហេតុការណ៍-- ចាប់ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ដែលស្តីអំពីតួនាទីរបស់ជនជាប់ចោទ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមកាន់កាប់អំណាចនៅក្នុងប្រទេសកម្ពុជា ហើយជនជាប់ចោទចាប់ផ្តើមអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់បក្ស។ ប៉ុល ពត, នួន ជា និង ខៀវ សំផន បានធ្វើដំណើរទៅភ្នំពេញរួមគ្នា ដោយបានមកដល់នាថ្ងៃទី២០ ខែមេសា ឆ្នាំ ១៩៧៥។ អៀង សារី បានធ្វើដំណើរពីប្រទេសចិន មកដល់ភ្នំពេញក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយមកគឺនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៥។ ក្នុងរយៈពេលមួយខែក្រោយមក ជនជាប់ចោទ និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតធ្វើការរួមគ្នាដោយពីដំបូងនៅស្ថានីយ៍អយស្ម័យានភ្នំពេញ និងក្រោយមកនៅវិហារព្រះកែវមរកត ដើម្បីពិនិត្យចុងក្រោយលើគោលនយោបាយនិងផែនការសម្រាប់អនុវត្ត។ បណ្តាញនៃរចនាសម្ព័ន្ធធំមួយបានត្រៀមទុករួចជាស្រេច។ ផែនការដែលបានរៀបចំដោយជនជាប់ចោទនៅមជ្ឈិមបក្សបានបញ្ជូនទៅតាមភូមិភាគតំបន់ស្រុក និងតំណាងយោធា ក្នុងពេលប្រជុំធំចំនួន៦ថ្ងៃដែល

មាន ប៉ុល ពត និង នួន ជា ជាអធិបតី ដោយ នួន ជា នូវមាគ៌ាបក្សជូនអង្គប្រជុំ។ ក្នុងពេលប្រជុំថ្ងៃទីមួយ គឺថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ដែលបច្ចុប្បន្នជាទិវារំឭកថ្ងៃចងកំហឹងនៅកម្ពុជា ទិវានេះគឺជាការទទួលស្គាល់នូវគោលនយោបាយឧក្រិដ្ឋដែលជនជាប់ចោទ ដាក់ឲ្យអនុវត្តនៅពេលនោះ។

[១៦:០១:១០]

លោក លោកស្រីចៅក្រមជាទីគោរព! គោលនយោបាយទាំងនោះ គឺជាសោកនាដកម្មសម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយទាំងនេះបានដាក់នៅចំពោះមុខលោក លោកស្រីចៅក្រម ហើយនិងយកមកពិភាក្សាលម្អិតនៅថ្ងៃស្អែក។ ក្នុងរយៈពេលតែប៉ុន្មានខែជនជាប់ចោទបានប្តូរទៅមន្ទីរអចិន្ត្រៃយ៍ និងទីស្នាក់ការនានាដែលនៅទីនោះ ជនជាប់ចោទបានពង្រីក និងចាក់ឫសអំណាចគ្រប់គ្រងប្រទេស។ ទីតាំងមួយឈ្មោះ ក-១ គឺជាមន្ទីរចម្បង ដែលយើងឃើញនៅក្នុងអេក្រង់នេះ និងជាកន្លែងស្នាក់នៅរបស់បងទីមួយ ប៉ុល ពត។ ទីតាំងនេះស្ថិតនៅមុខទន្លេបាសាក់គឺ នៅខាងត្បូងរដ្ឋសភានាពេលបច្ចុប្បន្ន។ ទីតាំងនេះមានអគារពីរជាន់ ហ៊ុមព័ទ្ធទៅដោយរបងឈើ និងខ្សែភ្លើង ដោយមានប៉មយាមចំនួនបួន នៅតាមជ្រុងនីមួយៗនៃទីតាំងនោះ ដែលមួយក្រុមៗមានអ្នកយាមប្រហែលពី៥០ទៅ៦០នាក់។

មន្ទីរក-៣ គឺនៅខាងលិចព្រះបរមរាជវាំងត្រង់ផ្លូវប៉ាស្ទ័រ គឺជាប្លុកផ្ទះល្វែង ទីតាំងនេះព័ទ្ធទៅដោយរបងស័ង្កសី និងបន្លាលួស ហើយមានឆ្មាំយាមល្បាត។ អ្នកយាមនិរសារ និងអ្នកបើកឡានមួយចំនួនធ្វើការងារជូនជនជាប់ចោទនៅមន្ទីរក-១ និងក-៣ អ្នកទាំងនេះ នឹងរៀបរាប់ជូនលោក លោកស្រីចៅក្រម នូវរបៀបដែល នួន ជា, អៀង សារី និង ខៀវ សំផន រស់នៅជាមួយគ្នានៅមន្ទីរក-៣ ស្ទើតែរាល់ថ្ងៃជាមួយគ្នា ធ្វើការស្ទើតែរាល់ថ្ងៃជាមួយគ្នានៅមន្ទីរក-១ និងត្រឡប់ទៅក-៣ វិញនៅពេលយប់។ ជនជាប់ចោទនីមួយៗក៏មានមន្ទីរ និងតួនាទីផ្សេងទៀតនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យដែរ។ ក្រៅពីមុខនាទីថ្នាក់ខ្ពស់របស់ខ្លួននៅក្នុងបក្ស ជនជាប់ចោទទាំងបីត្រូវបានតែងតាំងឲ្យកាន់កាប់តួនាទីកំពូលនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលបានបង្កើតឡើងនៅក្នុងខែមេសា ឆ្នាំ១៩៧៦ ដើម្បីជំនួសរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដូចបានបង្ហាញនៅទីនេះ។

នួន ជា គឺជាប្រធានសភាតំណាងប្រជាជន ដែលជាស្ថាប័ននីតិបញ្ញត្តិរបស់រដ្ឋ។ អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស និង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ពោលគឺជាប្រមុខរដ្ឋ។

[១៦:០៣:៤២]

លោក លោកស្រីចៅក្រមជាទីគោរព! ខណៈការតែងតាំងតំណែងដល់ជនទាំងនេះ បង្ហាញយ៉ាងច្បាស់នូវឋានៈជាមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា និងបានផ្តល់អំណាចបុព្វសិទ្ធិ និងការទទួលខុសត្រូវអង្គហេតុទាំងឡាយ និងបង្ហាញឲ្យឃើញថា អំណាចពិតប្រាកដកាន់កាប់ដោយជនជាប់ចោទម្នាក់ៗ គឺកើតចេញពីតួនាទីរបស់ជនទាំងនេះ ដែលស្ថិតនៅក្នុងជួរបក្ស។ នួន ជា ក្នុងនាមជាអនុលេខាបក្ស អនុលេខាគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ទទួលបន្ទុកលើការទទួលខុសត្រូវលើកិច្ចការបក្ស និងអប់រំបណ្តុះបណ្តាលនយោបាយដល់កម្មាភិបាល។ អៀង សារី ក្នុងនាមជាសមាជិកពេញសិទ្ធិនៃសមាជិកពេញសិទ្ធិចំនួនប្រាំរូបរបស់គណៈអចិន្ត្រៃយ៍ គឺជាបុគ្គលទទួលភារកិច្ចឲ្យតំណាងរបបនេះក្នុងកិច្ចការអន្តរជាតិ។ ខៀវ សំផន ជាសមាជិកគណៈមជ្ឈិម សមាជិកតាមព្រឹត្តិហេតុនៃគណៈអចិន្ត្រៃយ៍ ប្រធានមន្ទីរនយោបាយ៨៧០ និងទទួលខុសត្រូវត្រួតពិនិត្យកិច្ចការ ពាណិជ្ជកម្មនៅទាំងប្រទេស។

អៀង សារី ខ្លួនឯងបានលើកឡើងនៅក្នុងការសម្ភាសន៍នៅក្នុងខែឧសភា ឆ្នាំ១៩៧៧ ថា កម្ពុជាប្រជាធិបតេយ្យ គឺគ្រប់គ្រងដោយអង្គការ។ អង្គការគឺជាបក្សតែមួយគត់ និងជារដ្ឋតែមួយគត់។ រដ្ឋគឺជាបក្ស ហើយបក្សគឺជារដ្ឋ។ រដ្ឋនិងបក្ស គឺតែមួយ មានតែអង្គការតែប៉ុណ្ណោះ។

[១៦:០៥:១០]

លោក លោកស្រីចៅក្រមជាទីគោរព! នេះគឺជាមូលដ្ឋានដូចគ្នានៃប្រពន្ធ័ផ្តាច់ការក្នុងការគ្រប់គ្រងសង្គមដែលបានរៀបចំឡើង និងអនុវត្តដោយជនជាប់ចោទ។

អនុញ្ញាតឲ្យខ្ញុំបង្ហាញ និងលើកឡើងដោយឡែកៗពីគ្នារបស់ជនជាប់ចោទនៅក្នុងបក្ស។ នៅក្នុងសេចក្តីប្រកាសជូនសហចៅក្រមស៊ើបអង្កេត និងនៅក្នុងស្នាដៃនិពន្ធថ្មីមួយរបស់ខ្លួន ខៀវ សំផន បានលើកឡើងចំណុចមួយថា ខ្លួនមិនមានអំណាចពិតប្រាកដនៅក្នុងតួនាទីខ្លួនជាប្រធានគណៈប្រធានរដ្ឋនោះទេ។ ក៏ប៉ុន្តែការអះអាងនេះ គឺជាអំណាច និងសិទ្ធិដែលខៀវ សំផន កាន់កាប់ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ដែលជាជនជាប់ចោទជាសមាជិកគណៈមជ្ឈិម និងសមាជិកចូលរួមប្រជុំយ៉ាងទៀងទាត់នៃគណៈអចិន្ត្រៃយ៍។

[១៦:០៦:០២]

គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម គឺជាស្ថាប័នមានអំណាច និងខ្ពស់បំផុតនៅក្នុងបក្សកុម្មុយ

នីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ។ ស្ថាប័នមន្ទីរភូមិភាគកម្ពុជាប្រជាធិបតេយ្យទាំងអស់ រួមមានភូមិភាគកងពលឃោធាមជ្ឈិម និងក្រសួងរដ្ឋដែលធ្វើរបាយការណ៍ទៅថ្នាក់លើរបស់បក្ស។ យោងតាមលក្ខន្តិកៈគ្រប់គ្រងបក្ស គណៈមជ្ឈិម គឺជាអង្គភាពប្រតិបត្តិការជាន់ខ្ពស់បំផុតនៅទូទាំងប្រទេសដោយទទួលខុសត្រូវលើការអនុវត្តមាគ៌ាបក្ស និងលក្ខន្តិកៈបក្ស ណែនាំគ្រប់ភូមិភាគ តំបន់ អង្គការបក្សដើម្បីអនុវត្តសកម្មភាពទាំងឡាយឲ្យស្របទៅតាមមាគ៌ាបក្ស និងដើម្បីគ្រប់គ្រងកម្មាភិបាល និងសមាជិកបក្ស។

ខៀវ សំផន បានទទួលស្គាល់ថា ខ្លួនជាសមាជិកពេញសិទ្ធិមួយរូបក្នុងចំណោមសមាជិកពេញសិទ្ធិទាំង៣០រូប នៃគណៈមជ្ឈិម ដែលបានជួបប្រជុំរៀងរាល់ប្រាំមួយខែ។ ដោយហេតុថាគណៈមជ្ឈិមរួមមានសមាជិកស្ថិតនៅទូទាំងប្រទេស និងជួបប្រជុំគ្នារៀងរាល់ប្រាំមួយខែ ការអនុវត្តអំណាចប្រចាំថ្ងៃត្រូវបានកាន់កាប់ដោយគណៈអចិន្ត្រៃយ៍ ដែលរួមមានសមាជិកពេញសិទ្ធិចំនួនប្រាំរូប លេខា ប៉ុល ពត អនុលេខា នួន ជា, អៀង សារី, សោ ភឹម និងតាម៉ុក និងសមាជិកត្រៀមពីររូបទៀត គឺសុន សេន និងវន វ៉េត។

[១៦:០៧:៣០]

ខៀវ សំផន បានលើកឡើងថាគណៈអចិន្ត្រៃយ៍បានជួបប្រជុំយ៉ាងហោចណាស់មួយដងក្នុងមួយសប្តាហ៍ និងញឹកញាប់ជាងនេះ ពីព្រោះតែបក្សកុម្មុយនីស្តកម្ពុជាងប់ងល់នឹងការលាក់ការណ៍សម្ងាត់ការបំផ្លាញឯកសារ។ យើងពុំមានគ្រប់កំណត់ហេតុប្រជុំរបស់គណៈកម្មាធិការទាំងនេះឡើយ។ ក៏ប៉ុន្តែសំណាងល្អ យើងមានឯកសារតំណាងគ្រប់គ្រាន់អាចឲ្យយើងយល់អំពីរបៀបគណៈអចិន្ត្រៃយ៍ធ្វើការប្រធានបទ និងកម្មវត្ថុក្នុងការពិភាក្សា និងបុគ្គលដែលចូលរួមប្រជុំ។

តារាងនេះឆ្លុះបញ្ចាំងអំពីការចូលរួមនៃបុគ្គលនីមួយៗ នៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការចំនួន១៧លើក ដែលយើងមានកំណត់ហេតុបង្ហាញបុគ្គលដែលមានវត្តមាន។ ដូចលោក លោកស្រីចៅក្រមបានឃើញ ខៀវ សំផន បានចូលនៅក្នុងបញ្ជីនេះចំនួន១៤លើក ក្នុងចំណោមកិច្ចប្រជុំ១៧លើក។ អង្គហេតុនេះ ខៀវ សំផន បានទទួលស្គាល់នៅចំពោះសហចៅក្រមស៊ើបអង្កេត។ ជាការពិត ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ច្រើនជាង អៀង សារី ដែលពេលខ្លះត្រូវអវត្តមានដោយសារធ្វើដំណើរទៅបរទេសច្រើនជាងសមាជិកពេញសិទ្ធិ គឺតាម៉ុក, សោម ភឹម និងសមាជិកត្រៀម សុន សេន និង វន វ៉េត។ មានតែ ប៉ុល ពត និង នួន ជា ដែលបានចូលរួមក្នុងកិច្ចប្រជុំ

គណៈអចិន្ត្រៃយ៍ច្រើនដងជាង ខៀវ សំផន។ កំណត់ហេតុទាំងនេះ ក៏ឆ្លុះបញ្ចាំងឲ្យឃើញ ខៀវ សំផន មានវត្តមាន និងពិភាក្សាអំពីបញ្ហាជាច្រើននៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍។ ចំណុចនេះ គឺវាផ្ទុយនឹងការអះអាងរបស់ជនជាប់ចោទជូនសហចៅក្រមស៊ើបអង្កេតថា ខ្លួនពុំដែលមានតួនាទីធ្វើសេចក្ដីថ្លែងការណ៍នៅក្នុង កិច្ចប្រជុំបែបនោះឡើយ។ ហេតុផលមួយទៀត ដែលមានសារៈសំខាន់ត្រូវយល់ដឹងអំពីទំនាក់ទំនងរវាងរដ្ឋនិងបក្សនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គឺការអះអាងរបស់ នួន ជា ជូនសហចៅក្រមស៊ើបអង្កេតថា ខ្លួនរវល់នឹងការងារនៃសភាតំណាងប្រជាជនដែលខ្លួនជាប្រធាន។ ហេតុដូច្នេះខ្លួនពុំពាក់ព័ន្ធនឹងស្ថាប័ននីតិប្រតិបត្តិឡើយ។

[១៦:០៩:៣៩]

ជាក់ស្ដែងសភាដែលទទួលបន្ទុកដោយ នួន ជា ពុំដែលជួបប្រជុំឡើយ ក៏ពុំដែលរៀបចំបោះឆ្នោតពុំដែលអនុវត្តច្បាប់សូម្បីតែមួយ ហើយពុំមានការជ្រើសតាំងផងដែរ។ ដែលចំណុចនេះផ្ទុយនឹងការឃោសនាដែលចាក់ផ្សាយក្នុងវិទ្យុរដ្ឋកម្ពុជាប្រជាធិបតេយ្យ។ ជាការពិត ជាក់ស្ដែងអំពីសភាតំណាងប្រជាជន បានឆ្លុះបញ្ចាំងនៅក្នុងកំណត់ហេតុនៃកិច្ចចប្រជុំគណៈអចិន្ត្រៃយ៍នាថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ដែលចូលរួមដោយ នួន ជា និង ខៀវ សំផន។ នៅក្នុងកិច្ចប្រជុំនោះ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្ដកម្ពុជាបានពិភាក្សាអំពីរបៀបដែលពួកគេមិនគួរនិយាយលេងសើចអំពីសភានៅចំពោះមុខប្រជាជន។ នៅទីនេះ យើងឃើញនូវកំណត់ហេតុរបស់គណៈកម្មាធិការទាំងនេះ។

[១៦:១០:៤២]

បើដូច្នេះទេ តើ នួន ជា គាត់ធ្វើកិច្ចការអ្វីនៅមន្ទីររដ្ឋសភា? អង្គជំនុំជម្រះនឹងបានស្ដាប់សក្ខីកម្មទៅលើបញ្ហានេះពីប្រធានមន្ទីរសន្តិសុខស-២១ គឺកាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលបានជួប នួន ជា រៀងរាល់បី ឬប្រាំថ្ងៃចន្លោះពីខែកញ្ញា ឆ្នាំ១៩៧៧ ទៅដល់ ខែមករា ១៩៧៩ តាមធម្មតាគឺជួបនៅមន្ទីររដ្ឋសភា។ នៅក្នុងកិច្ចប្រជុំនេះ នួន ជា បានផ្ដល់សេចក្ដីណែនាំទៅឲ្យ ឌុច ថាតើអ្នកណាដែលត្រូវចាប់ខ្លួន ហើយអ្នកណាដែលត្រូវកម្ទេចចោល។ ដូច្នេះ សូម្បីតែនៅក្នុងមន្ទីររដ្ឋសភា ការងារតែមួយគត់ដែល នួន ជា ធ្វើ បើតាមដែលយើងខ្ញុំដឹងគឺការធ្វើផែនការដើម្បីបន្តការកាប់សម្លាប់បន្តទៅទៀត។ ហើយនៅក្នុងករណីខ្លះ គឺបានហៅអ្នកទាំងនោះមកចូលរួមប្រជុំ រួចចាប់ខ្លួន និងយកពួកគេទៅកាន់មន្ទីរស-២១។

សភាតំណាងប្រជាជនគឺគ្រាន់តែស្ថាប័នក្លែងក្លាយដែលត្រូវបានរៀបចំឡើង ដើម្បីបង្ហាញអំពីទិដ្ឋភាពខាងក្រៅនៃសកម្មភាពរបស់កម្ពុជាប្រជាធិបតេយ្យ ដែលតាមការពិតគឺជារដ្ឋផ្ដាច់ការដែលត្រូវ

គ្រប់គ្រងដោយគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ហើយមន្ទីររបស់ នួន ជា គ្រាន់តែជាផ្នែកមួយនៃក្បាលម៉ាស៊ីនកាប់សម្លាប់តែប៉ុណ្ណោះ។ ការទទួលសខុសត្រូវរបស់ អៀង សារី គឺទទួលខុសត្រូវទៅលើនិស្សិតបញ្ញវន្តដែលវិលត្រឡប់មកពីបរទេស។ នៅក្នុងអំឡុងដំបូងនៃរបបនេះ ហើយគាត់ក៏បាននិយាយទៅដល់និស្សិតបញ្ញវន្តដែលមានទីតាំងនៅស្រុកបារាំង និងប្រទេសដទៃទៀត ដើម្បីបង្ហាញអំពីរូបភាពល្អប្រណីតដូចផ្កា នៃជីវិតរស់នៅក្រោមរបបនៃបក្សកុម្មុយនីស្តកម្ពុជា។

លោក លោកស្រី ចៅក្រមនឹងបានស្តាប់សក្ខីកម្មពីនិស្សិតបញ្ញវន្តដែលបានត្រឡប់មកប្រទេសកម្ពុជាក្រោយខែមេសា ឆ្នាំ១៩៧៥ តាមរយៈការបង្ហាញរបស់ អៀង សារី។ នៅពេលដែលពួកគេបានមកដល់អាកាសយានដ្ឋានពោធិ៍ចិនតុង ពួកគេបានជួបជាមួយនឹងកម្មាភិបាលក្រសួងការបរទេស លិខិតឆ្លងដែនរបស់ពួកគេត្រូវបានរឹបអូស កម្មសិទ្ធត្រូវបានរឹបអូស ហើយពួកគេត្រូវបានយកទៅឃុំឃាំងនៅក្នុងជំរំអប់រំកែប្រែ ក្រោមការត្រួតត្រារបស់ អៀង សារី នៅច្រាំងចម្រេះ និងបឹងត្របែក។ ហើយត្រូវទទួលការបំពាក់បំប៉នមនោគមន៍វិជ្ជា និងបង្ខំឲ្យធ្វើពលកម្ម អ្នកទាំងនោះក៏ត្រូវបានសម្រេចបញ្ជូនខ្លួនទៅកាន់មន្ទីរស-២១ និងសម្លាប់ចោល។ អៀង សារី បានសារភាពអំពីតួនាទីសំខាន់ក្នុងការត្រឡប់មកវិញរបស់អ្នកទាំងអស់នេះ។ សម្រង់សម្តី៖“ខ្ញុំមានការសោកស្តាយ ចំពោះការស្លាប់និស្សិតបញ្ញវន្តដោយសារខ្ញុំគឺជាអ្នកដែលបានប្រមូលពួកគេឲ្យមកជួយកសាងប្រទេសឡើងវិញ” ចប់សេចក្តីដកស្រង់។

លោកប្រធាននេះគឺជាចំណុចដែលខ្ញុំសុំផ្អាកត្រឹមប៉ុណ្ណោះសិន។

[១៦:១៣:៣២]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ សហព្រះរាជអាជ្ញាអន្តរជាតិ ឥឡូវនេះពេលវេលាសមល្មមនឹងត្រូវសម្រាក ហើយសម្រាប់សវនាការថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងបន្តទៅធ្វើនៅព្រឹកថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួនទៅ សូមភាគីនិងសាធារណជនជ្រាប សូមសម្រាកចុះ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ចុះ នឹងបង្គាប់ឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៤:២៣ នាទី)*